## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន
# ក្នុងទីផ្សារមូលបត្រកម្ពុជា

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**


តាក់តែងឡើងដោយ
និស្សិតឈ្មោះ៖ **ម៉ិល ចន្ថា**
**សម្បត្តិ រ៉ាវី**

សាស្ត្រាចារ្យណែនាំ
លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ មុិល ចន្ទា និង សម្បត្តិ រ៉ាវី ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ច ឆ្នាំទី៤ ជំនាន់ទី ១៦ ក្រុម E4MC2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣-២០១៧ សូមថ្លែងនូវសេចក្តីដឹងគុណ និងសេចក្តីអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- លោកអ្នកមានគុណទាំងពីរ គឺលោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់មើលថែរក្សា អប់រំ ក្រើនរំលឹក ផ្តល់ដំបូន្មាន ព្រមទាំងទំនុកបម្រុងផ្នែកហិរញ្ញវត្ថុ និងស្មារតីគ្រប់បែបយ៉ាងដល់កូន ដែលអាចអោយកូនមានលទ្ធភាពបន្តការសិក្សាថ្នាក់បរិញ្ញាបត្ររហូតដល់បញ្ចប់ការសិក្សាផ្នែកមួយនេះ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្រ្តាចារ្យ និងបុគ្គលិកទាំងអស់ដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់បណ្តុះបណ្តាល បង្ហាត់បង្រៀន អប់រំ និងបង្ហាញផ្លូវដើម្បីក្រេបយកចំណេះដឹងសម្រាប់យកទៅប្រើប្រាស់ជាត្រីមុខក្នុងការបំភ្លឺផ្លូវនាពេលអនាគត។
- លោកគ្រូ **ឈាង ហ៊ុយ** ជាសាស្រ្តាចារ្យណែនាំ ដែលបានជួយដឹកនាំ បង្ហាត់បង្ហាញ ផ្តល់យោលបល់ល្អៗ និងលោកបានចំណាយពេលដ៏មានតម្លៃ និងមមាញឹកយ៉ាងខ្លាំងដើម្បីណែនាំក្រុមយើងខ្ញុំ ឱ្យខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើកិច្ចការឱ្យបានល្អក្នុងការឈានទៅរកភាពជោគជ័យនាពេលខាងមុខ។
- ឯកឧកត្តម **ស៊ូ សុជាតិ** ជាអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដែលបានអនុញ្ញាតឲ្យក្រុមយើងខ្ញុំបានចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជា។
- ឯកឧត្តម **សុខ ដារ៉ា** ជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងមន្ត្រីដែលជាបុគ្គលិកជំនាញនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល ទំនាក់ទំនងអន្តរជាតិ និងអភិវឌ្ឍទីផ្សារមូលបត្រ ដែលជាពិសេសលោក **រិន រដ្ឋា** លោក **ម៉ុក វ៉ាឌី** និងលោកស្រី **ហ៊ លីតា** ដែលបានផ្តល់ជាឯកសារ និងយកចិត្តទុកដាក់ធ្វើការណែនាំ បង្ហាត់បង្ហាញ ព្រមទាំងជួយសម្រួលក្នុងការធ្វើការចុះកម្មសិក្សារបស់ក្រុមយើងខ្ញុំ ឱ្យមានការប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួង រំលឹកនឹកដល់វត្ថុសក្តិសិទ្ធិទាំងពួងក្នុងលោក និងគុណព្រះរតនៈត្រ័យទាំងបី សូមជួយប្រោសព្រំ ដល់អ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែសុភមង្គល និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

វិស័យមូលបត្រ គឺជាវិស័យថ្មីមួយសម្រាប់ប្រទេសកម្ពុជា ដែលបម្រើដល់សេវាកម្មហិរញ្ញវត្ថុបន្ថែមទៅលើវិស័យធានាគារដែលមានស្រាប់ ដើម្បីកៀរគរដើមទុនដែលនៅទំនេរ ផ្តល់ជម្រើសវិនិយោគដល់បណ្តាលវិនិយោគិន និងជាកាតាលីករមួយដ៏សំខាន់សម្រាប់ជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ព្រមទាំងពង្រើកមធ្យោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងធ្វើអោយប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្តល់នូវជម្រើសថ្មីមួយទៀត ក្នុងការធ្វើហិរញ្ញប្បទានផ្ទាល់ដល់គម្រោងវិនិយោគនានា ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច។ ទោះបីជាដំណើរការនៃទីផ្សារមូលបត្រកម្ពុជា កំពុងតែធ្វើការចាប់ផ្តើមរីកលូតលាស់ទៅមុខក៏ដោយ ប៉ុន្តែការយល់ដឹងរបស់មនុស្សទូទៅ ឬក្រុមហ៊ុន មួយចំនួនដែលមានការជាប់ទងនឹងវិស័យមូលបត្រនេះហាក់បីដូចជានៅមានកម្រិតនៅឡើយ។ ពួកគេនៅមិនទាន់ជ្រាបច្បាស់នៅឡើយទេ ពីអត្ថន័យ និងអត្ថប្រយោជន៍នៃកាធ្វើការវិនិយោគក្នុងទីផ្សារមូលបត្រ ក៏ដូចជាការចូលរួមបោះផ្សាយមូលបត្រជាដើម។

វិស័យមូលបត្រ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តធ្វើការស្រាវជ្រាវ ហើយរៀបចំនូវរបាយការណ៍កម្មសិក្សាដោយមានប្រធានបទស្តីអំពី "**ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា**" ដែលជារបាយការណ៍កម្មសិក្សាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ វាជាប្រធានបទមួយ ដែលផ្តោតសំខាន់តែទៅលើការត្រៀមខ្លួនរបស់វិនិយោគិន ដែលមានគោលបំណងចង់ធ្វើការវិនិយោគក្នុងផ្សារមូលបត្រកម្ពុជា ដឹងពីដំណើរការនៃការជួញដូរមូលបត្រ និងហានិភ័យដែលវិនិយោគិនគួរតែដឹងនឹងធ្វើការស្វែងយល់បន្ថែម។ ជាងនេះទៅទៀត ប្រធានបទនេះក៏បានធ្វើការរួមបញ្ចូលទិដ្ឋភាពជាក់ស្តែងនៃវិស័យមូលបត្រនៅកម្ពុជា មានបង្ហាញពីតួអង្គចូលរួមសំខាន់ៗ តួអង្គដ៏ទៃទៀតដែលបានចូលរួមបន្ថែម (តួអង្គបន្ទាប់បន្សំ) និងការផ្តល់ជាអនុសាសន៍ដែលជាគំនិតផ្ទាល់របស់ក្រុមខ្ញុំបាទផងដែរ។ ក្រុមយើងខ្ញុំសង្ឃឹមថារបាយការណ៍កម្មសិក្សាមួយនេះ នឹងរួមចំណែកក្នុងការបង្កើននូវចំណេះដឹងដល់សិស្សនិស្សិត និងវិនិយោគិនផ្សេងៗ ដែលមានបំណងចង់ធ្វើការត្រៀមខ្លួនវិនិយោគនៅទីផ្សារមូលបត្រកម្ពុជា។ ក្រុមយើងខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍មួយនេះនឹងរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចមួយចំនួន តាមរយៈការចែករំលែកចំណេះដឹងដល់បងប្អូន ដែលជានិស្សិតជំនាន់ក្រោយៗ ដែលមានការចាប់អារម្មណ៍មកលើការវិនិយោគក្នុងវិស័យមូលបត្រកម្ពុជាជាដើម។

ជាចុងបញ្ចប់ យើងខ្ញុំសុំអភ័យទោសទុកជាមុនចំពោះរាល់កំហុសខុសឆ្គងដែលបានកើតឡើងក្នុងប្រការណាមួយដោយក្តីអនុគ្រោះ ពីព្រោះទោះបីជាកិច្ចការទាំងឡាយត្រូវបានសរសេរ និងចងក្រងដោយយកចិត្តទុកដាក់យ៉ាងណាក្តី ក៏នៅតែមានភាពខ្វះចន្លោះ កំហុសអក្ខរាវិរុទ្ធ បូករួមទាំងកំហុសខុសឆ្គងនានា តែងតែកើតមានដោយអចេតនាជាក់ជាមិនខាន។ ក្រុមយើងខ្ញុំនឹងទទួលស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនានានាពីសំណាក់លោកគ្រូ ដែលជាសាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូប ដើម្បីធ្វើការកែលម្អរបាយការណ៍នេះឱ្យកាន់តែប្រសើរឡើង ដោយសេចក្តីសោមនស្សរីករាយជាទីបំផុត។

# មាតិកា

បញ្ជីឧបសម្ព័ន្ធ ........ v

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី ១
## រំលឹកទ្រឹស្តី

១.១. ការវិនិយោគ (Investment) ........ ៥
១.១.១. ដូចម្តេចដែលហៅថាការវិនិយោគ? ........ ៥
១.១.២. ប្រភេទនៃការវិនិយោគ ........ ៦
១.២. វិនិយោគិន (Investors) ........ ៧
១.២.១. វិនិយោគិនជារូបវន្តបុគ្គល (Individual Investors) ........ ៧
១.២.២. វិនិយោគិនជានីតិបុគ្គល (Institutional Investors) ........ ៧
១.៣. មូលបត្រ (Securities) ........ ៨
១.៣.១. មូលបត្ររដ្ឋ (Government Securities) ........ ៨
១.៣.២. មូលបត្រមហាជន (Non-Government Securities) ........ ៨
១.៤. ទីផ្សារមូលបត្រ ........ ១០
១.៤.១. អ្វីទៅជាទីផ្សារមូលបត្រ? ........ ១០
១.៤.២. ប្រភេទីផ្សារមូលបត្រ ........ ១០
១.៥. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ........ ១១

## ជំពូកទី ២
## ទីផ្សារមូលបត្រនៅកម្ពុជា

២.១. ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជា ........ ១២

២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ..................................................................... ១៣
២.២.១. សាវតា ..................................................................... ១៣
២.២.២. រចនាសម្ព័ន្ធគ្រប់គ្រង ..................................................................... ១៤
២.២.៣. ក្រុមប្រឹក្សាភិបាល ..................................................................... ១៤
២.២.៤. គណៈគ្រប់គ្រង ..................................................................... ១៥
២.២.៥. ចក្ខុវិស័យ និងបេសសកម្ម ..................................................................... ១៦
២.២.៥.១. ចក្ខុវិស័យ ..................................................................... ១៦
២.២.៥.២. បេសសកម្ម ..................................................................... ១៦
២.៣. តួអង្គពាក់ព័ន្ធក្នុងទីផ្សារមូលបត្រកម្ពុជា ..................................................................... ១៦
២.៣.១. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ ..................................................................... ១៦
២.៣.១.១. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ..................................................................... ១៦
២.៣.១.២. ក្រុមហ៊ុនមូលបត្រ ..................................................................... ១៩
២.៣.១.៣. វិនិយោគិន ..................................................................... ២២
២.៣.២. តួអង្គចូលរួមដទៃទៀត ..................................................................... ២២

## ជំពូកទី ៣

## គណៈកម្មការមូលបត្រកម្ពុជា

៣.១. ទិដ្ឋភាពទូទៅនៃគណៈកម្មការមូលបត្រកម្ពុជា ..................................................................... ២៥
៣.១.១. សាវតា ..................................................................... ២៦
៣.១.២. សមាសភាពរបស់ គ.ម.ក ..................................................................... ២៦
៣.១.២.១. អង្គការចាត់តាំង ..................................................................... ២៨
៣.១.២.២. សមាសភាពរបស់ថ្នាក់ដឹកនាំបច្ចេកទេស ..................................................................... ២៨
៣.១.៣. ចក្ខុវិស័យ និងបេសសកម្ម ..................................................................... ៣៤
៣.១.៣.១. ចក្ខុវិស័យ ..................................................................... ៣៤
៣.១.៣.២. បេសសកម្ម ..................................................................... ៣៣
៣.១.៤. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា ..................................................................... ៣៥
៣.១.៤.១. រូបសញ្ញា ..................................................................... ៣៥
៣.១.៤.២. អត្ថន័យនៃរូបសញ្ញា ..................................................................... ៣៥
៣.១.៤.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា ..................................................................... ៣៦

៣.១.៥. គ្រោះរបស់គណៈកម្មការមូលបត្រកម្ពុជា.........................................................៣៦
៣.១.៦. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា ...................................................៣៧

## ជំពូកទី ៤

## ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន

៤.១. ការត្រៀមខ្លួនជាមូលដ្ឋានរបស់វិនិយោគិន.....................................................៣៨
៤.២. ដំណើរការប្រតិបត្តិការជួញដូរមូលបត្រ.........................................................៤០
៤.២.១. ការជ្រើសរើសក្រុមហ៊ុនចុះបញ្ជី ......................................................................៤០
៤.២.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ .........................................................៤០
៤.២.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (Investor ID).............................៤០
៤.២.១.៣. ការបើកគណនីជួញដូរ (Open a Trade Account) ....................................៤២
៤.២.១.៤. ការបើកគណនីសាច់ប្រាក់ (Open a Cash Account)...................................៤២
៤.២.១.៥. ដាក់បញ្ជា.............................................................................................៤៣
៤.២.២. វិធានប្រតិបត្តិការជួញដូរនៅលើទីផ្សារ .............................................................៤៥
៤.២.៣. ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន និងបច្ចេកទេស .....................................៥០
៤.២.៣.១. ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន..................................................៥១
ក. កត្តាសេដ្ឋកិច្ច ........................................................................................៥១
ខ.កត្តាអាជីវកម្ម .........................................................................................៥៣
គ. កត្តារបាយការណ៍ហិរញ្ញវត្ថុ ....................................................................៥៤
៤.២.៣.២. ការវិភាគដោយផ្អែកលើកត្តាបច្ចេកទេស.............................................៥៦
ក. ទិន្នន័យទីផ្សារ .........................................................................................៥៦
ខ. និន្នាការថ្លៃ .............................................................................................៥៦
គ. តម្រូវការ និងការផ្គត់ផ្គង់.........................................................................៥៨
៤.៣. អត្ថប្រយោជន៍នៃការវិនិយោគលើមូលបត្រ...........................................................៥៩
៤.៣.១. ចំពោះវិនិយោគិន .........................................................................................៥៩
៤.៣.២. ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ.........................................................៦០
៤.៣.៣. ចំពោះសេដ្ឋកិច្ច...........................................................................................៦០
៤.៤.យល់ដឹងអំពីហានិភ័យលើការវិនិយោគលើមូលបត្រ ......................................................៦១

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........................................................................................................ ៦៣
២. អនុសាសន៍ ........................................................................................................ ៦៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១ ៖** គណៈកម្មការមូលបត្រកម្ពុជា "ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន"។
- **ឧបសម្ព័ន្ធទី២៖** គណៈកម្មការមូលបត្រកម្ពុជា "ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគសម្រាប់រូបវន្តបុគ្គល" (ទម្រង់ ក)។
- **ឧបសម្ព័ន្ធទី៣៖** គណៈកម្មការមូលបត្រកម្ពុជា "ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគសម្រាប់នីតិបុគ្គល" (ទម្រង់ ខ)។
- **ឧបសម្ព័ន្ធទី៤៖** គណៈកម្មការមូលបត្រកម្ពុជា "គោលការណ៍ណែនាំស្តីពីការធ្វើប៉ុកប៉ៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ" (ទម្រង់០១ ទម្រង់០២ និងទម្រង់០៣)
- **ឧបសម្ព័ន្ធទី៥៖** គណៈកម្មការមូលបត្រកម្ពុជា "យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លើកដំបូង"។
- **ឧបសម្ព័ន្ធទី៦៖** រាជរដ្ឋាភិបាលកម្ពុជា "ការកែសម្រួលសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា"។
- **ឧបសម្ព័ន្ធទី៧៖** រាជរដ្ឋាភិបាលកម្ពុជា "ការលើកទឹកចិត្តពន្ធដារលើវិស័យមូលបត្រ"។
- **ឧបសម្ព័ន្ធទី៨៖** កំពង់ផែស្វយ័តក្រុងព្រះសីហនុ "របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ, របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ, របាយការណ៍បម្រែបម្រួលមូលធន, និងរបាយការណ៍លំហូរសាច់ប្រាក់"។

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងយុគសម័យសកលភាវូបនីយកម្មនេះ ជាសម័យសេដ្ឋកិច្ចទីផ្សារសេរី ដែលបណ្តាលប្រទេសនានាលើសកលលោក ខិតខំប្រឹងប្រែងប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ដើម្បីអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនឱ្យកាន់តែរីកចម្រើន។ សេដ្ឋកិច្ចរបស់ប្រទេសជាតិមួយមានការរីកចម្រើនលូតលាស់ខ្លាំងទៅបាន លុះត្រាតែប្រទេសជាតិនោះមានហិរញ្ញវត្ថុមានស្ថេរភាព និងដំណើរការល្អ។ ប្រព័ន្ធហិរញ្ញវត្ថុប្រៀបបានទៅនឹងស្លាបពីរ ដែលជម្រុញឱ្យសេដ្ឋកិច្ចមានការរីចម្រើនលូតលាស់ទៅមុខ។ ប្រសិនបើគ្មានប្រព័ន្ធហិញ្ញវត្ថុនោះទេ នោះការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រាកដជាជួបប្រទះនឹងការលំបាកច្រើន ដោយសារតែមិនអាចធ្វើឱ្យមានលំហូរសាច់ប្រាក់ ដែលនៅសល់ចូលរួមក្នុងការវិនិយោគ។ ជាទូទៅប្រព័ន្ធហិរញ្ញវត្ថុត្រូវបានគេបែងចែកជាពីរផ្នែកដែលរួមមាន ស្ថាប័នហិរញ្ញវត្ថុ (មានស្ថាប័នជានាគា និងមិនមែនជានាគារ) និងទីផ្សារហិរញ្ញវត្ថុ។ ចំណែកឯប្រទេសកម្ពុជាវិញ ដោយសារតែមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលទៅលើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច ទើបធ្វើឱ្យប្រទេសកម្ពុជាមានការរីកចម្រើនឆ្ពោះទៅមុខជាបន្តបន្ទាប់។ យ៉ាងណាមិញ រាជរដ្ឋាភិបាលបានបង្កើតទីផ្សារថ្មីមួយទៀតគឺ "ទីផ្សារមូលបត្រកម្ពុជា" ។ ការបង្កើតនូវទីផ្សារមូលបត្រកម្ពុជានេះឡើង គឺបានផ្តល់នូវជម្រើសថ្មីមួយដល់វិនិយោគិនទូទៅក្នុងការធ្វើហិរញ្ញប្បទាន ដើម្បីឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ប្រើប្រាស់មូលធនដែលមានទៅពង្រីកអាជីវកម្មឱ្យកាន់តែរីកចម្រើនមួយកម្រិតទៀត។

ទីផ្សារមូលបត្រកម្ពុជា ជាវិស័យមូលបត្រមួយបានចាប់កំណើតឡើងនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ដែលធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវ និងសាធារណៈជនមានការចាប់អារម្មណ៍ជាច្រើនលើវិស័យមួយនេះ។ ដោយឃើញហើយថា នៅក្នុងប្រទេសកម្ពុជាប្រជាជនភាគច្រើនមិនសូវយល់ដឹង និងមិនទាន់ដឹងច្បាស់លាស់អំពីវិស័យមូលបត្រនេះនៅឡើយទេ ដោយពួកគាត់ភាគច្រើនមានការយល់ដឹងតិចតួចពីវិស័យមួយនេះ តាមរយៈកាសែត ទស្សនាវដ្តី និងពីប្រភពពត៌មានដ៏ទៃទៀតដែលបានផ្សព្វផ្សាយ។ ពិតណាស់ទីផ្សារមូលបត្រកម្ពុជា ជាកន្លែងមួយសម្រាប់ប្រមូល និងកៀរគរមូលធនពីបុគ្គលដែលមានមូលធនលើស ទៅកាន់បុគ្គលដែលមានមូលធនខ្វះ ឬត្រូវការមូលធនបន្ថែមសម្រាប់ពង្រីក និងពង្រឹងការវិនិយោគឱ្យកាន់តែរឹងមាំថែមមួយកម្រិតទៀត។ ការលេចឡើងនៃទីផ្សារមូលបត្រកម្ពុជានៅក្នុងប្រទេសកម្ពុជាអាចផ្តល់ឱកាសវិនិយោគដល់វិនិយោគិន និងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈផ្សេងៗទៀត។ ដូចនេះហើយ ដើម្បីដោះស្រាយចម្ងល់ដែលមាន

ទាក់ទងទៅនឹងទីផ្សារមូលបត្រកម្ពុជា របាយការកម្មសិក្សារមួយនេះ បានលើកយកនូវប្រធានបទ "**ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា**" មកសិក្សា និងបកស្រាយ ដើម្បីឱ្យសាធារណៈជនបានយល់ដឹងកាន់តែច្បាស់អំពីផ្សារមូលបត្រកម្ពុជា និងសារៈប្រយោជន៍នៃទីផ្សារសម្រាប់ការត្រៀមខ្លួនវិនិយោគ រួមទាំងដំណើរការរបស់ទីផ្សារមូលបត្រកម្ពុជា។

ដើម្បីជាទិសដៅមួយក្នុងការអភិវឌ្ឍន៍វិស័យមូលបត្រកម្ពុជា ក៏ដូចជាជម្រុញឱ្យមានកំណើនលើវិស័យសេដ្ឋកិច្ចប្រកបដោយលក្ខណៈល្អប្រសើរ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំរកគ្រប់មធ្យោបាយ ដើម្បីទាក់ទាញការវិនិយោគលើវិស័យមូលបត្រកម្ពុជាអោយមានសន្ទុះកាន់តែខ្លាំង។ វាអាចមានដំណើរការទៅបាន អាស្រ័យដោយមានការយល់ដឹង និងមានការចូលរួមពីសំណាក់សាធារណៈជន និងវិនិយោគិនផងដែរ។ មុននឹងធ្វើការសម្រេចចិត្តក្នុងការដាក់មូលធនរបស់ខ្លួនក្នុងការវិនិយោគមូលបត្រ វិនិយោគិនភាគច្រើនតែងតែចោទសួរនូវសំណួរថា តើវិនិយោគិននឹងបានទទួលអត្ថប្រយោជន៍អ្វីខ្លះ ហើយផ្តល់ភាពជឿទុកចិត្តកម្រិតណាពីសំណាក់ទីផ្សារមូលបត្រកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វត្ថុបំណងនៃការបង្កើតទីផ្សារមូលបត្រកម្ពុជានេះឡើង គឺដើម្បីអភិវឌ្ឍប្រទេសជាតិ ជាពិសេសវិស័យសេដ្ឋកិច្ចនេះតែម្តងឱ្យកាន់តែរីកចម្រើនថែមមួយកម្រិតទៀត។ ហេតុដូចនេះ របាយការណ៍កម្មសិក្សានេះ បានកំណត់យកនូវបញ្ហាចម្បងមួយគឺ "ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន ដែលទទួលបានពីទីផ្សារមូលបត្រកម្ពុជា" ។ ដោយផ្អែកលើប្រធានបទខាងលើនេះ មានមនុស្សមួយចំនួនបានឆ្ងល់ថា តើវិនិយោគិនត្រូវត្រៀមលក្ខណៈអ្វីខ្លះក្នុងការវិនិយោគមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

របាយការណ៍នេះត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងកត្តាមួយចំនួនខាងលើការសិក្សាស្រាវជ្រាវមានគោលបំណងដូចខាងក្រោម៖

- សិក្សាពីលក្ខណៈទូទៅរបស់ទីផ្សារមូលបត្រកម្ពុជា និងដំណើរការរបស់វា។
- បង្ហាញអំពីតួអង្គសំខាន់ៗមួយចំនួន ដែលបានចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា។
- សិក្សាស្វែងយល់អំពីការត្រៀមខ្លួនរបស់វិនិយោគិន ក្នុងការវិនិយោគមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា។
- សិក្សាអំពីដំណើរការទិញ និងលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា។
- សិក្សាអំពីវិធានប្រតិបត្តិការទីផ្សារមូលបត្រ។

- យល់ដឹងពីផលចំណេញ និងអត្ថប្រយោជន៍នៃការវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា។
- យល់ដឹងអំពីហានិភ័យលើការវិនិយោគលើមូលបត្រ។

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅគណៈកម្មការមូលបត្រកម្ពុជា ដែលសិក្សាអំពីដំណើរការនៃទីផ្សារមូលបត្រកម្ពុជានៅក្នុងព្រះរាជាណាចក្រកម្ពុជានៅក្នុងចន្លោះឆ្នាំ ២០១១ ដល់ ២០១៧ ដោយផ្តោតសំខាន់ទៅលើ "ការត្រៀមខ្លួនវិនយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា" ។

**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ**

ដើម្បីចង់ក្រងចេញជារបាយករណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះបាន គឺប្រមូលបានពីប្រភពទិនន្ន័យ ២ ប្រភេទ រួមមានទិន្ន័យចម្បង (Primary Data) និងទិន្ន័យបន្ទាប់បន្សំ (Secondary Data) ៖

**ទិន្នន័យចម្បង៖** ប្រភពទិន្នន័យតាមរយៈគណៈកម្មការមូលបត្រកម្ពុជា ដែលមានដូចជាច្បាប់ ប្រកាស អនុក្រឹត្យ បទបញ្ញាត្តិ និងឯកសារផ្សេងៗទៀត និងសាកសួរដោយផ្ទាល់ជាមួយមន្ត្រីដែលកំពុងបម្រើការនៅទីនោះ ដែលគាត់ជាអ្នកទទួលបន្ទុកក្នុងប្រតិបត្តិការទីផ្សារ និងការទាក់ទាញវិនិយោគិន រួមទាំងទិន្នន័យដែលទទួលបានពីការធ្វើបទបង្ហាញ និងសិក្ខាសាលាដែលបានរៀបចំដោយគណៈកម្មការមូលបត្រកម្ពុជា ក៏ដូចជាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាផងដែរ។

**និន្នន័យបន្ទាប់បន្សំ៖** ចំណែកឯការប្រមូលទិន្នន័យបន្ទាប់បន្សំវិញ គឺបានមកពីការស្រាវជ្រាវឯកសារដែលទាក់ទងទៅនឹងវិស័យមូលបត្រដូចជា ការសុំយោបល់ និងការណែនាំពីសំណាក់លោកគ្រូដែលជាសាស្ត្រាចារ្យ ស្វែងរកតាមរយៈគេហទំព័រផ្សេងៗដែលមានការពាក់ព័ន្ធនឹងប្រធានបទ និងការស្រាវជ្រាវពីបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

**៦. សារៈសំខាន់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនឹងផ្តល់នូវអត្ថប្រយោជន៍ដល់មជ្ឈដ្ឋានជាច្រើនដូចជា៖

**គណៈកម្មកាមូលបត្រកម្ពុជា៖** លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងអាចក្លាយជាឯកសារមួយដ៏មានតម្លៃ និងមានសារៈប្រយោជន៍ចំពោះគណៈកម្មការមូលបត្រកម្ពុជាដូចជា៖

- ទទួលបាននូវយុទ្ធសាស្ត្រថ្មីៗនិយ័តករមូលបត្របរទេស ក្នុងការទាក់ទាក់ទាញវិនិយោគិន។
- អាចមើលឃើញពីចំណុចខ្វះខាត ឬចំណុចខ្សោយក្នុងការអនុវត្តវិធានការផ្សេងៗ ដើម្បីពង្រឹងទំនុកចិត្តវិនិយោគិនក្នុងទីផ្សារមូលបត្រ។

- មានការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ក្នុងការទាក់ទាញវិនិយោគិនឱ្យកាន់តែប្រសើរឡើង ស្របតាមស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា។

**មជ្ឈដ្ឋានទូទៅ៖** របាយការណ៍នេះនឹងក្លាយជាឯកសារដល់មិត្តអ្នកអានពីគ្រប់តំបន់ទាំងអស់ដែលមានបំណងចង់ដឹងពីវិស័យមូលបត្រ និងការត្រៀមខ្លួនរបស់វិនិយោគិនផ្សេងៗទៀត អាចប្រើឯកសារនេះសម្រាប់ធ្វើការប្រឡូកចូលក្នុងវិស័យមូលបត្រប្រកបដោយភាពជឿជាក់ និងមានទំនុកចិត្ត ហើយមានភាពជោគជោគជ័យនាពេលខាងមុខ។

**និស្សិតជាអ្នកស្រាវស្រាវ៖**

- អាចរំលឹកពីទ្រឹស្តីដែលទាក់ទងនឹងការសិក្សាកន្លងមកឡើងវិញ។
- ស្គាល់នូវពាក្យបច្ចេកទេសមួយចំនួនដែលមានការពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- ស្គាល់នូវបទប្បញ្ញត្តិរបស់មូលបត្រមួយចំនួន ដែលមានការពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ។
- បានទទួលនូវបទពិសោធន៍ជាច្រើនក្នុងការងារជាក់ស្តែងតែម្តង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះប្រធានបទនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៤ ជំពូកសំខាន់ៗគឺ ៖

សេចក្តីផ្តើម

ជំពូកទី ១៖ រំលឹកទ្រឹស្តី

ជំពូកទី ២៖ ទីផ្សារមូលបត្រនៅកម្ពុជា

ជំពូកទី ៣៖ គណៈកម្មការមូលបត្រកម្ពុជា

ជំពូកទី ៤៖ ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១. ការវិនិយោគ ( Investment )

ទ្រឹស្តីវិនិយោគបានចែងថា "គ្មានការទទួលផលចំណេញឯណាដែលបានមកដោយពុំមានការដាក់ទុនជាដំបូងនោះទេ"។ ទោះបីជាមានទ្រឹស្តី Arbitrage ចែងថាគេអាចទទួលបានផលចំណេញដោយពុំចាំបាច់ដាក់ទុនក៏ដោយ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះអ្នកធ្វើប្រតិបត្តិការបែបនេះមានការលំបាកនឹងឆ្លៀតយកចំណេញណាស់ ដោយសារបញ្ហាបច្ចេកវិទ្យាដ៏ទំនើប និងមានពត៌មានឥតខ្ចោះដែលគេទទួលបានពីទីផ្សារ។ ដូចនេះមានតែការធ្វើវិនិយោគទេដែលអាចធ្វើអោយគេទទួលបានជាផលចំណេញ។

### ១.១.១. ដូចម្តេចដែលហៅថាការវិនិយោគ?

ការវិនិយោគ (Investment) គឺជាការប្រើប្រាស់ ឬចំណាយធនធានពេលបច្ចុប្បន្ន ដោយរំពឹងនឹងទទួលបានការកើនឡើងនៃចំណូល ឬធនធាននោះនាពេលអនាគត។ នៅពេលគេត្រូវការលក់ភាគហ៊ុនទាំងនោះចេញទៅវិញ។ ហើយគេអាចបកស្រាយម្យ៉ាងទៀតបានថា ការវិនិយោគ គឺជាការចំណាយសាច់ប្រាក់ ឬប្រភពផ្សេងៗទៀតក្នុងពេលបច្ចុប្បន្ន ហើយសង្ឃឹមថានឹងទទួលបានប្រាក់ចំណេញនាពេលអនាគត។ បុគ្គល ឬក្រុមហ៊ុនដែលសម្រេចចិត្តដាក់ទុនវិនិយោគដោយទិញភាគហ៊ុន (Stock) ពីក្រុមហ៊ុនណាមួយមានការរំពឹងទុកដូចៗគ្នា គឺចង់បានចំណូលច្រើន (ភាគលាភ Dividend) និងការកើនឡើង ឬចំណេញជាមូលធន (Capital Gain) លើភាគហ៊ុនដែលបានវិនិយោគនោះ នៅពេលគេត្រូវការលក់ភាគហ៊ុនទាំងនោះចេញទៅវិញ។

ការវិនិយោគ គឺជាការប្រើប្រាស់សាច់ប្រាក់ដើម្បីបង្កើនសាច់ប្រាក់ (The use of money for making more money) ។ មានមធ្យោបាយជាច្រើនសម្រាប់ភ្នាក់ងារសេដ្ឋកិច្ចដាក់ទុនវិនិយោគរបស់ខ្លួននាពេលបច្ចុប្បន្ននេះ។ គេអាចយកប្រភពទុនរបស់ខ្លួនដែលមានទៅដាក់នៅធនាគារ ដើម្បីយកអត្រាការប្រាក់ អាចទិញប័ណ្ណរតនាគាររយៈពេលខ្លី (T-bills: Treasury bills) ប័ណ្ណរតនាគាររយៈពេលមធ្យម (T-notes: Treasury Notes) និងរយៈពេលវែង (T-bond: Treasury Bonds) ឬអាចទិញភាគហ៊ុនពីក្រុមហ៊ុនដ៏ទៃទៀត ឬអាចចូលរួមគ្នាបង្កើតបានជា Mutual Funds ដើម្បីវិនិយោគលើអ្វីមួយ ឬវិនិយោគលើទ្រព្យសម្បត្តិពិត (Real investment) តាមលទ្ធភាពដែលអាចធ្វើបាន។

### ១.១.២. ប្រភេទនៃការវិនិយោគ

ចំពោះបរិភាគមួយចំនួនដែលត្រូវយកមកធ្វើការវិនិយោគ គឺបានមកពីប្រាក់កំចី សញ្ញាប័ណ្ណ ការសន្សំ ការបោះផ្សាយលក់ភាគហ៊ុន និងប្រភពផ្សេងៗទៀត។ល។ ជាមួយនិងប្រភពទុនដែលខ្លួនមាន អ្នកវិនិយោគអាចប្រើប្រាស់តាមមធ្យោបាយច្រើនយ៉ាង ដើម្បីទទួលបានផលលាភត្រលប់ពីការវិនិយោគវិញ (Return on investment) តាមការរំពឹងទុកជាមួយនឹងមូលនិធិដែលបានដាក់ទុន។ គេបានដាក់បែងចែកប្រភេទនៃការវិនិយោគជាពីរ គឺការវិនិយោគពិត (Real investment) និងវិនិយោគបែបហិរញ្ញវត្ថុ (Financial Investment) ។ គំនូសបំព្រួញខាងក្រោមនេះបានបង្ហាញអំពីលទ្ធភាពផ្សេងៗដែលអ្នកវិនិយោគអាចជ្រើសរើសដើម្បីដាក់ទុនលើគម្រោងរបស់ខ្លួន៖




❖ **ការវិនិយោគពិត** ( Real Investment )

**ការវិនិយោគពិត (Real Investment)** គឺជាការយកប្រភពធនធានដែលខ្លួនមានក្រៅពីយកប្រភពធនធានទាំងនោះទៅដាក់ទុនលើទីផ្សារហិរញ្ញវត្ថុដោយបានទិញភាគហ៊ុន សញ្ញាប័ណ្ណ ឬផលិតផលហិរញ្ញវត្ថុដ៏ទៃទៀត បុគ្គលទាំងអស់នោះអាចជ្រើសរើសការវិនិយោគរបស់ខ្លួនដាក់ទុនលើទ្រព្យសម្បត្តិពិតដូចជា សង់សណ្ឋាគារ ការសាងសងផ្ទះល្វែង ឬផ្ទះសំណាក់សម្រាប់ជួល ទិញដីជាច្រើនដើម្បីសាងសង់រោងចក្រដើម្បីធ្វើផលិតកម្ម ដើម្បីបង្កើនប្រាក់ចំណេញឱ្យមានការកើនឡើង។ ការវិនិយោគរបស់បុគ្គល (Individual) ខាងលើនេះត្រូវបានចាត់ទុកថាជាប្រភេទ វិនិយោគពិត។

❖ **ការវិនិយោគហិរញ្ញវត្ថុ** ( Financial Investment )

**ការវិនិយោគហិរញ្ញវត្ថុ (Financial Investment)** គឺជាការដាក់ទុនវិនិយោគដែលដាក់ទុនទៅលើឧបករណ៍ហិរញ្ញវត្ថុ ដូចជា ភាគហ៊ុន សញ្ញាប័ណ្ណក្រុមហ៊ុន សញ្ញប័ណ្ណ រដ្ឋាភិបាលជាដើម។ ប្រសិនបើជាយើងមិនអាចមានចំណែកជាម្ចាស់ក្រុមហ៊ុនទាំងមូលបាន យើងក៏អាចមានចំណែកជាម្ចាស់លើក្រុមហ៊ុនបានមួយភាគដែរ។ មានន័យថា បើគ្មានលទ្ធភាពបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួនឯង

នោះទេ ក៏អាចចូលរួមទិញភាគហ៊ុនក្នុងក្រុមហ៊ុនអាជីវកម្មមួយទៀតបាន ហើយក៏អាចនឹងអាចទទួលបានចំណែកជាម្ចាស់តាមសមាមាត្រទុនដែលបានធ្វើ ឬដាក់ទុនវិនិយោគនោះដែរ។ បន្ថែមលើនេះទៀត យើងអាចទិញសញ្ញបណ្ណពីក្រុមហ៊ុនណាមួយ ឬទិញមូលបត្រក្លាយ (Derivative securities) លើទីផ្សារហិរញ្ញវត្ថុដែលការធ្វើការវិនិយោគបែបនេះគេអោយឈ្មោះថា ការធ្វើវិនិយោគបែបហិរញ្ញវត្ថុ។

## ១.២. វិនិយោគិន ( Investors )

វិនិយោគិនមូលបត្រ គឺត្រូវបានគេឱ្យនិយមន័យថា ជាបុគ្គលទាំងឡាយណាដែលវិនិយោគលើមូលបត្រ ដោយរំពឹងទុកថានឹងទទួលបានផលចំណេញមកវិញយ៉ាងសមគួរ។ ការចាប់អារម្មណ៍ដែលជាកត្តាចម្បងបង្អស់របស់វិនិយោគិននោះ គឺធ្វើយ៉ាងណាដើម្បីទទួលបានផលចំណេញឱ្យខ្ពស់បំផុត ហើយប្រឈមមុខនឹងហានិភ័យតិចតួចបំផុត ដោយផ្ទុយគ្នាទៅនឹងវិនិយោគិនមួយប្រភេទផ្សេងទៀត ដែលហ៊ានប្រឈមមុខនឹងហានិភ័យដោយសង្ឃឹមថានឹងទទួលបានប្រាក់ចំណេញច្រើនផងដែរ។ ជាទូទៅវិនិយោគិននៅក្នុងទីផ្សារមូលបត្រកម្ពុជា ត្រូវបានចែកជាពីរប្រភេទ គឺ វិនិយោគិនជារូបវន្តបុគ្គល ឬឯកត្តជន (Individual Investors) និងវិនិយោគិនជានីតិបុគ្គល (Institutional Investors)។

### ១.២.១. វិនិយោគិនជារូបវន្តបុគ្គល ( Individual Investors )

វិនិយោគិនជារូបវន្តបុគ្គល គឺសំដៅទៅលើរូបវន្តបុគ្គលដែលជាធម្មតាធ្វើអាជីវកម្មទិញ-លក់មូលបត្រក្នុងបរិមាណមួយតិចតួចក្នុងទីផ្សារបន្ទាប់ (Secondary market)។ វិនិយោគិនប្រភេទនេះគេអាចហៅម្យ៉ាងទៀតបានថាជា វិនិយោគិនរាយ (Retail investor) ឬវិនិយោគតូចតាច ពីព្រោះដោយសារតែវិនិយោគិនទាំងនេះទិញ និងលក់មូលបត្រតាមរយៈទីផ្សារលក់រាយ (Retail market) ហើយក្នុងកម្រិតតម្លៃលក់រាយពីឈ្មួញជើងសារមូលបត្រ (Brokers)។

### ១.២.២. វិនិយោគិនជានីតិបុគ្គល ( Institutional Investors )

វិនិយោគិនជានីតិបុគ្គល អាចជាអង្គភាព (Entity) ស្ថាប័ន ឬក្រុមហ៊ុនទាំងឡាយណាដែលធ្វើការវិនិយោគលើមូលបត្រក្នុងទំហំធំ និងជាសាច់ប្រាក់ធំៗ។ វិនិយោគិនជានិតិបុគ្គលទទួលបាននូវការការពារ ព្រោះវិនិយោគិនទាំងនោះត្រូវបានគេយល់ថា មានការយល់ដឹងច្រើនលើកាវិនិយោគក្នុងវិស័យមូលបត្រ ហើយពួកគាត់មានសម្ថភាពគ្រប់គ្រាន់ក្នុងការការពារខ្លួនឯងទៀតផង។ វិនិយោគិននៅក្នុងប្រទេសកម្ពុជា ដែលរំពឹងទុកថានឹងចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា មានដូចជាសាធារណៈជនទូទៅ ឬរូបវន្តបុគ្គលដែលមានធនធានលើស ហើយនៅទំនេរច្រើន។ មានធនាគារ

មួយចំនួនដែលអាចធ្វើការវិនិយោគប្រាក់តម្កល់នៃអតិថិជនរបស់ខ្លួន ដើម្បីបង្កើនប្រាក់ចំណូលឱ្យមានការកើនឡើងថែមមួយកម្រិតទៀត មានក្រុមហ៊ុនធានារ៉ាប់រង ព្រមទាំងមានភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត មានទ្រព្យសកម្មជាមូលនិធិសោធននិវត្តន៍ (Pension Fund) ដែលវិនិយោគិនប្រភេទនេះធ្វើការ វិនិយោគជាលក្ខណៈទ្រង់ទ្រាយធំ[1]។

**១.៣. មូលបត្រ** ( Securities )

យោងទៅតាមច្បាប់ និងបទបញ្ញត្តិមូលបត្រនៅក្នុងប្រទេសកម្ពុជាចែកចេញជា ពីរ ប្រភេទធំៗ គឺមូលបត្ររដ្ឋ និងមូលបត្រមហាជន[2]។

**១.៣.១. មូលបត្ររដ្ឋ** ( Government Securities )

មូលបត្ររដ្ឋ គឺសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមជារាជរដ្ឋាភិបាលកម្ពុជា[3]។

មូលបត្ររដ្ឋរួមមាន:

ក). ប័ណ្ណរតនាគារ (Treasury Bills) ដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។

ខ). សញ្ញាប័ណ្ណរតនាគារ (Treasury Bonds) ដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។

គ). សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។

ឃ). មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ។

**១.៣.២. មូលបត្រមហាជន** ( Non-government Securities )

មូលបត្រមហាជន គឺសំដៅដល់មូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនមហាជនដែលមានការទទួលខុសត្រូវមានកម្រិត (PLC) ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ[4]។

មូលបត្រមហាជនរួមមានដូចជា៖

១). មូលបត្រកម្មសិទ្ធ (Equities Securities) រាប់បញ្ចូលទាំងភាគហ៊ុន (Stock)។

---

[1] ស៊ូ សុជាតិ, អ៊ុង នីតា (២០១៥) របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន" ទំព័រ ១១។

[2] គណៈកម្មការមូលបត្រកម្ពុជា, ច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន"

[3] គណៈកម្មការមូលបត្រកម្ពុជា, ច្បាប់ស្តីពី "មូលបត្ររដ្ឋ"

[4] គណៈកម្មការមូលបត្រកម្ពុជា, ច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន"

២). មូលបត្របំណុល (Debt Securities) ដោយរាប់បញ្ចូលទាំងសញ្ញាប័ណ្ណ (Bond)។

៣). គម្រោងវិនិយោគរួម (Collective Investment Scheme) ។

៤). ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ (Derivative Instrument)។

❖ **មូលបត្រកម្មសិទ្ធិ** ( Equities Securities )

មូលបត្រ (Securities) សម្តៅទៅលើ ភាគហ៊ុន (Stock) ប័ណ្ណបំណុល (Bond) និងឧបករណ៍និស្សន្ទ (Derivatives)។ ភាគហ៊ុន (Stock) ជាប្រភេទមូលបត្រដែលបង្ហាញពីភាពជាម្ចាស់នៅក្នុងក្រុមហ៊ុន និងតំណាងឱ្យការទាមទារលើទ្រព្យសម្បត្តិ និងប្រាក់ចំណូលរបស់ក្រុមហ៊ុន។ ជាធម្មតាភាគហ៊ុន បែងចែកជាពីរប្រភេទក្នុងនោះរួមមាន ភាគហ៊ុនធម្មតា (Common Stock) និងភាគហ៊ុនអាទិភាព (Preferred Stock)។

**ភាគហ៊ុនធម្មតា (Common Stock)**

ភាគហ៊ុន គឺជាមូលបត្រដែលតំណាងឱ្យចំណែកនៃទុនរបស់ភ្នាក់ងារសេដ្ឋកិច្ច ដែលបានដាក់ទុនវិនិយោគ ហើយនឹងចំណែកនៃកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនសាជីវកម្មនោះ។ ភាគហ៊ុនធម្មតា គឺជាទុនផ្ទាល់របស់ក្រុមហ៊ុនមួយ។ រាល់ភាគហ៊ុននីមួយៗគឺតំណាងឱ្យចំណែកនៃមូលធន ដែលអ្នកវិនិយោគមាន ឬបានដាក់ទុនវិនិយោគលើក្រុមហ៊ុននោះ។ ម្ចាស់កាន់កាប់ភាគហ៊ុនទាំងអស់មានសិទ្ធិចូលរួមទទួលចំណូលរបស់អាជីវកម្មតាមរយៈការបែងចែកភាគលាភ (Dividends) ឬមូលធនចំណេញនៅក្នុងតម្លៃដែលបានកាន់កាប់ភាគហ៊ុននោះ (Increase in Value or Capital Gain or Loss) ។ ភាគលាភ (Dividends) គឺជាចំណែកនៃប្រាក់ចំណេញទទួលបានដោយក្រុមហ៊ុន ហើយត្រូវបែងចែកទៅម្ចាស់ភាគហ៊ុនម្នាក់ៗសមាមាត្រនឹងទឹកប្រាក់ ដែលបានធ្វើការវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុននោះ។ ចំណែកឯ ប្រាក់ចំណេញ (Capital Gain or Loss) គឺទទួលបានមកពីការលក់ភាគហ៊ុនដែលបានវិនិយោគនោះ។

**ភាគហ៊ុនអាទិភាព (Preferred Stock)**

ភាគហ៊ុនអាទិភាព មានលក្ខណៈដូចគ្នានឹងភាគហ៊ុនធម្មតាដែរ តែអ្នកកាន់ភាគហ៊ុនអាទិភាពពេលបែងចែកភាគលាភ គឺទទួលបានមុនគេ ហើយត្រូវបានកំណត់ជាដំបូងគឺ Fixed លើទឹកប្រាក់កំណត់មួយ។ បន្ថែមលើនេះអ្នកកាន់ភាគហ៊ុនអាទិភាពពុំមានសិទ្ធិបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។ ធ្វើការវិនិយោគដោយទិញភាគហ៊ុនអាទិភាព គឺទទួលបានភាគលាភថេរ (Fixed Dividend) និងអាចទទួលបានប្រាក់ចំណេញ (Capital Gain) ក្នុងករណីតម្លៃទីផ្សាររបស់ភាគហ៊ុននោះឡើងថ្លៃនៅពេលគេចង់លក់។

## ១.៤. ទីផ្សារមូលបត្រ

### ១.៤.១. អ្វីទៅជាទីផ្សារមូលបត្រ?

វត្តមានទីផ្សារមូលបត្របានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុ និងជម្រុញវិស័យសេដ្ឋកិច្ចប្រទេសមួយឱ្យមានការរីកចម្រើន។ ទីផ្សារមូលបត្រ គឺជាទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រដែលក្រុមហ៊ុនបោះផ្សាយបានបោះផ្សាយលក់ជាសាធារណៈ[5]។ ទីផ្សារមូលបត្រ (Securities market) សំដៅដល់ទីកន្លែងលក់-ទិញដូរមូលបត្រ បើនិយាយសាមញ្ញ យើងអាចហៅទីផ្សារមូលបត្រថាជា "ទីផ្សារភាគហ៊ុន" ពីព្រោះផលិតផលដែលលក់ដំបូងគេនៅលើទីផ្សារនេះគឺភាគហ៊ុន។

### ១.៤.២. ប្រភេទទីផ្សារមូលបត្រ

បើតាមយន្តការទីផ្សារ គេអាចបែងចែកទីផ្សារមូលបត្រជា ពីរ(០២)ប្រភេទគឺទីផ្សារដំបូង និង ទីផ្សារបន្ទាប់ ។

- **ទីផ្សារដំបូង** (Primary Market) ៖ គឺជាកន្លែងដែលមូលបត្រត្រូវបានដាក់លក់លើកទីមួយទៅឱ្យវិនិយោគិន ដែលការទិញមូលបត្រនេះត្រូវទិញដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ[6]។ មូលបត្រដែលជួញដូរក្នុងទីផ្សារដំបូងគឺមូលបត្រថ្មី ដែលជាមូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬធ្វើសំណើរជាសាធារណៈ ពីមុនមកដោយក្រុមហ៊ុនបោះផ្សាយ។
- **ទីផ្សារបន្ទាប់** (Secondary Market) ៖ គឺជាទីផ្សារសម្រាប់ជួញដូរមូលបត្រដែលបានបោះផ្សាយរួចរវាងវិនិយោគិនសាធារណៈ និងវិនិយោគិនសាធារណៈ[7]។ នៅពេលដែលវិនិយោគិនសាធារណៈទិញភាគហ៊ុនផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយក្នុងទីផ្សារដំបូង ពួកគេអាចលក់ភាគហ៊ុនទៅវិនិយោគិនផ្សេងទៀត ដែលដំណើរការលក់ភាគហ៊ុននេះត្រូវបានធ្វើឡើងក្នុងទីផ្សារបន្ទាប់។ ការកំណត់ថ្លៃ និងការផ្តល់កម្មសិទ្ធកើតមានឡើងផងដែរ នៅពេលដែលវិនិយោគិនធ្វើការជួញដូរភាគហ៊ុនក្នុងទីផ្សារនេះហើយ ទីផ្សារបន្ទាប់ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាធានានូវសន្ទនីយ៍ភាពនៃមូលបត្រ ធានាការកំណត់ថ្លៃទាក់ទាញវិនិយោគិន រួមទាំងការកាត់បន្ថយចំណាយលើប្រតិបត្តិការជួញដូរ (ទីផ្សារនេះផ្តល់ពត៌មាន

[5] គណៈកម្មការមូលបត្រកម្ពុជា, ច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន"
[6] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សាមូលបត្រ,ភ្នំពេញ ២០១១ ទំព័រ ១៧
[7] ញាន វណ្ណៈ ហិរញ្ញប្បទានរបស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយៈទីផ្សារមូលបត្រ ភ្នំពេញ ២០០៧ ទំព័រ២៩

ច្បាស់លាស់ និងទាន់ពេលវេលាទាក់ទងនឹងតម្លៃ)។ ទីផ្សារបន្ទាប់នេះអាចជាទីផ្សារផ្លូវការ ឬ ទីផ្សារក្រៅប្រព័ន្ធ។

## ១.៥. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាសរសៃឈាមមួយដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និង វិនិយោគិននានា ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូលផងដែរ។ អាស្រ័យហេតុដូចនេះគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកតែងតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍទីផ្សារនេះ ដើម្បីធានាបាននូវការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងចីរភាពក្នុងទិសដៅរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ក្នុងរយៈពេលជាងមួយទសវត្សរកន្លងទៅ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ទោះបីជាត្រូវជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេសយ៉ាងណាក៏ដោយ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នសកលបានចាត់ទុកកម្ពុជាថា ជាប្រទេសមួយនៅក្នុងចំណោមប្រទេសទាំងប្រាំបី ដែលមានភាពនៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត។ ក្នុងន័យនេះ វិស័យមូលបត្រត្រូវបានអភិវឌ្ឍនិងដើរតួជាមធ្យោបាយនៃការកៀរគរមូលធន ប្រភពហិរញ្ញវត្ថុរយៈពេលវែង ដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើហិរញ្ញប្បទាន (Financing) ជាក់ស្តែង និងការបែងចែកមូលធននៅកម្ពុជាឱ្យកាន់តែសម្បូរបែប សម្រាប់គម្រោងវិនិយោគនានា ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។

# ជំពូកទី ២

# ទីផ្សារមូលបត្រនៅកម្ពុជា

## ២.១. ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជា

វិស័យធនាគារ និងវិស័យមូលបត្រ ជាវិស័យពីរដែលដំណើរការដោយមានការបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពដើម្បីធ្វើការជម្រុញដល់កំណើនសេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពប្រសើរឡើង។ វិស័យមូលបត្រ គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុរបស់ជាតិ ដោយតាមរយៈការផ្តល់ជាយន្តការមួយសម្រាប់ប្រមូលប្រភពហិរញ្ញវត្ថុដ៏ទៃៗទៀត រួមទាំងខ្នាតធំ និងមធ្យម ព្រមទាំងរយៈពេលខ្លី វែង និងមធ្យមដើម្បីធ្វើហិរញ្ញប្បទាន (Financing) គម្រោងវិនិយោគនានា និងធ្វើឱ្យមានភាពសម្បូរបែបនៃប្រភពធនធានដែលមានក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចមានសន្ទុះកាន់តែខ្លាំង។ ការលេចមុខឡើងនូវទីផ្សារមូលបត្រកម្ពុជានឹងផ្តល់ជម្រើសថ្មីមួយថែមទៀតក្នុងការវិនិយោគលើវិស័យហិរញ្ញវត្ថុ បន្ទាប់ពីមានការដាក់ប្រាក់បញ្ញើនៅក្នុងធនាគារ និងការប្រើប្រាស់សាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព។

ដំណើរការទីផ្សារមូលបត្រអាចប្រព្រឹត្តិទៅបានដោយស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលបានរៀបចំឡើង និងអនុម័តដោយអាជ្ញាធរមូលបត្រនៃប្រទេសនីមួយៗ។ ជាទូទៅច្បាប់ និងបទប្បញ្ញត្តិនានានៅក្នុងវិស័យមូលបត្រ គឺមានគោលដៅក្នុងការការពារវិនិយោគិនទាំងអស់ ព្រមទាំងធានាបានថាប្រព័ន្ធនៃទីផ្សារមូលបត្រទាំងមូលមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធភាព រួមទាំងយន្តការនៃការគ្រប់គ្រងហានិភ័យ ជម្រុញឱ្យមានតម្លាភាព មានភាពល្អប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុ និងមានភាពល្អប្រសើរចំពោះសាជីវកម្មក្នុងក្រុមហ៊ុន និងសហគ្រាស។ រាល់សកម្មភាពទាំងអស់ដែលមានការពាក់ព័ន្ធក្នុងវិស័យមូលបត្រទាំងមូល គឺត្រូវតែស្ថិតនៅក្រោមច្បាប់នៃបទប្បញ្ញត្តិពិសេសមួយ ដោយតម្រូវឱ្យមានការដាក់បង្ហាញពត៌មានជាសាធារណៈដោយមិនមានការក្លែងបន្លំណាមួយខុសច្បាប់ នៅក្នុងវិស័យមូលបត្រនោះឡើយ។ ហើយចំពោះច្បាប់និងបទប្បញ្ញត្តិ គឺត្រូវបានគេប្រើប្រាស់ ដើម្បីគ្រប់គ្រងរាល់ពត៌មានទាំងឡាយលើទីផ្សារ រួមទាំងដំណើរការទិញ-លក់មូលបត្រ ដែលគេស្គាល់ថា គឺជាការជួញដូរមូលបត្រ។ ការធ្វើបែបនេះក្នុងគោលបំណងឱ្យវិនិយោគិនទាំងអស់ អាចទទួលបាននូវពត៌មានដូចៗគ្នា ហើយមានឱកាសដូចៗគ្នាក្នុងការធ្វើការជួញដូរមូលបត្រលើទីផ្សារមូលបត្រ។ ពោលគឺវាអាចទទួលបានកម្រិតប្រកួតប្រជែងស្មើៗគ្នាមួយ ដែលជាកត្តាសំខាន់មួយ ធ្វើឱ្យវិនិយោគិនទាំងអស់មានទំនុកចិត្តចំពោះទីផ្សារមូលបត្រ។ ដើម្បីទទួលបានកម្រិតប្រកួតប្រជែងស្មើភាពគ្នានោះ គឺទាមទារឱ្យមានការឃោសនា

ផ្សព្វផ្សាយរាល់ពត៌មានទាំងឡាយ ដែលទាក់ទងនឹងព្រឹត្តិការណ៍សំខាន់ៗនៃក្រុមហ៊ុនបោះផ្សាយមូលបត្រឱ្យបានទូលំទូលាយ រួមទាំងវិនិយោគិនទាំងអស់ទទួលបាននូវពត៌មានស្មើៗគ្នា។ ច្បាប់និងបទប្បញ្ញត្តិត្រូវបានកំណត់ និងតាមដានពីអាកប្បកិរិយា អ្នកចូលរួមនៅក្នុងទីផ្សារមូលបត្រទាំងអស់ ព្រមទាំងដាក់ផាក់ពិន័យចំពោះទង្វើទាំងឡាយណា ដែលមានការរំលោភលើការជឿទុកចិត្តចំពោះទីផ្សារមូលបត្រ និងនិយាមទីផ្សារដែលបានកំណត់ទុកជាមុន ក្នុងការចុះបញ្ជីនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អន្តរការីមូលបត្រ និងមូលបត្រដែលបានបោះផ្សាយទាំងអស់។

## ២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា ផ.ម.ក.) គឺជាអ្នកដែលផ្តល់កន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រនៅលើទីផ្សារបន្ទាប់ ដែលវាជាប្រត្តិបត្តិករទីផ្សារមូលបត្រទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា។ យើងដឹងហើយថា ទីផ្សារបន្ទាប់ គឺជាន្លែងដែលមូលបត្រត្រូវបានជួញដូរបន្ត រវាងអ្នកទិញ និងអ្នកលក់ ដែលជាវិនិយោគិនមានន័យថា វិនិយោគិនដែលបានទិញមូលបត្ររួចក្នុងទីផ្សារដំបូងអាចលក់ចេញវិញបានទៅឱ្យវិនិយោគិនមួយផ្សេងទៀត។ ដោយឡែកប្រាក់ដែលបានមកពីសកម្មភាពជួញដូរលើទីផ្សារបន្ទាប់គឺ បានទៅលើអ្នកកាន់កាប់មូលបត្រមិនមែនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រឡើយ។ ពោលគឺក្រុមហ៊ុនបោះផ្សាយលក់មិនទទួលផលប្រយោជន៍សេដ្ឋកិច្ចពីការជួញដូរលើទីផ្សារបន្ទាប់ឡើយ។

### ២.២.១. សាវតា

ដើម្បីសម្រេចបាននូវការ អភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធននៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍន៍ផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឱ្យដំណើរការគម្រោងបង្កើត ទីផ្សារមូលបត្រនៅ ប្រទេសកម្ពុជានៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ

(Joint Venter) ដើម្បីបង្កើតផ្សារមូលបត្រ ‶ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា″ ដែលស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១០។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានដាក់សម្ពោធឱ្យដំណើរការកាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១១ ក្រោមអធិបតីភាពរបស់ ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាប្រភេទក្រុមហ៊ុនចម្រុះ (Joint Venture) ដែលមានភាគហ៊ុន ៥៥% កាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា និង ៤៥% ទៀតត្រូវបានកាន់កាប់ដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

### ២.២.២. រចនាសម្ព័ន្ធគ្រប់គ្រង

រូបភាពទី២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា




### ២.២.៣. ក្រុមប្រឹក្សាភិបាល

រូបភាពទី៣៖ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា



ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធាន ក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

សមាជិកចំនួន ៤ រូបផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ដោយក្នុងនោះ ២ រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ២ រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅក្នុងក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧ រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយកនោះមានដូចខាងក្រោម៖

- ឯ.ឧ. បណ្ឌិត **ហ៊ាន សាហ៊ីប** ប្រធានក្រុមប្រឹក្សាភិបាលអគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- Mr. **Lee Ihnsoo** អនុប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយករងនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- លោក **ហុង សុហួរ** សមាជិកអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- លោក **វ័ន្ន សារុធ** សមាជិកអគ្គនាយករងនៃធនាគារជាតិនៃកម្ពុជា។
- លោក **ហ៊ីម ហ៊ាន** សមាជិកប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។
- Mr. **KI-JOON YOON** សមាជិកអគ្គនាយករងជាន់ខ្ពស់នៃនាយកដ្ឋាន Global Business Management នៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- Mr. **HWI-SHIG CHO** សមាជិកប្រធាននាយកដ្ឋានប្រតិបត្តិការទីផ្សារនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

### ២.២.៤. គណៈគ្រប់គ្រង



#### ២.២.៥. ចក្ខុវិស័យ និងបេសសកម្ម

##### ២.២.៥.១. ចក្ខុវិស័យ

ដើម្បីឱ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានដំណើរការនៅលើមាគ៌ាមួយ ដែលប្រកបដោយសេចក្តីត្រឹមត្រូវ ក្រុមហ៊ុនបានធ្វើការកំណត់យ៉ាងច្បាស់លាស់ ទៅលើចក្ខុវិស័យរបស់ខ្លួន គឺ «ដើម្បីកសាងឧត្តមភាពនៃហិរញ្ញវត្ថុសម្រាប់ព្រះរាជាណាចក្រកម្ពុជា»។

##### ២.២.៥.២. បេសសកម្ម

គណៈកម្មការមូលបត្រកម្ពុជា ដើម្បីសម្រេចបាននូវ ចក្ខុវិស័យខាងលើ គឺបានដាក់ចេញនូវបេសកកម្មដែលមានដូចខាងក្រោមៈ

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា។
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស។
- ដើម្បីបង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទ សម្រាប់ចូលរួមទីផ្សារទាំងអស់។
- ដើម្បីដាក់ឱ្យដំណើរការនៅសហគ្រាសសាធារណៈមួយ ដែលមាស្វ័យចិរភាពក្រោមមគ្គុទេសដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.៣. តួអង្គពាក់ព័ន្ធក្នុងទីផ្សារមូលបត្រកម្ពុជា

#### ២.៣.១. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ

ទីផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារដ៏ថ្មីស្រឡាងមួយសម្រាប់សាធារណៈជនក្នុងប្រទេសកម្ពុជា។ ទីផ្សារនេះអាចដំណើរការទៅបាន អាស្រ័យលើតួអង្គសំខាន់ៗដែលមានដូចជា និយ័តករមូលបត្រសំដៅដល់គណៈកម្មការមូលបត្រកម្ពុជា ប្រតិបត្តិករមូលបត្រសំដៅដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្រុមហ៊ុន បោះផ្សាយមូលបត្រ ក្រុមហ៊ុនមូលបត្រ និងវិនិយោគិនមូលបត្រ។

##### ២.៣.១.១. ក្រុមហ៊ុនបោះផ្សាយមូលបត្រ

បើយោងតាមសន្ទានុក្រមនៅក្នុងគេហទំព័រគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សំដៅលើក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយមូលបត្រលក់ជាសាធារណៈ។ ក្រុមហ៊ុនបោះ

ផ្សាយមូលបត្រជាតួអង្គយ៉ាងសំខាន់ក្នុងវិស័យមូលបត្រ ព្រោះបើគ្មានក្រុមហ៊ុនបោះផ្សាយមូលបត្រទេ នោះក៏មិនមានមូលបត្រដាក់លក់លើទីផ្សារឡើយ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រក៏អាច ទទួលបានអត្ថប្រយោជន៍ពីលក់មូលបត្រដូចជា ការប្រមូលទុនវិនិយោគ ជាជាងការខ្ចីឥណទាន ពីធានាគារ និងដៃគូពាណិជ្ជកម្មផ្សេងៗ ព្រមទាំងកៀរគរមូលធន ឬដើមទុនពីវិនិយោគសាធារណៈ សម្រាប់ពង្រីកការវិនិយោគរបស់ក្រុមហ៊ុនថែមទៀត។ យ៉ាងណាមិញបើគិតមកត្រឹមខែមិថុនា ឆ្នាំ ២០១៧ នេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រនៅ កម្ពុជាមានចំនួន ៥ ដែលក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

- **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (Phnom Penh Water Supply Authority)** ជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ផលិត និងចែកចាយទឹកស្អាតជូនប្រជាពលរដ្ឋ ទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាល ដែលជាប់នឹងរាជធានីភ្នំពេញ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាក្រុមហ៊ុនមួយដែលចុះបញ្ជីផ្លូវការនៅក្រុមហ៊ុនមូលបត្រកម្ពុជានៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ដោយបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ លើចំនួនមូលបត្រកម្មសិទ្ធមានសិទ្ធិបោះឆ្នោះតសរុប ៨៦.៩៧៣.១៦២ ក្នុងថ្លៃ ៦.៣០០០ រៀលក្នុងមួយឯកតា[8]។
- **ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ីនធើណេតសិនណល (ខេមបូឌា) ភីអិលស៊ី (Grand Twins International (Cambodia) Plc.)** ជាក្រុមហ៊ុនផលិតសម្លៀកបំពាក់សម្រាប់នាំចេញ និងជារោងចក្រមៅការបន្ត ផលិតសំលៀកបំពាក់ម៉ាក់ Adidas, Reebok, Taylor Made, Salomon, New Balance, Nautica, និង North Face ជាដើម។ ក្រុមហ៊ុននេះចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ដោយបោះផ្សាយមូលបត្រកម្មសិទ្ធជាសាធារណៈចំនួន ៨.០០០.០០០ លើចំនួនមូលបត្រកម្មសិទ្ធ មានសិទ្ធបោះឆ្នោតសរុប ៥០.០០០.០០០ ក្នុងថ្លៃ ៩.៦៥០ រៀលមួយឯកតា[9]។
- **កំពង់ផែស្វយ័តភ្នំពេញ (Phnom Penh Autonomous Port)** ជាគ្រឹះស្ថានសាធារណៈដែលមានសេដ្ឋកិច្ចស្ថិតក្រោមច្បាប់ ហើយដើរតួនាទីជាអាជ្ញាធរផែ និងជាប្រតិបត្តិករផែ ដែលមានចំណាតផែចំនួន៤ គឺចំណាតកំពង់ផែពហុបំណង TS3 ចំណាតផែអ្នកដំណើរ TS1

[8] គណៈកម្មការមូលបត្រកម្ពុជា, អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ(ភ្នំពេញ,២០១៦)ទំព័រ ១៨។
[9] គណៈកម្មការមូលបត្រកម្ពុជា, អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ(ភ្នំពេញ,២០១៦)ទំព័រ ១៨។

ចំណត ផែកុងតឺន័រថ្មី LM17 និងចំណតផែទន្លេបិទ UM2 ព្រមទាំងអាជីវកម្មមួយចំនួនទៀត។ កំពង់ផែស្វយ័តភ្នំពេញបានចុះបញ្ជីជា ផ្លូវការនៅផ្សារមូលបត្រកម្ពុជានៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៥ដោយបោះផ្សាយ លក់មូលបត្រកម្មសិទ្ធ ជាសាធារណៈចំនួន ៤.១៣៦.៨៧៣ លើចំនួនមូលបត្រកម្មសិទ្ធដែលមានបោះឆ្នោតសរុប ២០.៦៨៤.៣៦៥ ក្នុងថ្លៃមួយ ឯកតា ៥.១២០ រៀល[10]។

- **ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** (Phnom Penh SEZ Plc.) ជាក្រុមហ៊ុនអភិវឌ្ឍន៍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេស (PPSEZ) ដែលមានប្រតិបត្តិការអាជីវកម្មជាច្រើនប្រភេទដូចជា ការអភិវឌ្ឍន៍ដីសម្រាប់លក់ ឬជួល ការផ្គត់ផ្គង់សេវាកម្មបរិវេណ PPSEZ ដែលមានដូចជា ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាប្រឹក្សាយោលបល់ និងជំនួយកិច្ចការរដ្ឋបាលជាដើម។ ក្រុមហ៊ុននេះបានចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក. នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ដោយបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈចំនួន ១១.៥៧៥.០០០ លើចំនួនមូលកម្មសិទ្ធមានសិទ្ធបោះឆ្នោតសរុប ៥៧, ៨៧៥,០០០ ក្នុងថ្លៃមួយឯកតា ២.៨៦០រៀល[11]។
- **កំពង់ផែស្វយ័តក្រុងព្រះសីហនុះ ក.ស.ស.** ជាក្រុមហ៊ុនរបស់រដ្ឋ ដែលបានបង្កើតឡើងដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារ។ កណ្តាធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់សម្ភារៈដល់នាវា លើកដាក់ ផ្ទេរ ផ្ទុកទំនិញ ស្តុកទំនិញនៅឃ្លាំង ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្តល់សេវាកម្មផ្សេងទៀតៈ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាជួលឃ្លាំង និងថែរក្សារទំនិញ លើកដាក់ និងដឹកញ្ជូនទំនិញ រួមទាំងសេវាកម្មសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ មួយវិញទៀតវាជាទីតាំងយុទ្ធសាស្ត្រមួយងាយស្រួលដឹកជញ្ជូនទៅទីផ្សារតំបន់អាស៊ាន និងតំបន់អាស៊ីប៉ាស៊ីហ្វិច ដោយពុំចាំបាច់ឆ្លងកាត់កំពង់ផែក្នុងតំបន់។ បើគិតត្រឹម ៦ខែ ដំបូងក្នុងឆ្នាំ ២០១៦ ក.ស.ស រកចំណូលបាន១០២, ០៦ ពាន់លានរៀល។

[10] គណៈកម្មការមូលបត្រកម្ពុជា, អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ(ភ្នំពេញ,២០១៦)ទំព័រ ១៨។

[11] ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី, ឯកសារផ្តល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ(ភ្នំពេញ, ២០១៦), ទំព័រ ០១។

### ២.៣.១.២. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការទិញ-លក់ក្នុងទីផ្សារមូលបត្រកម្ពុជាតាមរយៈការដើរតួជាអន្តរការី។ ជាទូទៅក្រុមហ៊ុននេះដើរតួនាទីជាអន្តរការី ឬជាអ្នកសម្របសម្រួលប្រតិបត្តការមូលបត្រនៅក្នុងទីផ្សារ។ ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គសំខាន់មួយនៅក្នុងដំណើរការទីផ្សារមូលបត្រ ព្រោះក្រុមហ៊ុនមូលបត្រ ត្រូវបានចាត់ទុកជាអ្នកជំនាញក្នុងវិស័យកមូលបត្រដែលមានតួនាទីយ៉ាងសំខាន់ដើម្បីជួយ ក្រុមហ៊ុនបោះផ្សាយក្នុងដំណើរការបោះផ្សាយលក់មូលបត្រ នៅលើទីផ្សារទទួលបានជោគជ័យ។ លើសពីនេះទៀតក្រុមហ៊ុនមូលបត្រក៏មានតួនាទីជួយដល់វិនិយោគិនមូលបត្រនៅក្នុងដំណើរការនៃការជួញដូរមូលបត្រ (ការទិញ-លក់មូលបត្រ) នៅក្នុងទីផ្សារផងដែរ ព្រោះវិនិយោគិនមិនអាចធ្វើការជួញដូរមូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្រដោយខ្លួនឯងបាននោះទេ។ រាល់ការជួញដូរមូលបត្ររបស់វិនិយោគិនត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលជាឈ្មួញជើងសារ។ ជារួមក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអន្តរការីមូលបត្រដែលមិនអាចខ្វះបាននៅក្នុងទីផ្សារ ទាំងក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ និងក្នុងដំណើរការនៃការជួញដូរមូលបត្ររបស់វិនិយោគិន។ បច្ចុប្បន្ននៅកម្ពុជាមានក្រុមហ៊ុនមូលបត្រចំនួន ១៥ (ដប់ប្រាំ) ដែលមានសកម្មភាពអាជីវកម្ម ៤ (បួន) យ៉ាងសំខាន់ៗ[12]៖

- ក្រុមហ៊ុនធានាទិញមូលបត្រ ( Securities Underwriters )
- ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ( Securities Dealers )
- ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ( Securities Brokers )
- ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ( Investment Advisers )

ចំពោះក្រុមហ៊ុនមូលបត្រ ដែលមានសកម្មភាពអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ និង ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រទាមទារឱ្យមាន ការផ្ដល់អាជ្ញាបណ្ណពីគណៈគម្មាការមូលបត្រកម្ពុជា ដើម្បីធ្វើអាជីវកម្មនៅលើទីផ្សារមូលបត្រ។ ដោយឡែកក្រុមហ៊ុន ទីប្រឹក្សាវិនិយោគ មិនតម្រូវឱ្យមានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាទេ តែក្រុមហ៊ុននេះត្រូវតែមានភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គណៈកម្មការមូលបត្រកម្ពុជាយ៉ាងតិចមួយរូប។

[12] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៥

➢ **ក្រុមហ៊ុនធានាទិញមូលបត្រ**

ក្រុមហ៊ុនធានាទិញមូលបត្រ មានតួនាទីក្នុងទិញយកមូលបត្រ ដែលនៅសល់ទាំងអស់ ឬមួយផ្នែកទៅតាមលក្ខខណ្ឌនៃកិច្ចសន្យារវាងក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងករណី ដែលមូលបត្រដែលបោះផ្សាយនោះមិនបានលក់អស់ក្នុងដំណាក់កាលបរិវិស កម្ម។ ក្នុងការបោះផ្សាយជាសាធារណៈលើកដំបូង (Initial Public Offering/ IPO) ក្រុមហ៊ុនធានាទិញមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការទិញយកមូលបត្រដែលនៅសល់ និងផ្តល់ជាការប្រឹក្សាដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ការប្រឹក្សាក្នុងការបោះផ្សាយជាសាធារណៈ លើកដំបូងនេះមានដូចជា ការកំណត់ទំហំទឹកប្រាក់ ការកំណត់ថ្លៃមូលបត្រ ការកំណត់ចំនួនមូលបត្រ និងការកំណត់ពេលវេលាក្នុងការបោះផ្សាយ។ ចំពោះក្រុមហ៊ុនដែលជាក្រុមហ៊ុនធានាទិញមូលបត្រ អាចមានសិទ្ធិធ្វើអាជីវកម្មធានាទិញមូលបត្រអាជីវកម្មជួញដូរមូលបត្រ អាជីវកម្មឈ្មួញជើងសាមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

ក្រុមហ៊ុនដែលធានាទិញមូលបត្រមានដូចជា៖

- ក្រុមហ៊ុនយាន់តាស៊ីយ្យូរីធី( ខេមបូឌា)ភីអិលស៊ី
- ក្រុមហ៊ុន អ អេច ប៊ី អូ អេស ខេ ឥណ្ឌូឆៃណាស៊ីយ្យូរីធី លីមីធីត
- ក្រុមហ៊ុន កាណា ស៊ីយ្យូរីធី អិលធីឌី
- ក្រុមហ៊ុន កម្ពុ ស៊ីយ្យូរីធីភីអិលស៊ី
- ក្រុមហ៊ុន ខេមបូឌា-វៀតណាម ស៊ីយ្យូរីធី ភីអិលស៊ី
- ក្រុមហ៊ុនអេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី ភីអិលស៊ី
- ក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី

➢ **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ**

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរមូលបត្រ (ទិញ-លក់) ក្នុងទីផ្សារមូលបត្រ។ ដូចនេះ តម្រូវឱ្យក្រុមហ៊ុនពាណិជ្ជករមូលបត្រមានគណនីផ្ទាល់ខ្លួនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្នុងការជួញដូរនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រអាចទទួលបានផលចំណេញពីមូលបត្រ ហើយក៏ ត្រូវប្រឈមមុខនឹងហានិភ័យក្នុងការជួញដូរមូលបត្រផងដែរ[13]។ ក្នុងនាមជាក្រុមហ៊ុនពាណិជ្ជករមូលបត្រអាចមានសិទ្ធិធ្វើអាជីវកម្មដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ និង

[13] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៦។

អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រមានតែក្រុមហ៊ុន ហ្គោលដេន ហ្វ៊រឈ្យូន (ខេមបូឌា) ភីអិលស៊ី តែប៉ុណ្ណោះ។

➢ **ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ**

ក្រុមហ៊ុនមូលបត្រដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ មាននាទីជាអ្នកទទួលទិញ ឬលក់មូលបត្រ តាមបញ្ជារបស់អតិថិជនរបស់ខ្លួន[14]។ ក្នុងន័យនេះ សាធារណៈជនមិនអាចធ្វើការទិញ-លក់ មូលបត្រដោយផ្ទាល់នៅលើទីផ្សារមូលបត្របានទេ ប្រតិបត្តិការនេះទាមទារឱ្យឆ្លងកាត់អន្តរការីដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រទទួលបានកម្រៃជើងសារមូលបត្រ ទទួលបានកម្រៃជើងសារពីការ ទទួលបញ្ជាទិញ ឬលក់ពីអតិថិជនរបស់ខ្លួន។ ក្នុងនាមជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ អាចមានសិទ្ធិធ្វើអាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ ក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

- ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
- ក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី ភីអិលស៊ី

➢ **ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ**

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មានតួនាទីជាអ្នកផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រ និងបោះផ្សាយកាលវិភាគនៃការវិនិយោគលើមូលបត្រ សម្រាប់បវិនិយោគិនសាធារណៈ[15]។ ចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ មិនតម្រូវអោយមានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាទេ តែក្រុមហ៊ុននេះត្រូវតែមានភ្នាក់ងារទីប្រឹក្សាវិនិយោគ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាយ៉ាងតិចមួយរូប។ ក្នុងនាមជាក្រុមហ៊ុនប្រឹក្សវិនិយោគ អាចមានសិទ្ធតែធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគតែប៉ុណ្ណោះ។ ក្រុមហ៊ុនប្រឹក្សាវិនិយោគមានចំនួនពីរដែលមានដូចខាងក្រោម៖

- ក្រុមហ៊ុន អង្គរ យៃភីថល អ៊ែតវ៉ាយហ្ស៊ើរ
- ក្រុមហ៊ុន អេហ្វ.យូ.ជី.អាយ ហ្គោល។

---

[14] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៧។

[15] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ប្រការ៨។

**២.៣.១.៣. វិនិយោគិន**

វិនិយោគិនធម្មតា គឺសំដៅលើសាធារណៈជននៅក្នុងប្រទេសកម្ពុជា រួមទាំងរូបវន្តបុគ្គល និង នីតិបុគ្គលដែលមានសិទ្ធទិញឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើរលក់ជាសាធារណៈក្នុងប្រទេសកម្ពុជា ដោយក្រុមមូលបត្រមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ[16]។ វត្តមាននៃទីផ្សារមូលបត្រនៅកម្ពុជាបានអនុញ្ញាតវិនិយោគិន ដែលមានធនធាន (សាច់ប្រាក់) នៅទំនេរទៅវិនិយោគតាមរយៈការទិញមូលបត្របោះផ្សាយ ដោយក្រុមហ៊ុនបោះផ្សាយនៅលើទីផ្សារដើម្បីទទួលបាននូវផលចំណេញដូចជា ភាគលាភ ការប្រាក់ ឬការចំណេញជាមូលធន ជាជាងការទុកឱ្យនៅទំនេរចោល។

**២.៣.២. តួអង្គចូលរួមដទៃទៀត**

ក្រៅពីតួអង្គសំខាន់ៗ ដូចដែលបានរៀបរាប់ខាងលើ វិស័យមូលបត្រក៏មានតួអង្គចូលរួមដ៏ទៃទៀតដែលមានដូចជា៖

- **ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ៖** ជាភ្នាក់ងារដែលបានទទួលស្គាល់ពី គ.ម.ក ដែលគ្រប់គ្រងគណៈនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមានចំនួនបីគឺ៖
  - ធនាគារ អេស៊ីលីដា ភីអិលស៊ី
  - ធនាគារ កាណាឌីយ៉ា ក.អ
  - ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
- **ភ្នាក់ងារបញ្ជិកាមូលបត្រ ៖** ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក ដែលគ្រប់គ្រងនូវដំណើរនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រ កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រ និងធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។
- **ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ៖** ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក ដែលគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រឱ្យមានសង្គតិភាព ការផ្លាស់ប្តូរកម្មសិទ្ធករ ការធ្វើរបាយករណ៍ ស្ថិតិ និងការរៀបចំការពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិករមូលបត្រ ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបងការប្រាក់ដើម។

[16] ប្រកាសស្តីពីកាផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ,លេខ ០០៩ គ.ម.ក. ១៩ វិច្ឆិកា ២០០៩ , ទំព័រ ៥។

- **ភ្នាក់ងារទូទាត់ ៖** ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក ដែលមានតួនាទីជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើម ទូទាត់ជូនកម្មសិទ្ធិករ ឬភាគីដែលមានការពាក់ព័ន្ធក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ និងបញ្ជូនពត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ដល់កម្មសិទ្ធករមូលបត្រ និងទៅក្រុមហ៊ុនបោះផ្សាយ និងគ.ម.ក តាមការចាំបាច់។ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ មានចំនួន ពីរ ៖
  - ធនាគារ អេស៊ីលីដា ភីអិលស៊ី
  - ក្រុមហ៊ុន ត្រាយខ័រ ស៊ីយ្យូរីធី សិរីល ភីអិលស៊ី
- **ក្រុមហ៊ុន និងការិយាល័យមេធាវីផ្តល់សេវាផ្នែកច្បាប់នៅក្នុងវិស័យមូលបត្រ ៖** ជាក្រុមហ៊ុនដែលផ្តល់សេវាកម្មផ្នែកច្បាប់ ដែលបានទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជា។ ក្រុមហ៊ុនទាំនោះរួមមានដូចជា៖
  - ក្រុមហ៊ុនមេធាវី អេច ប៊ី អេស
  - ការិយាល័យមេធាវី អ អេន ធី សុខអេន ហេង
  - ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការី
  - ការិយាល័យមេធាវី សិទ្ធិសក្តិ
  - ក្រុមហ៊ុនមេធាវីអាស៊ី កម្ពុជា
  - ការិយាល័យមេធាវី ប៊ុន និងសហការី
  - ការិយាល័យ វីឌីប៊ី ឡយ & យុន
  - ការិយាល័យមេធាវី ស៊ិនត្រល
  - ការិយាល័យមេធាវី ស៊ី អេស អែល និងសហការី
- **ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ ៖** ជាក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជដែលទទួលស្គាល់ពី គ.ម.ក ដើម្បីធ្វើសវនកម្មនូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តតាមស្តង់ដារដែលបានកំណត់។ ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រមានចំនួនប្រាំមួយដូចជា៖
  - ក្រុមហ៊ុន ប្រាយវ៉េតផ៉រ ហាវខូភើស៍ (ខេមបូឌា)
  - ក្រុមហ៊ុន ខេ ភី អឹម ជី (ខេមបូឌា)
  - ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត
  - ក្រុមហ៊ុន អឺន ស្ទ័ អែន យ៉ាំង (ខេមបូឌា)

- ក្រុមហ៊ុន អង្គរ សឺធីហ្វាយ អឺខោនថឹន ណោតវើកអិមស៊ី មីលលែន រ៉ូដ (ខេមបូឌា)
- ក្រុមហ៊ុន ប្រេគ្គន សនថុន (ខេមបូឌា) លីមីតធីត។

- **ក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃផ្តល់សេវានៅក្នុងវិស័យមូលបត្រ ៖** ជាក្រុមហ៊ុនដែលទទួលស្គាល់ដោយ គ.ម.ក ដើម្បីវាយតម្លៃលើទ្រព្យសកម្ម ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។ បញ្ជីឈ្មោះក្រុមហ៊ុនដែលផ្តល់សេវានៅក្នុងការវិស័យមូលបត្រមានដូចជា៖

- ក្រុមហ៊ុន វីត្រាល់ អឺព្រេង្សល
- ក្រុមហ៊ុន រៀល អ៊ីស្ទេត វី.អិម.ស៊ី (ខេមបូឌា) អិលធីឌី
- ក្រុមហ៊ុន ស៊ី ប៊ី រីឆាត អ៊ែលលីស (ខេមបូឌា) ខមភេនីលីមីធីត
- ក្រុមហ៊ុន ប៊ុណ្ណា រៀលធី គ្រុប ខូលអិលធីឌី
- ក្រុមហ៊ុន ណាយ ប្រែង (ខេមបូឌា)

# ជំពូកទី ៣

# គណៈកម្មការមូលបត្រកម្ពុជា

## ៣.១. ទិដ្ឋភាពទូទៅនៃគណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា គ.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រ ប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា[17]។ គណៈកម្មការមូលបត្រកម្ពុជា ជានិយ័តករវិស័យមូលបត្រ ឬជាស្ថាប័នរដ្ឋមួយ ដែលមានភារកិច្ចជាអ្នករៀបរៀងរាល់បទប្បញ្ញត្តិដែលមានការពាក់ព័ន្ធសម្រាប់បង្កើត និងជួយត្រួតពិនិត្យទីផ្សារមូលបត្រ ព្រមទាំងជាអ្នកអនុញ្ញាត និងជាអ្នកផ្តល់អាជ្ញាប័ណ្ណគ្រប់បែបយ៉ាង ទៅឱ្យភាគីដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការប្រព្រឹត្តទៅនៅក្នុងទីផ្សារ។ ស្របតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ទីផ្សារមូលបត្រត្រូវបានបង្កើតឡើងដើម្បីជាមធ្យោបាយក្នុងកៀរគរមូលធន ព្រមទាំងបែងចែកទុនសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ចាប់តាំងពីការបង្កើតឱ្យមានទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជាមក សង្កេតឃើញថា ការអភិវឌ្ឍន៍របស់ទីផ្សារនេះ កំពុងបោះជំហ៊ានទៅមុខជាបណ្តើរៗ គួរឱ្យកត់សម្គាល់ ដោយមានវត្តមាននៃតួអង្គ ៤ សំខាន់ៗជាសារវ័ន្ត រួមមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់មូលបត្រ អន្តរការីមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិន។ ដំណើរការទីផ្សារមូលបត្រមួយ ដែលមានចីរភាព ប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងមានសណ្តាប់ធ្នាប់ ទាមទារឱ្យមានតួអង្គគាំទ្រជាច្រើនទៀតបន្ថែមពីលើតួអង្គទាំង ៤ នេះ។ ក្រៅពីការគាំទ្ររបស់តួអង្គទាំង ៤ ខាងលើ ចំណេះដឹង និងជំនាញរបស់តួអង្គនីមួយៗ ពីទីផ្សារមូលបត្រ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍ទីផ្សារនេះ។ ការយល់ដឹងពីវិស័យមូលបត្ររបស់សាធារណៈជន នៅមានកម្រិតនៅឡើយ ដោយហេតុថា វិស័យមូលបត្រជាវិស័យថ្មីមួយនៅព្រះរាជាណាចក្រកម្ពុជា ហើយវិសាលភាពនៃការបញ្ជ្រាបចំណេះដឹងពីវិស័យនេះ ក៏ពុំទាន់បានទូលំទូលាយគ្រប់គ្រាន់នៅឡើយ ទៅកាន់ស្រទាប់មហាជនគ្រប់មជ្ឈដ្ឋាន។ ក្នុងន័យនេះ ការផ្សព្វផ្សាយពត៌មានដែលមានសុក្រឹតភាព និងអាចជឿទុកចិត្តបានពីវិស័យមូលបត្រ ជាកត្តាគន្លឹះសម្រាប់ជំរុញការអភិវឌ្ឍន៍វិស័យមូលបត្រ

[17] គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (www.secc.gov.kh) (ចូលមើលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧)

នៅព្រះរាជាណាចក្រកម្ពុជា។ ស្របពេលនោះដែរ គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) មានមុខងារជាអ្នកគ្រប់គ្រងនឹងត្រួតពិនិត្យទីផ្សារមូលបត្រ បានគ្រប់គ្រងរាល់បណ្ដាប្រតិបត្តិការមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងអភិវឌ្ឍន៍ និងធានាឱ្យទីផ្សារមូលបត្រមានដំណើរការល្អប្រកបដោយតម្លាភាព មានប្រសិទ្ធភាពនៃទីផ្សារ មានរបៀបរាបរយ សណ្ដាប់ធ្នាប់ល្អ មានភាពយុត្តិធម៌ និងជួយសម្របសម្រួលដល់ការបង្កើតមូលធន។

### ៣.១.១. សាវតា

គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) ត្រូវបានបង្កើតឡើងក្រោមបញ្ញាតិនៃច្បាប់ស្ដីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការកាលពី ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៩ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្ដីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា" ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។

ពត៌មានសម្រាប់ទំនាក់ទំនងគណៈកម្មការមូលបត្រកម្ពុជា៖

- អាសយដ្ឋានផ្ទះលេខ ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ ភ្នំពេញ។
- ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៨ ៥៦ ១១
- ទូរសារ: (៨៥៥) ២៣ ៨៨ ៥៦ ២២
- អ៊ីម៉ែល: INFO@SECC.GOV.KH
- គេហទំព័រ: www.secc.gov.kh

### ៣.១.២. សមាសភាពរបស់ គ.ម.ក.

ធនធានមនុស្ស ជាទ្រព្យសកម្មមួយដ៏ចាំបាច់របស់ស្ថាប័ន ឬអង្គការក្នុងការធ្វើឱ្យមានភាពរលូន និងប្រសិទ្ធភាពនៅក្នុងការអនុវត្តការងារ។ រចនាសម្ព័ន្ធ ត្រូវបានរៀបចំឡើងដើម្បីបែងចែកការទទួលខុសត្រូវរបស់បុគ្គលិកទៅតាមផ្នែក និងតួនាទីរៀងៗខ្លួន ។

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងក្រោមច្បាប់ស្ដីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ រូប ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានសមាជិក ៨ រូប ដែលមានដូចជា៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប

- តំណាងធានាគារជាតិនៃកម្ពុជា ១ រូប
- តំណាងក្រសួងយុត្តិធម៌ ១ រូប
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
- អគ្គនាយកនៃ គ.ម.ក ១ រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រ ២ រូប

សមាជិករបស់ គ.ម.ក មានអាណត្តិរយៈពេល ៥ ឆ្នាំ និងអាចត្រូវបានតែងតាំងសារជាថ្មី ឬក៏ផ្ទេរភារកិច្ចតាមសំណើររបស់ប្រធាន គ.ម.ក នៅពេលមានការផុតអាណត្តិ។ ក្នុងកំឡុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារៈកិច្ចមុនពេលអស់អាណត្តិ[18]។ គណៈកម្មការមូលបត្រកម្ពុជាដែលមានឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន មានសមាជិកចំនួន ០៨ រូបដែលមានអាណត្តិរយៈពេល ០៥ ឆ្នាំ។ សមាជិកទាំងនោះរួមមាន៖ គណៈកម្មការមូលបត្រកម្ពុជាដែលមានឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន មានសមាជិកចំនួន ០៨ រូបដែលមានអាណត្តិរយៈពេល ០៥ ឆ្នាំ។ សមាជិកទាំងនោះរួមមានៈ

- ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ម.ក.
- លោកជំទាវ **ងួន សុខា** ជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកនៃ គ.ម.ក.
- លោកជំទាវ **នាវ ច័ន្ទថាណា** ជាអគ្គទេសាភិបាលរងនៃធនាគារជាតិកម្ពុជា និងជាសមាជិកនៃ គ.ម.ក.
- លោកជំទាវ **តឹករ៉េត កំរង** ជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម និងជាសមាជិក គ.ម.ក.
- ឯកឧត្តម **កើត រិទ្ធ** ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាសមាជិក គ.ម.ក.
- ឯកឧត្តម **គឹម រ័ត្នវិសិដ្ឋ** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិក គ.ម.ក.
- ឯកឧត្តម **ស៊ូ សុជាតិ** ជាអគ្គនាយកនៃ គ.ម.ក. និងជាសមាជិក គ.ម.ក.
- លោកសាស្ត្រាចារ្យបណ្ឌិត **សំ ឃង្វី** ជាអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក.

[18] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០០៧ "ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនៈ មាត្រាទី ៥

- លោកសាស្ត្រាចារ្យបណ្ឌិត **សំ សុខុម** ជាអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធន៍វិស័យមូលបត្រ និងជាសមាជិក គ.ម.ក។

**៣.១.២.១. អង្គភាពចាត់តាំង**

គ.ម.ក. មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម ៖




**៣.១.២.២. សមាសភាពរបស់ថ្នាក់ដឹកនាំបច្ចេកទេស**

| ឈ្មោះ | តួនាទី |
|---|---|
| ឯកឧត្តម ស៊ូ សុជាតិ | អគ្គនាយក |
| ឯកឧត្តម សុខ ដារ៉ា | អគ្គនាយករងទទួលបន្ទុកខាងនាយកដ្ឋានត្រួតពិនិត្យអង្គការីមូលបត្រ និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ |
| ឯកឧត្តម ឈុន សម្បត្តិ | អគ្គនាយករងទទួលបន្ទុកខាងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ |
| ឯកឧត្តម ស្រៀង ធីរិទ្ធ | អគ្គនាយករងទទួលបន្ទុកខាងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ និងនាយកដ្ឋានកិច្ចការគតិយុត្ត |
| លោកបណ្ឌិត រិន ភក្តី | នាយកដ្ឋាន ត្រួតពិនិត្យអង្គការីមូលបត្រ |
| លោក វ៉ា សូរី | នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ |
| ឯកឧត្តម ឆឹង ចន្ថា | នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| លោកស្រី នាង បូនី | នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ |

| | |
|---|---|
| ឯកឧត្តម សូវ្យ ប៉ូលែន | នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ |
| លោកស្រី សុខ សុគន្ធជីវី | នាយកដ្ឋានកិច្ចការគតិយុត្ត |
| លោក ឈុំ សេរីវុធ | អគ្គភាពសវនកម្មផ្ទៃក្នុង |

- **នាយកដ្ឋានរបស់ គ.ម.ក.**

គ.ម.ក. មាននាយកដ្ឋានចំណុះចំនួន ០៦ (ប្រាំមួយ) ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ គ.ម. ក មានដូចជា៖

**នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក.។
- គ្រប់គ្រងកិច្ចការរដ្ឋបាល។
- ផ្គត់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ។
- ចាត់ចែងការងារពិធីការ។
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា។
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក។
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.។
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន។

**នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុននានា បោះផ្សាយលក់មូលបត្រជាសាធារណៈ។
- រៀបចំលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ។
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ។
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈ។

- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ។
- ចុះបញ្ជីឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬ/និងតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និងរបាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ជាសាធារណៈ។
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមានការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ។
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃនៅក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ។
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ។

- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ។
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុន មូលបត្រភ្នាក់ងារ ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារ មូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ។

**នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារ និងតួនាទីដូចតទៅៈ

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការជាមួយ។
- ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុក មូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ
- ប្រតិបត្តិករប្រព័ន្ធទូទាត់ និងជាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀត របស់ប្រតិបត្តិករទីផ្សារមូលបត្រ។
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់។
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ។
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធ ជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹង ប្រតិបត្តិករទីផ្សារ ។
- មូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយក ដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារ និងតួនាទីដូចតទៅៈ

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករ ប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និង

សម្រេចពីអគ្គនាយកនៃ គ.ម.ក។

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ។
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ។
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ។
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតីទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់។
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ។
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ពាព័ន្ធនឹងវិស័យមូលបត្រ។
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ។
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ អគ្គនាយកនៃគ.ម.ក។

**នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានមុខងារ និងតួនាទីដូចតទៅៈ

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា សិក្សាស្រាវជ្រាវលើការអភិវឌ្ឍន៍នៃវិស័យមូលបត្រនៅកម្ពុជា។
- គ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល់។
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឱ្យបោះផ្សាយនៅលើទីផ្សារ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណៈជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ។
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

**អង្គភាពសវនកម្មផ្ទៃក្នុង**

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ ប្រធាន គ.ម.ក។ អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួនាទីដូចតទៅៈ

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក. ក្នុងការិយបរិច្ឆេទសមស្រប ដើម្បីកំនត់ការអនុវត្តអោយបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទបញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក.។
- កំនត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក.។
- ពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃពត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីពត៌មាន និងទិន្នន័យទាំងនេះក្នុងការិយបរិច្ឆេតសមស្រប។
- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអ ប្រសិនបើមានកំហុស។
- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក.។
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ គ.ម.ក ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តប្រតិបត្តិការ។
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការបស់ គ.ម.ក. ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ។
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន និងសមាជិកនៃគ.ម.ក. ពិនិត្យ និងផ្តល់ការណែនាំ។
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក.។
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក. ពិនិត្យ និងសម្រេច។

- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឱ្យបានគ្រប់គ្រាន់ និងសមស្របជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

### ៣.១.៣. ចក្ខុវិស័យ និងបេសកកម្ម

ក្នុងគោលបំណងគ្រប់គ្រងវិស័យមូលបត្រក្នុងប្រទេសកម្ពុជាប្រកបដោយស្ថេរភាព មានតម្លាភាព មានយុត្តិធម៌ និងមានសណ្តាប់ធ្នាប់ គណៈកម្មការមូលបត្រមូលបត្រកម្ពុជា ដែលគេច្រើនហៅកាត់ថា **គ.ម.ក** មានចក្ខុវិស័យ និងបេសកកម្មដូចខាងក្រោម៖

#### ៣.១.៣.១. ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា **គ.ម.ក** ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ **គ.ម.ក** មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

#### ៣.១.៣.២. បេសកកម្ម

- បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៣.១.៤. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា

គណៈកម្មការមូលបត្រកម្ពុជា មានរូបសញ្ញាដូចជាស្ថាប័នរដ្ឋដទៃទៀត ដែលមានកំណត់សម្គាល់ដូចខាងក្រោម៖

#### ៣.១.៤.១. រូបសញ្ញា

*រូបភាពទី១៖ រូបសញ្ញាគណៈកម្មការមូលបត្រកម្ពុជា*

- រូបហង្សពណ៌មាស
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេង មានការលិចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់ កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- មានអក្សរពណ៌ទឹកប៊ិច ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើមានអក្សរខ្មែរថា "គណៈកម្មកាមូលបត្រកម្ពុជា" និងពាក់កណ្តាលនៃរង្វង់ នៅផ្នែកខាងក្រោមជាអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA" ។

#### ៣.១.៤.២. អត្ថន័យនៃរូបសញ្ញា

- **រូបហង្សមានពណ៌មាស** តំណាងឱ្យអាជ្ញាធរបរិញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រត្តិបត្តិការមូលបត្រ និងធានាឱ្យដំណើរការនៃទីផ្សារប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- **រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ** គឺតំណាងឱ្យភាពចំណេញខាតនៃដំណើរការទីផ្សារ។

- **រូបហង្សពណ៌មាសឈរលើរង្វង់ថាស ដែលមានជើងម្ខាង ជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ** ចង់បង្ហាញពីភាពចំណេញខាត ឬភាពឡើង ចុះនៃកិច្ចដំណើរការទីផ្សារដោយស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រង់របស់អាជ្ញាធរ ជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព សណ្តាប់ធ្នាប់ និងតម្លាភាពគ្នាជានិច្ច។
- **រូបស្លឹកឈើ** តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែក របស់វិស័យមូលបត្រក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

**៣.១.៤.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការអភិវឌ្ឍន៍នៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរាជ្ជកាលព្រះបាទអង្គឌួងដើម្បីរំលឹកដល់លោក សំអាង ហង្ស ដែលព្រះបាទអង្គឌួងបញ្ជូនអោយទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ចេញឱ្យប្រើប្រាស់ក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ និងសម័យសាធារណរដ្ឋ ក្រោមការដឹកនាំដោយការឆ្លាតវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនាពេលនោះត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៣.១.៥. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា**

រូបភាពទី ៖ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា



ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានសរសេរអក្សរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញា ប្រសាទអង្គរវត្ត និងផ្នែកខាងក្រោមមានសរសេរអក្សរថា "គណៈកម្មការមូលបត្រកម្ពុជា" ។

### ៣.១.៦. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងរាល់បណ្តាលប្រតិបត្តិការ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យការជួញដូរមូលបត្រ ប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ ការគ្រប់គ្រងនេះមានគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការប្រមូលមូលធនពីអ្នកវិនិយោគដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ធ្វើការ វិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មការមូលបត្រកម្ពុជា មានតួនាទីដូចខាងក្រោម[19] ៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។
- ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

[19] ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ភ្នំពេញ ២០០៧

# ជំពូកទី ៤
# ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិន

## ៤.១. ការត្រៀមខ្លួនជាមូលដ្ឋានរបស់វិនិយោគិន

**តើគួរដឹង យល់ និងចេះអ្វីខ្លះ មុននឹងចូលវិនិយោគនៅផ្សារហ៊ុន?** មានការទទួលស្គាល់ជាទូទៅនៅលើពិភពលោកថា ការវិនិយោគលើភាគហ៊ុនមានភាពងាយស្រួល និងអាចទទួលបានប្រាក់ចំណេញច្រើនជាងគេ លើរយៈពេលវែង។ ប៉ុន្តែការវិនិយោគភាគហ៊ុន ក៏មិនខុសពីការវិនិយោគដទៃដែរ គឺតែងទាមទារឱ្យមានចំណេះដឹងមួយចំនួនជាអប្បបរមា ដើម្បីអាចទាញប្រយោជន៍ពីទីផ្សារមូលបត្រមួយនេះ។

**ចំណេះដឹងជាអប្បបរមាសំដៅដល់ការយល់ដឹងមួយចំនួនដូចជា៖**

រចនាសម្ព័ន្ធ និងដំណើរការទីផ្សារមូលបត្រនៅកម្ពុជា៖ សំដៅដល់តួអង្គនានានៅក្នុងវិស័យមូលបត្រ ដែលមានតួនាទីខុសៗគ្នា និងមានទំនាក់ទំនងជាមួយគ្នា។ តួអង្គសំខាន់ៗមួយចំនួនមានដូចខាងក្រោម ៖

- **គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក.)៖** គឺជាស្ថាប័នរដ្ឋដែលមានតួនាទីចំបងគ្រប់គ្រងវិស័យមូលបត្រទាំងមូល។
- **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)៖** ក្រុមហ៊ុនចំរុះរដ្ឋដែលមានតួនាទីផ្តល់សេវាចុះបញ្ជីក្រុមហ៊ុន សេវាជួញដូរមូលបត្រ ផាត់ទាត់ និងទូទាត់ ព្រមទាំងរក្សាទុកមូលបត្រ។
- **ក្រុមហ៊ុនមូលបត្រ៖** ក្រុមហ៊ុនដែលធ្វើអាជីវកម្មទាក់ទងនឹងមូលបត្រដូចជា ធានាទិញមូលបត្រ ជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួន ជួញដូរមូលបត្រសម្រាប់គណនីអតិថិជន និងផ្តល់ប្រឹក្សាវិនិយោគមូលបត្រ។
- **ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ៖** ធនាគារដែលទទួលស្គាល់ដោយគ.ម.ក. ក្នុងការផ្តល់សេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។
- **ក្រុមហ៊ុនបោះផ្សាយ/ចុះបញ្ជី៖** ក្រុមហ៊ុនដែលត្រូវការទុនបន្ថែមហើយបោះផ្សាយ និងចុះបញ្ជីលក់ភាគហ៊ុនរបស់ខ្លួននៅផ.ម.ក.។
- **វិនិយោគិន៖** វិនិយោគិនជារូបវន្ត ឬជាក្រុមហ៊ុន ដែលទិញ/លក់ភាគហ៊ុននៅផ.ម.ក. តាមរយៈក្រុមហ៊ុនមូលបត្រ។
- **លក្ខណៈនៃផ្សារមូលបត្រកម្ពុជា៖** មានច្បាប់ និងបទប្បញ្ញត្តិជាច្រើនដែលបង្កើតឡើងសម្រាប់ការគ្រប់គ្រង និងដំណើរការនៃវិស័យមូលបត្រនៅកម្ពុជា។ វិនិយោគិនគួរចំណាយ

ពេលស្វែងយល់តែបទប្បញ្ញត្តិណាដែលពាក់ព័ន្ធនឹងការវិនិយោគ ដូចជា របៀបដំណើរការទីផ្សារ ម៉ោងបើកនិងបិទផ្សារ លក្ខណៈនៃការជួញដូរ ទង្វើហាមឃាត់ក្នុងការជួញដូរ ។ល។ ដើម្បីទទួលបាននូវចំណេះដឹងទាំងនេះ វិនិយោគិនក៏អាចទៅពិគ្រោះជាមួយក្រុមហ៊ុនមូលបត្រណាមួយដែលខ្លួនជ្រើសរើសផងដែរ។

- **គោលការណ៍គ្រឹះមួយចំនួននៃសេដ្ឋកិច្ច និងដំណើរការអាជីវកម្ម៖** ការទិញភាគហ៊ុននៃក្រុមហ៊ុនចុះបញ្ជីមួយគឺដូចគ្នាទៅនឹងការចូលហ៊ុនធ្វើអាជីវកម្មទូទៅដែរ។ ដូច្នេះ ក្នុងនាមជាម្ចាស់ភាគហ៊ុនម្នាក់ (បើទោះបីជាមិនបានគ្រប់គ្រងអាជីវកម្មនោះដោយផ្ទាល់ក៏ដោយ) វិនិយោគិនគួរមានចំណេះដឹង ឬបទពិសោធន៍ខ្លះទាក់ទងនឹងការគ្រប់គ្រង ឬដំណើរការអាជីវកម្មទូទៅ ស្គាល់អំពីមូលដ្ឋានគ្រឹះនៃគណនេយ្យ ព្រមទាំងគោលការណ៍គ្រឹះមួយចំនួននៃសេដ្ឋកិច្ច ដូចជាទំនាក់ទំនងរវាងតម្រូវការ ផ្គត់ផ្គង់ និងថ្លៃ ជាដើម។
- **ស្គាល់ចរិតលក្ខណៈរបស់ទីផ្សារភាគហ៊ុន៖** វិនិយោគិនគួរស្វែងយល់អំពីប្រវត្តិឡើងចុះនៃផ្សារហ៊ុន អំពីចរិតលក្ខណៈរបស់ផ្សារហ៊ុនដែលអាចមានការប្រែប្រួលខ្លាំងនិងរហ័ស អំពីកត្តាផ្សេងៗដែលអាចធ្វើឱ្យផ្សារនេះប្រែប្រួលខ្លាំង (volatile) ជាដើម។
- **ស្គាល់ខ្លួនឯង៖** សំដៅដល់ការដឹង និងត្រៀមធនធានដែលខ្លួនមាន ព្រមទាំងស្គាល់បុគ្គលិកលក្ខណៈរបស់ខ្លួនឯង (style) មុននឹងចូលប្រឡូកក្នុងការវិនិយោគ។ ដូច្នេះ វិនិយោគិនគួរ៖
    - វិនិយោគតែជាមួយលុយដែលខ្លួនឯងអាចទទួលយកការខាតបង់បាន។ លុយនោះទៀតសោត គួរតែជាលុយដែលអាចកប់ទុកក្នុងការវិនិយោគរយៈពេលវែង (អប្បបរមាបីឆ្នាំ ឬយកល្អប្រាំឆ្នាំឡើង)។
    - ត្រៀមពេលវេលាមួយចំនួន (ក្នុងមួយសប្តាហ៍) ដើម្បីសិក្សាឬតាមដានព័ត៌មានអំពីក្រុមហ៊ុនដែលខ្លួនចង់វិនិយោគជាមុន ព្រមទាំងព័ត៌មានដទៃទៀត ដែលអាចប៉ះពាល់ដល់ក្រុមហ៊ុន និងភាគហ៊ុននោះ។
    - ស្គាល់ពីភាពរហ័សរហួនក្នុងការសម្រេចចិត្ត និងសមត្ថភាពកេងចំណេញពីបម្រែបម្រួលថ្លៃភាគហ៊ុនរបស់ខ្លួន ប្រសិនបើវិនិយោគិននោះមិនមានបំណងធ្វើជាម្ចាស់ក្រុមហ៊ុនចុះបញ្ជីណាមួយយូរអង្វែង ។ល។ ដើម្បីអាចទទួលបានចំណេះដឹងទាំងនេះ និងកាន់តែពេញលេញ វិនិយោគិនគួរអានឱ្យបានច្រើន ពិគ្រោះជាមួយអ្នកមានបទពិសោធន៍ក្នុងវិស័យនេះ ហើយនិងត្រូវការពេលវេលាសមស្របមួយទម្រាំមាន

មូលដ្ឋានចំណេះដឹងមួយសមល្មម មុននឹងអាចចូលប្រឡូកក្នុងការវិនិយោគភាគហ៊ុនប្រកបដោយទំនុកចិត្ត។

## ៤.២. ដំណើរការប្រតិបត្តិការជួញដូរមូលបត្រ

### ៤.២.១. ការជ្រើសរើសក្រុមហ៊ុនចុះបញ្ជី

នៅពេលសម្រេចចិត្តត្រៀមថវិកា និងពេលវេលាមួយចំនួន ដើម្បីចូលវិនិយោគនៅផ្សារហ៊ុនរួចហើយ វិនិយោគិនគួរចាប់ផ្តើមរកមើលក្រុមហ៊ុនចុះបញ្ជីណា ដែលទំនងជានឹងរកបានប្រាក់ចំណេញច្រើននាពេលអនាគត។ ជាចម្បងតាមុននឹងសម្រេចចិត្តចូលវិនិយោគជាមួយនឹងក្រុមហ៊ុនណាមួយ យើងត្រូវការស្គាល់ក្រុមហ៊ុននោះឱ្យបានច្បាស់ (ទៅតាមលទ្ធភាព) ជាមុនសិន។

#### ៤.២.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រដែលកំពុងដំណើរការបច្ចុប្បន្ន និងជាសមាជិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានចំនួនដប់ (បញ្ជីឈ្មោះក្រុមហ៊ុនមូលបត្រមាននៅក្នុងគេហទំព័ររបស់ផ.ម.ក. (http://www.csx.com.kh)។ ដូច្នេះ វិនិយោគិនអាចបើកគណនីជួញដូរអតិបរមាចំនួនដប់។ ប៉ុន្តែវិនិយោគិនមិនគួរបើកគណនីជួញដូរច្រើនដូច្នោះទេ។ វិនិយោគិនគួរជ្រើសរើសក្រុមហ៊ុនមូលបត្រមួយ ពីរ ឬបី ទៅតាមតម្រូវការផ្ទាល់ខ្លួន ដោយផ្អែកលើគុណភាពសេវាកម្ម ចំនួនសេវាកម្ម និងកម្រៃសេវា ជាដើម។

#### ៤.២.១.២. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ( Investor ID )

នៅពេលជ្រើសរើសក្រុមហ៊ុនមូលបត្រ ដែលជាភ្នាក់ងារបម្រើសេវាកម្មក្នុងវិស័យមូលបត្ររួចហើយ វិនិយោគិនត្រូវអញ្ជើញទៅដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. ឬដាក់ពាក្យស្នើសុំដោយផ្ទាល់នៅ គ.ម.ក.។ ដំណើរការនៃការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន និងឯកសារភ្ជាប់មានដូចខាងក្រោម[20] ៖

**សម្រាប់វិនិយោគិនជារូបវន្តបុគ្គល**

វិនិយោគិនជារូបវន្តបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគ ត្រូវ:

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ក) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x៦ មួយសន្លឹក។
- ភ្ជាប់មកជានូវឯកសារដូចខាងក្រោម:

[20] គណៈកម្មការមូលបត្រកម្ពុជា, គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, ភ្នំពេញ ២០១២, ទំព័រទី១

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ)។
- លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ)។
- ប្រវត្តិរូបសង្ខេបដោយមានពត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

**សម្រាប់វិនិយោគិនជានីតិបុគ្គល**

វិនិយោគិនជានីតិបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវៈ

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ខ) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x៦ មួយសន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងមាននីតិបុគ្គល។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាបណ្ណធ្វើអាជីវកម្ម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។
  - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ប្រសិនបើមាន)។
  - ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណបណ្ណ (សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ) ថតចម្លងមានបញ្ជាក់ត្រឹមត្រូវរបស់អភិបាលនីមួយៗ។
  - លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានពត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
  - បញ្ជីឈ្មោះអ្នកដែលមានសិទ្ធិ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ។

| **ឯកសារតម្រូវសម្រាប់ស្នើសុំលេខអត្តសញ្ញាណវិនិយោគ** | |
|---|---|
| **រូបវន្តបុគ្គល (Individual)** | **នីតិបុគ្គល (Institute)** |
| - ID card (Cambodian only) / Passport | - Business registration certificate |
| - Picture 4x6 (2) | - ID Card/Passport (representative person) and Board director |
| - Passbook | - Picture 4x6 (representative person) |
| - Fee 20,000KHR/Exp: 10 years (Investor ID) | - Authorize letter |

| | |
|---|---|
| | - CV of Board director and representative person |
| | - Board meeting |
| | - Passbook |
| | - Fee 50,000 KHR |

### ៣.២.១.៣. ការបើកគណនីជួញដូរ (Open a Trade Account)

នៅពេលរកឃើញក្រុមហ៊ុនចុះបញ្ជីល្អ តម្លៃសមរម្យ និងចង់វិនិយោគជាមួយហើយ វិនិយោគិនដែលចង់ជួញដូរភាគហ៊ុននៃក្រុមហ៊ុននោះនៅផ្សារហ៊ុន ត្រូវចាប់ផ្តើមដោយការបើកគណនីជួញដូរជាមុនសិន។ វិនិយោគិនត្រូវមានគណនីមូលបត្រ ដោយសារបច្ចុប្បន្នមូលបត្រភាគហ៊ុន ឬមូលបត្រប្រភេទដទៃទៀត លែងមានទម្រង់ជាវិញ្ញាបនបត្រទៀតហើយ។ មូលបត្រទាំងនេះត្រូវបានបំប្លែងជាតួលេខកត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រ ដូចការបំប្លែងក្រដាសប្រាក់ទៅជាតួលេខកត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័ររបស់ធនាគារដូច្នោះដែរ។ វិនិយោគិនអាចបើកគណនីជួញដូរបានតែមួយប៉ុណ្ណោះនៅក្រុមហ៊ុនមូលបត្រមួយ។ ក្រុមហ៊ុនមូលបត្រដែលកំពុងដំណើរការបច្ចុប្បន្ន និងជាសមាជិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានចំនួន ១០ (បញ្ជីឈ្មោះក្រុមហ៊ុនមូលបត្រមាននៅក្នុងគេហទំព័រ ផ.ម.ក. *(http:/www.csx.com.kh)*) ។ ដូច្នេះ វិនិយោគិនអាចបើកគណនីជួញដូរអតិបរមាចំនួនដប់ ប៉ុន្តែវិនិយោគិនមិនគួរបើកគណនីជួញដូរច្រើនដូច្នោះទេ។ វិនិយោគិនគួរជ្រើសរើសក្រុមហ៊ុនមូលបត្រមួយ ពីរ ឬបី ទៅតាមតម្រូវការផ្ទាល់ខ្លួន ដោយផ្អែកលើគុណភាពសេវាកម្ម ចំនួនសេវាកម្ម និងកម្រៃសេវា ជាដើម។

### ៤.២.១.៤. ការបើកគណនីសាច់ប្រាក់ (Open a Cash Account)

ចំណែកឯគណនីសាច់ប្រាក់វិញ (នៅពេលបើកគណនីជួញដូររួចហើយ) វិនិយោគិនអាចយកសាច់ប្រាក់ទៅបញ្ចូលក្នុងគណនីនោះតែម្តង ឬអាចផ្ទេរពីគណនីសាច់ប្រាក់ផ្ទាល់ខ្លួនទៅកាន់គណនីសាច់ប្រាក់សម្រាប់ការជួញដូរមូលបត្រនេះ។ នៅពេលគណនីជួញដូរមានសុពលភាពហើយ វិនិយោគិនអាចទិញ/លក់ភាគហ៊ុនរបស់ក្រុមហ៊ុន ដែលចុះបញ្ជីនៅផ.ម.ក.បាន តាមរយៈក្រុមហ៊ុនមូលបត្រដែលខ្លួនបានបើកគណនីជួញដូរនៅទីនោះ។ វិនិយោគិនអាចធ្វើការជួញដូរបានដោយធ្វើការបញ្ជាទិញ/លក់ភាគហ៊ុនណាមួយ តាមរយៈការអញ្ជើញទៅក្រុមហ៊ុនមូលបត្រនោះដោយផ្ទាល់ ឬក៏តាមរយៈទូរស័ព្ទ សារអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀតដែលផ្តល់ដោយក្រុមហ៊ុនមូលបត្រនោះ។ វិនិយោគិនគួរគិតពិចារណាទៅលើអត្ថប្រយោជន៍នៃការបើកគណនីសាច់ប្រាក់ មានន័យថា វិនិយោគិនបើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រ ដែលធ្វើការទូទាត់សាច់ប្រាក់ជាមួយនឹងធនាគារនោះ វាធ្វើអោយវិនិយោគិនងាយស្រួលក្នុងការដាក់ ឬដកសាច់ប្រាក់ដើម្បី

ទូទាត់។ ឧទាហរណ៍: វិនិយោគិនមានគណនីសាច់ប្រាក់នៅក្នុងធនគារអេស៊ីលីដា ដោយធ្វើការបើកគណនីជួញដូរមូលប្រនៅក្រុមហ៊ុនមូលបត្រកម្ពុ-ស៊ីឃ្យូរីធី (Campu Securities Plc) នោះធ្វើឱ្យវិនិយោគិនត្រូវបង់កម្រៃក្នុងការទូទាត់សាច់ប្រាក់ ពិបាកក្នុងការទំនាក់ទំនង និងខាតពេលវេលាផងដែរ។

**រូបភាពទី ៖ ការបើកគណនីសាច់ប្រាក់**

| Yuan Ta | CVS | PPS |
|---|---|---|
| Acleda | Campu | RHB |
| | | CANA |
| | | SBI |
| | | Golden Fortune |
| | | CAB |

**ប្រភព៖ វគ្គបណ្តុះបណ្តាលស្តីពីទីផ្សារមូលបត្រកម្ពុជានៅ ផ.ម.ក**

**៤.២.១.៥. ដាក់បញ្ជា**

វិនិយោគិនអាចបង្គាប់ឱ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួន (ដែលដើរតួនាទីជាអន្តរការី) ដាក់បញ្ជាទៅកាន់ ផ.ម.ក ។ វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាមានសាច់ប្រាក់យ៉ាងហោចណាសមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ឬមានបរិមាណមូលបត្រយ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់បញ្ជាលក់)។ នៅពេលបញ្ជាត្រូវបានបញ្ជូន សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កក់ទុកដោយក្រុមហ៊ុនមូលបត្រ ក្នុងគោលបំណងដើម្បីទុកទូទាត់ ឬបង្កក់ទុករហូតដល់បញ្ជានោះអស់សុពលភាព។ វិនិយោគិនបង្គាប់ឱ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួនដាក់បញ្ជាមកកាន់ ផ.ក.ម ដោយបញ្ជាក់ប្រាប់យ៉ាងហោចនូវពត៌មានសំខាន់ៗដូចខាងក្រោម៖

- ឈ្មោះមូលបត្រ
- បរិមាណ
- ថ្លៃ

- ប្រភេទនៃបញ្ជាទិញ ឬបញ្ជាលក់។

វិនិយោគិនអាចបង្គាប់ទៅក្រុមហ៊ុនមូលបត្រឱ្យដាក់បញ្ជា ដោយប្រើប្រាស់មធ្យោបាយទំនាក់ទំនងណាមួយខាងក្រោម៖

- ឯកសារជាលាយលក្ខណ៍អក្សរ
- ពាក្យសម្ដី
- សារអេឡិចត្រូនិក
- មធ្យោបាយអេឡិចត្រូនិចដទៃទៀត។

**រូបភាពទី ៖ ដំណើរការជួញដូរនៅក្នុងទីផ្សារមូលបត្រ**




១. វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្នុងហ៊ុនមូលបត្រមួយ នៅមួយថ្ងៃមុខថ្ងៃជួញដូរ។

២. វិនិយោគិនផ្ដល់សេចក្ដីបង្គាប់ឱ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រ ជាលាយលក្ខណ៍អក្សរ ពាក្យសម្ដី ឬមធ្យោបាយអេឡិចត្រូនិចនានា។

៣. ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ ផ.ម.ក. ប៉ុន្តែនឹងដាក់បញ្ជា ក្រុមហ៊ុនមូលបត្របានបង្កក់ទុករួចហើយនូវសាច់ប្រាក់ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយនៃបញ្ជានីមួយៗ។

៤. បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

៥. ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0 ។

៦. ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន (នៅ T+0)។

៧. ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1 ។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

៨. វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង គឺក្រុមហ៊ុនមូលបត្រប្រើប្រាស់ប្រាក់ ឬមូលបត្ររបស់អតិថិជន ដែលបានបង្កក់ទុកដើម្បីទូទាត់ដោយសុំ ឬមិនបាច់សុំការអនុញ្ញាតពីអតិថិជនជូនឡើយ។

៩. ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ ផ.ម.ក. ។

### ៤.២.២. វិធានប្រតិបត្តិការជួញដូរនៅលើទីផ្សារ

ការជួញដូរភាគហ៊ុនគឺជាការទិញ/លក់កម្មសិទ្ធិនៅក្នុងក្រុមហ៊ុនមួយ។ ដូច្នេះ ការស្វែងយល់អំពីគុណភាពដំណើរការអាជីវកម្ម និងការគ្រប់គ្រងក្រុមហ៊ុន ព្រមទាំងការវាយតម្លៃភាគហ៊ុន គឺជាការចាំបាច់មួយ។ ប៉ុន្តែដោយសារភាគហ៊ុនទាំងនោះត្រូវបានដាក់ឱ្យជួញដូរនៅលើទីផ្សារអេឡិចត្រូនិក ដែលមានការរៀបចំជាលក្ខណៈប្រព័ន្ធ និងមានភាពស្មុគស្មាញខ្លះនោះ វិនិយោគិនត្រូវសិក្សាស្វែងយល់អំពីការប្រព្រឹត្តទៅនៅលើទីផ្សារមូលបត្រនេះដែលវិធាន និងប្រតិបត្តិការមួយចំនួនមានសារៈសំខាន់ចំពោះវិនិយោគិន។

- **ថ្ងៃជួញដូរ**

  ថ្ងៃជួញដូរ ចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាក់ជាសាធារណៈ។

- **ម៉ោង និងវគ្គជួញដូរ**

ផ្សារហ៊ុនចាប់បើកទទួលបញ្ជាទិញ/លក់ពីវិនិយោគិនពីម៉ោង ០៨:០០ ព្រឹក និងបិទនៅម៉ោង ១១:៣០ ព្រឹក។ ប៉ុន្តែ ការជួញដូរចាប់ធ្វើឡើងពីម៉ោង ០៩:០០ ដល់ម៉ោង ១១:០០ ព្រឹក និងនៅម៉ោង ១១:៣០ ព្រឹក ម្តងទៀតមុនពេលបិទផ្សារ។

**រូបភាពទី ៖ ម៉ោង និងវគ្គជួញដូរ**




**ប្រភព: វគ្គបណ្តុះបណ្តាលស្តីពីការជួញដូរមូលបត្រកម្ពុជានៅ គ.ម.ក**

- នៅម៉ោង ៨:០០ ព្រឹក ផ្សារចាប់ផ្តើមដំណើរការ។
- ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៩:០០ ព្រឹក ការជួញដូរដេញថ្លៃដោយយកថ្លៃតែមួយ។
- ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ១១:០០ ព្រឹក ការជួញដូរដេញថ្លៃដោយយកថ្លៃច្រើន។
- ចាប់ពីម៉ោង ១១:០០ ព្រឹក ដល់ម៉ោង ១១:៣០ ការជួញដូរដេញថ្លៃដោយយកថ្លៃតែមួយម្តងទៀត។
- នៅម៉ោង ១១:០០ ព្រឹក ការជួញដូរមូលបត្របានបិទ ហើយបញ្ជាទិញ ឬលក់ដែលនៅសល់ត្រូវដាក់អនុវត្តនៅថ្ងៃស្អែកប្រសិនបើគ្មានការផ្លាស់ប្តូរ។

| វគ្គជួញដូរ | ម៉ោងបិទ/បើកវគ្គ | ចំនួនជួញដូរ | ម៉ោងជួញដូរ | វិធីសាស្ត្រជួញដូរ |
|---|---|---|---|---|
| វគ្គបើក | ០៨:០០-០៩:០០ ព្រឹក | ០១ ដង | ០៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គជួញដូរនិរន្តន៍ | ០៩:០០-១១:០០ ព្រឹក | មិនកំណត់ | ០៩:០០-១១:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១១:០០-១១:៣០ ព្រឹក | ០១ ដង | ១១:៣០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |

➢ **បញ្ជា**

នៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) បច្ចុប្បន្ន ប្រភេទនៃបញ្ជាមានតែមួយប៉ុណ្ណោះគឺ "បញ្ជាមានកំណត់" (Limit Order) ដែលមានន័យថា រាល់ថ្លៃបញ្ជាទិញដែលបានដាក់ គឺជាថ្លៃហ៊ានទិញខ្ពស់បំផុត ហើយរាល់ថ្លៃបញ្ជាលក់ គឺជាថ្លៃហ៊ានលក់ទាបបំផុត។ រាល់បញ្ជាទាំងអស់មានសុពលភាពចាប់ពីពេលទទួលបាននៅក្នុងប្រព័ន្ធជួញដូរ រហូតដល់ម៉ោងបិទផ្សារនៃថ្ងៃតែមួយ ឬរហូតដល់បញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ឧទាហរណ៍៖ បញ្ជាទិញមានកំណត់មួយដែលមានថ្លៃ ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ ៥០,០០០រៀល ឬថោកជាងនេះ ហើយចំណែកឯបញ្ជាលក់មានកំណត់ដែលមានថ្លៃ ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ ៥០,០០០រៀល ឬខ្ពស់ជាងនេះ។

➢ **ការដេញថ្លៃ**

ការជួញដូរត្រូវធ្វើឡើងដោយផ្អែកលើវិធីសាស្ត្រ ដេញថ្លៃដោយយកថ្លៃតែមួយ និងដេញថ្លៃដោយយកថ្លៃច្រើន ។

❖ ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

គោលការណ៍៖

១. បញ្ជាទាំងអស់ត្រូវជួញដូរនៅថ្លៃតែមួយ និងត្រូវរងចាំដល់ម៉ោងជួញដូរ

២. ថ្លៃផ្គូផ្គងជាថ្លៃដែលអាចផ្គូផ្គងនៅបរិមាណច្រើនបំផុត

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❶ ~~700~~ 100 |
| ❷ ~~200~~ | 10,300 | |
| ❸ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ០៩:០០ ឬ ១១:៣០)÷
600 x 10,400 ៛ = 6,240,000 ៛

❖ ឧទាហរណ៍៖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

គោលការណ៍៖

១. បញ្ជានីមួយៗអាចជួញដូរនៅថ្លៃច្រើនខុសៗគ្នា និងជួញដូរបានភ្លាមៗនៅពេលដែលមានបញ្ជាត្រូវគ្នា។

២. នៅពេលបញ្ជាទិញនិងលក់ត្រូវគ្នា ថ្លៃផ្គូផ្គងត្រូវជ្រើសយកថ្លៃរបស់បញ្ជាដែលទទួលបានមុន។

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❸ ~~700~~ 100 |
| ❷ ~~200~~ | 10,300 | |
| ❸ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ម៉ោងជួញដូរ(09:00-11:00 ព្រឹក)
1. 200 x 10,300 ៛ = 2,060,000 ៛(ភ្លាមៗ)
2. 300 x 10,400 ៛ = 3,120,000 ៛(ភ្លាមៗ)
3. 100 x 10,400 ៛ = 1,040,000 ៛(ភ្លាមៗ)
6,220,000 ៛

ការផ្គូផ្គងដោយផ្អែកលើវិធីសាស្ត្រទាំងពីរត្រូវគោរពតាមអាទិភាពៈ

- **ថ្លៃ**

- បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។
- បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។

- **ពេលវេលា**

- ប្រសិនបើថ្លៃនៃបញ្ជាទិញ/លក់ស្មើគ្នា នោះបញ្ជាដែលបញ្ជូនមកប្រព័ន្ធជួញដូរ ផ.ម.ក. មុននឹងមានអាទិភាពមុន។

**ឧទាហរណ៍**

❋ អាទិភាពថ្លៃ (❶) ❋ អាទិភាពពេលវេលា (❷ , ❸)

| **លក់** | | **ថ្លៃ** | **ទិញ** | |
|---|---|---|---|---|
| | | ៦,២៦០ | ❶ ២០ (ថ្លៃទិញខ្ពស់បំផុត) | |
| | | ៦,២៤០ | ❷ ២០០ | ❸ ៣០០ |
| | | ៦,២២០ | | |
| | | ៦,២០០ | | |
| ៨០ ❸ | ១០០ ❷ | ៦,១៨០ | | |
| (ថ្លៃលក់ទាបបំផុត) ២០ ❶ | | ៦,១៦០ | | |

➢ **ថ្លៃមូលដ្ឋាន**

ជាទូទៅ ថ្លៃមូលដ្ឋានគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។ ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ ៩០% និង ១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃ IPO ដែលបានកំណត់នៅក្នុងឯកសារផ្តល់ពត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក)។

| **បញ្ជាលក់** | **ថ្លៃ** | **បញ្ជាទិញ** |
|---|---|---|
| ដែនកំណត់ខាងលើ (១៥០%) | ១៥,០០០ | |
| | : | |
| | ១២,៦០០ | ដែនកំណត់ខាងលើ (+៥%) |
| | ១២,០០០ | ថ្លៃមូលដ្ឋាន |
| | : | |
| | ១១,៤០០ | ដែនកំណត់ខាងក្រោម (-៥%) |

| | | |
|---|---|---|
| | : | |
| ថ្លៃ IPO | ១០,០០០ | |
| ដែនកំណត់ខាងក្រោម (៩០%) | ៩,០០០ | |
| | **សរុប** | |

➢ **បម្រែបម្រួលថ្លៃប្រចាំថ្ងៃ**

ដើម្បីការពារមិនឱ្យថ្លៃប្រែប្រួលខ្លាំងពេកក្នុងមួយថ្ងៃៗ ថ្លៃភាគហ៊ុនត្រូវបានអនុញ្ញាតឱ្យប្រែប្រួលតែក្នុងចន្លោះប្រាំភាគរយ (±៥%) ប៉ុណ្ណោះក្នុងមួយថ្ងៃ (ធៀបនឹងថ្លៃមូលដ្ឋាន ដែលជាទូទៅគឺជាថ្លៃបិទពីម្សិលមិញ) លើកលែងតែការជួញដូរនៅថ្ងៃដំបូងនៃក្រុមហ៊ុនដែលទើបនឹងចុះបញ្ជីនៅផ្សារហ៊ុន ដែលត្រូវបានអនុញ្ញាតឱ្យថ្លៃប្រែប្រួលនៅវគ្គជួញដូរដំបូង ចន្លោះពី ៩០% ទៅ ១៥០% នៃថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង (ឬហៅថា ថ្លៃ IPO)។

| **លក់** | **ថ្លៃ** | **ទិញ** |
|---|---|---|
| ○ ○ | ៦,៣០០ | ដែនខាងលើ (+៥) |
| | | ○ ○ |
| ○ ○ | : | ○ |
| ○ ○ ○ | | ○ ○ ○ |
| | ៦,០០០ | ថ្លៃមូលដ្ឋាន |
| ○ ○ ○ | | ○ |
| | : | |
| ○ | | ○ ○ ○ ○ |
| | ៥,៧០០ | ដែនខាងក្រោម (-៥) |

➢ **ឯកតាជួញដូរ**

ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅ ផ.ម.ក គឺ ០១ (មួយ) ឯកតាមូលបត្រ។

➢ **ឯកតាថ្លៃ (ឯកតាគម្លាតថ្លៃ)**

ថ្លៃប្រែប្រួលទៅតាមឯកតាថ្លៃ (ឯកតាគម្លាតថ្លៃ) ដែលត្រូវបានកំណត់ដូចខាងក្រោម៖

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាខុស | ឧទាហរណ៍ថ្លៃបញ្ជាត្រឹមត្រូវ |
|---|---|---|---|
| P<4,000 | 10 | 2,555; 3,012; 3,999 | 2,550; 2,560; 3,020; 3,990 |
| 4,000≤P<20,000 | 20 | 4,210; 19,525 | 4,200; 4,220; 19,520; 19,540 |
| 20,000≤P <40,000 | 50 | 20,110; 35,530 | 20,100; 20,150; 35,500; 35,550 |
| 40,000≤P <100,000 | 100 | 50,720; 90,450 | 50,700; 50,800; 90,400; 90,500 |
| 100,000≤P <200,000 | 200 | 150,500; 125,300 | 150,400; 150,600; 125,200; 125,400 |

| | | | |
|---|---|---|---|
| 200,000≤ P<400,000 | 500 | 300,100; 350,200 | 300,000; 300,500; 350,000; 350,500 |
| P ≥400,000 | 1,000 | 620,500; 852,100 | 620,000; 621,000; 811,000; 853,000 |

➢ **កាលបរិច្ឆេទទូទាត់**

ការទូទាត់ក្នុងការជួញដូរមូលបត្រ ខុសពីផ្សារទូទៅធម្មតា ដែលអ្នកទិញ និងអ្នកលក់ជួបមុខគ្នា និងធ្វើការទូទាត់ជាមួយគ្នាភ្លាមៗនៅនឹងកន្លែង ការទូទាត់នៅផ្សារមូលបត្រត្រូវធ្វើឡើងនៅពីរថ្ងៃ (T+2) ក្រោយថ្ងៃជួញដូរ (T+0)។




## ៤.២.៣. ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន និងបច្ចេកទេស

ការវិនិយោគលើមូលបត្រ (ភាគហ៊ុន) គួរធ្វើការស្វែងរកពត៌មាន ពិចារណា និងធ្វើការវិភាគទៅលើកត្តាពី គឺការវិភាគផ្អែកលើកត្តាមូលដ្ឋាន (Fundamental Analysis) និងការវិភាគផ្អែកលើកត្តាបច្ចេកទេស (Technical Analysis)។ ការវិភាគផ្អែកលើកត្តាមូលដ្ឋាន និងការវិភាគផ្អែកលើកត្តាបច្ចេកទេស សម្តៅដល់វិធីសាស្ត្រ ដែលត្រូវបានប្រើសម្រាប់ការសិក្សាស្រាវជ្រាវ និងស្ទង់ប្រមាណមើលអំពីទំនោរកើន បម្រែបម្រួលនៃមូលបត្រ (ភាគហ៊ុន) ដើម្បីធ្វើការជួញដូរ និងវិនិយោគ។ មានលំនាំនឹងផែនការយុទ្ធសាស្ត្រ ឬទស្សនៈនៃការវិនិយោគនានា ដែលការវិភាគទាំងពីរមានគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្លួន។ អ្នកវិនិយោគនឹងទទួលបានចំណេះដឹងបន្ថែមលើរបៀប និងគំនិតពាក់ព័ន្ធនឹងការវិភាគលើមូលបត្រ និងមានលទ្ធភាពក្នុងការប្រើប្រាស់នាពេលខាងមុខលើវិស័យគោលដៅសម្រាប់ការវិនិយោគ ដោយការជឿជាក់ មិនប្រឈមនឹងការខាត់ទាំងស្រុង។

#### ៤.២.៣.១. ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន

ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន (ការវិភាគមូលដ្ឋាន) គឺជាវិធីសាស្ត្រមួយនៃការស៊ើបអង្កេតយ៉ាងយកចិត្តទុកដាក់ (Rigorous Investigation) លើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ[21]។ ហើយក៏ជាវិធីសាស្ត្រដ៏សំខាន់មួយនៃការវិនិយោគសម្រាប់វិនិយោគិនក្នុងការវិនិយោគមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា។ ការវិភាគដោយផ្អែកលើកត្តាមូលដ្ឋាន គឺជាបច្ចេកតទេសមួយដើម្បីកំណត់សុវត្ថិភាពតម្លៃ ដោយផ្តោតលើកត្តាដែលប៉ះពាល់ដល់អាជីវកម្មរបស់ក្រុមហ៊ុននាពេលបច្ចុប្បន្ន និងពេលអនាគត។ ហើយក៏ជាវិធីសាស្ត្រនៃការវាយតម្លៃលើសុវត្ថិភាព ដែលតម្រូវឱ្យមានការកំណត់តម្លៃមូលបត្រដោយពិនិត្យលើកត្តាដូចជា ៖

#### ក. កត្តាសេដ្ឋកិច្ច

កំណើនផលិតផលក្នុងស្រុកសរុប (GDP) នៅក្នុងប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថាមានចំនួន ៧% នៅក្នុងឆ្នាំ ២០១៦ និង ៧,១% សម្រាប់ឆ្នាំ ២០១៧[22] ។ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាបានកើនឡើង ៩,៤% នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១៦ ដែលកំណើននេះមានចំនួនសឹងនឹងទ្វេដងបើធៀបនឹងឆ្នាំ ២០១៥។ ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា រហូតមកដល់ឆ្នាំ ២០១៦ នេះ បានបង្ហាញលទ្ធផលដូចការរំពឹងទុក។ ការនាំចេញពីឧស្សាហកម្មកាត់ដេរ និងស្បែកជើងបានកើនឡើង ៩,៤% នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១៦ ដែលកំណើននេះមានចំនួនសឹងនឹងទ្វេដងបើធៀបនឹងឆ្នាំ ២០១៥ ។ ចំណែកឯចំនួនភ្ញៀវទេសចរដែលបានមកទស្សនាប្រទេសកម្ពុជាវិញមានកំណើន ៤,៩៥ កាលពីឆ្នាំ ២០១៥។ ស្ថានភាពអាកាសធាតុល្អប្រសើរឡើងវិញចាប់ពីខែមិថុនា ឆ្នាំ ២០១៦ បន្ទាប់ពីមានគ្រោះរាំងស្ងួតបានធ្វើឱ្យវិស័យកសិកម្មចាប់ផ្តើមងើបឡើងវិញ។ ដូចនេះវិនិយោគិនគួរសិក្សា ពិចារណាថា តើក្រុមហ៊ុនបោះផ្សាយលក់មូលបត្រណាមួយ ដែលមានទំនោរទៅរកភាពរីកចម្រើន និងភាពរឹងមាំ នាពេលសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគតមានការរីកចម្រើនទៅមុខជាបន្តបន្ទាប់នោះ ដែលអាចឱ្យវិនិយោគិន វិនិយោគលើមូលបត្រទាំងនោះទទួលបានប្រាក់ចំណេញ និងទទួលបានភាគលាភនៅពេលក្រុមហ៊ុនរកស៊ីចំណេញ និងមិនមានហានិភ័យ។

[21] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ,ភ្នំពេញ ២០១១ ទំព័រ ៨៧
[22] ធនាគារអភិវឌ្ឍន៍អាស៊ី




- សូចនករសេដ្ឋកិច្ច (Economic Indicators)

ជំហានដំបូងនៃការវិភាគម្ភូលដ្ឋានរួមមានការពិនិត្យមើលស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដែលស្ថានភាពទាំងនោះរួមមាន ៖

- វដ្តនៃអាជីវកម្ម (អត្រាកំណើន)
- អត្រាការប្រាក់
- ការផ្គត់ផ្គង់ប្រាក់
- សន្ទស្សន៍ថ្លៃ (អតិផរណា)
- វត្ថុធាតុដើមអន្តរជាតិ
- អ្នកវិនិយោគបរទេស
- តុល្យភាពនៃការទូទាត់
- ផ្សេងៗទៀត (GDP … )



- សូចនាករសេដ្ឋកិច្ចនិងផលប៉ះពាល់របស់ពួកគេទៅលើទីផ្សារភាគហ៊ុន

| INDICATOR | Favourable Impact | Unfavourable Impact |
|---|---|---|
| GDP/Growth Rate | HIGH Growth Rate | SLOW Growth Rate |
| Domestic Savings Rate | High | Low |
| Interest Rate | Low | High |
| Tax Rates | Low | High |
| Inflation | Low | High |
| Industrial Production | High | Low |
| Balance of Trade | Positive | Negative |
| Balance of Payments | Positive | Negative |
| Foreign Exchange Position | High | Low |
| Deficit Financing | Low | High |
| Agricultural Production | High | Low |
| Infrastructural Facilities | Good | Not Good |

**ខ. កត្តាអាជីវកម្ម**

វិនិយោគិនគួរតែសិក្សាស្វែងយល់នូវក្រុមហ៊ុន ដែលខ្លួនចង់វិនិយោគថាតើ ក្រុមហ៊ុននោះមានដំណើរការគ្រប់គ្រងយ៉ាងដូចម្តេច? ៖

- ព័ត៌មានអំពីអាជីវកម្មចម្បងៗរបស់ក្រុមហ៊ុន។
- ប្រវត្តិនៃការវិវត្តរបស់ក្រុមហ៊ុន។
- ផែនការ និងយុទ្ធសាស្ត្រអាជីវកម្មរបស់ក្រុមហ៊ុន។
- ប្រវត្តិ និងសមត្ថភាពរបស់ស្ថាបនិក និងថ្នាក់ដឹកនាំសំខាន់ៗរបស់ក្រុមហ៊ុន។
- នយោបាយគ្រប់គ្រងបុគ្គលិក (និងទំនាក់ទំនងជាមួយសហជីព)។
- ប្រាក់បៀវត្ស និងប្រាក់លើកទឹកចិត្តផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន។
- នយោបាយបែងចែកភាគលាភដល់ភាគហ៊ុនិក។
- កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនមានប្រជាប្រិយភាពយ៉ាង ។ល។

### គ. ភក្តារបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគមូលដ្ឋាន ជាដំណើរការនៃការពិនិត្យសិក្សាលើរបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនមួយ ដើម្បីអាចសម្រេចបានសមស្របក្នុងការវិនិយោគ ឬទិញ-លក់មូលបត្រ (ភាគហ៊ុន)។ តាមរយៈ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលរួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល និង របាយការណ៍លំហូរសាច់ប្រាក់ វិនិយោគិនគួរពិនិត្យមើល និងគណនារកព័ត៌មានមួយចំនួនដូចជា ៖

- **តារាងតុល្យការ** (Balance Sheet): ជាជំនួយលើការពិនិត្យមើលពីដំណើរការក្រុមហ៊ុនមួយក្នុងការបង្កើនសាច់ប្រាក់សម្រាប់ទ្រព្យសកម្ម។ វាអាចជួយកំណត់អំពីទំហំ ឬវិសាលភាពរបស់ក្រុមហ៊ុននោះ។

| | | | | |
|---|---|---|---|---|
| ទ្រព្យសកម្ម | = | បំណុល | + | មូលធន |

- **របាយការណ៍លទ្ធផល (ចំណេញ-ខាត)** (Income Statement): ជារបាយការណ៍ដែលអាចអោយដឹងពីចំណូលរបស់ក្រុមហ៊ុន ដែលក្នុងនោះមានចំណូលដុល និងចំណាយ (ប្រតិបត្តិការ ការប្រាក់ បង់ពន្ធ -ល-)។

| | | | | |
|---|---|---|---|---|
| ចំណេញ | = | ចំណូល | - | ចំណាយ |

- **ការចាត់ចែងប្រាក់ចំណេញ** (Handle the Earnings): ចំណូលសុទ្ធ (ក្រោយបង់ពន្ធ) ជាចំណេញរបស់ក្រុមហ៊ុន និងជាទូទៅត្រូវបានចាត់ចែង:
    - ជាភាគលាភជូនភាគទុនិកតាមអត្រាជាក់លាក់ណាមួយ។
    - និងវិនិយោគទៅក្នុងក្រុមហ៊ុនវិញ ដើម្បីអោយស្ថានភាពសាច់ប្រាក់កាន់តែប្រសើរសម្រាប់ប្រតិបត្តិការ។
- **របាយការណ៍លំហូរសាច់ប្រាក់** (Cash Flow Statement): គេតែងនិយាយថា ប្រាក់គឺជាស្តេច ហេតុនេះបានជារបាយករណ៍នេះមានសារៈសំខាន់ ដែលមានបង្ហាញពីការប្រើប្រាស់សាច់ប្រាក់សម្រាប់ប្រតិបត្តិការ វិនិយោគ និងកម្ចី។ លំហូរទាំងនេះនឹងមានការប្រែប្រួលស្ថានភាពសាច់ប្រាក់។ របាយការណ៍នេះមានបញ្ជាក់ពីគណនីលម្អិត លើប្រភពចំណូល ហេតុនេះវាជាការលំបាក ករណីមានចេតនាបញ្ឆោតបន្លំលើរបាយការណ៍ចំណូល។

- **អនុបាត (Ratios):** ពត៌មានមានជាច្រើនក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហេតុនេះវិនិយោគិនអាចប្រើប្រាស់អនុបាតមួយចំនួន ដែលអាចជាជំនួយក្នុងការប្រៀបធៀបតម្លៃភាគហ៊ុននានា។

អនុបាត Ratio: - P/E: Price/Earnings

| | |
|---|---|
| - Price/Book Value | - Return on Invested Capital |
| - Debt/Equity | - Earnings Per Share |
| - Return on Equity | - Return on Net Worth |
| - Current Ratio | - Return on Total Assets |
| - Net Profit Margin | - Return on Equity |

- **អនុបាត ថ្លៃ/ចំណូល: ថ្លៃធៀបនឹងចំណូល (P/E: Price to Earnings):** អនុបាតដែលនិយមប្រើក្នុងចំណោមអនុបាតដទៃទៀតគឺ ផលធៀបថ្លៃធៀបទៅនឹងចំណូល។ វាត្រូវបានប្រើបញ្ជាក់ពីបំណងដែលវិនិយោគិនចំណាយទិញមូលបត្រ (ភាគហ៊ុន) ធៀបនឹងចំណូលរបស់ក្រុមហ៊ុន។
- **ភាពចំណេញរបស់ក្រុមហ៊ុន (Profitability):** ប្រាក់ចំណេញធៀបនឹងចំណូលដែលរកបាន (Profit Margin) ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មដែលបានប្រើ (Return on Asset) ប្រាក់ចំណេញធៀបនឹងមូលធនភាគហ៊ុនិក (Return on Equity) ។ល។
- **សុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន:** កម្រិតបំណុលធៀបនឹងមូលធនភាគហ៊ុនិក (Debt/Equity) ប្រាក់ចំណេញមុនបង់ការប្រាក់ និងពន្ធធៀបនឹងការប្រាក់ (Interest Coverage) កម្រិតនៃទុនបង្វិល (Working Capital) ។ល។
- **ប្រសិទ្ធិភាពក្នុងការប្រើប្រាស់ធនធាន:** ចំណូលរកបានធៀបនឹងទ្រព្យសកម្មដែលបានប្រើ (Asset Turnover) ថ្លៃដើមលក់ធៀបនឹងទំហំស្តុក(Inventory Turnover) ប្រាក់ចំណូលធៀបនឹងប្រាក់ដែលអតិថិជនជំពាក់(Account Receivable Turnover) ។ល។

ព័ត៌មានទាំងឡាយខាងលើ និងព័ត៌មានផ្សេងទៀតដែលទទួលបាន វិនិយោគិនមិនគួរយកមកពិចារណាតែឯកឯងនោះទេ។ វិនិយោគិនគួរយកព័ត៌មានទាំងនេះទៅប្រៀបធៀបជាមួយនឹងព័ត៌មានដូចគ្នា (ឬប្រហាក់ប្រហែលគ្នា) របស់ក្រុមហ៊ុនប្រកួតប្រជែងផ្សេងៗ (បើមាន) ឬទៅប្រៀបធៀបជាមួយនឹងព័ត៌មានដដែលនៃឆ្នាំមុនៗរបស់ក្រុមហ៊ុននោះ ដើម្បីអាចវាយតម្លៃឱ្យកាន់តែប្រសើរអំពីគុណភាពអាជីវកម្មរបស់ក្រុមហ៊ុន។ ក្រៅពីព័ត៌មានទាំងនេះ វិនិយោគិនគួរស្វែងយល់និងវាយតម្លៃពីកម្រិតហានិភ័យផ្សេងៗរបស់ក្រុមហ៊ុន។ ហានិភ័យនេះសំដៅដល់លទ្ធភាពដែលហេតុការណ៍ផ្សេងៗអាចកើតមាន ហើយផ្តល់ផលអវិជ្ជមានដល់គុណភាពក្រុមហ៊ុន។ ហានិភ័យ

ទាំងនេះអាចមានដូចជា៖ ហានិភ័យនៃការធ្លាក់ចុះប្រាក់ចំណូលដោយសារផលិតផលរបស់គូប្រជែងល្អជាង ឬទំនើបជាង ហានិភ័យនៃការបន្លំរបាយការណ៍ពីថ្នាក់ដឹកនាំក្រុមហ៊ុន ហានិភ័យនៃការខូចខាតទំនិញដោយសារទឹកជំនន់ ឬភ្លើងឆេះជាដើម។ ចំពោះក្រុមហ៊ុនដែលចុះបញ្ជីជាសាធារណៈ វិនិយោគិនពុំមានការលំបាកក្នុងការទទួលបានព័ត៌មានទាំងអស់នេះឡើយ។ វាមាននៅក្នុងឯកសារ ផ្តល់ព័ត៌មាន របាយការណ៍ប្រចាំឆ្នាំ និងឯកសារផ្សេងទៀត ដែលក្រុមហ៊ុនបានផ្សព្វផ្សាយជា សាធារណៈ តាមរយៈគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (www.csx.com.kh) គេហទំព័ររបស់ក្រុមហ៊ុនចុះបញ្ជីនោះផ្ទាល់តែម្តង ឬគេហទំព័រដទៃទៀត។

### ៤.២.៣.២. ការវិភាគដោយផ្អែកលើកត្តាបច្ចេកទេស

ការវិភាគដោយផ្អែកលើកត្តាបច្ចេកទេស (ការវិភាគបច្ចេកទេស) គឺជាការសិក្សាពីប្រវត្តិថ្លៃដើម្បីព្យាករណ៍ថ្លៃហ៊ុននាពេលអនាគត។ ជាទូទៅគេប្រើ Chart ក្នុងការមើលពីលំនាំប្រវត្តិថ្លៃ ដើម្បីព្យាករណ៍ថ្លៃពេលខាងមុខ។ អ្នកវិភាគជឿថាថ្លៃក្នុងទីផ្សារ ជាពត៌មានទាន់ពេល និងមានប្រយោជន៍។ អ្នកវិភាគបច្ចេកទេសផ្តោតលើបម្រែបម្រួលថ្លៃ និងវិភាគលើទិន្នន័យស្ថិតិដែលបានមកពីសកម្មភាពទីផ្សារដូចជា ៖

- ថ្លៃអតីតកាល និងទំហំជួញដូរ
- ការផ្គត់ផ្គង់ និងតម្រូវការ និងការព្យាករទំនោរនាពេលខាងមុខ
- ការប្រើលំនាំគំរូក្រាហ្វិច និងសូចនាករបច្ចេកទេស និងលំយោល

#### ក. ទិន្នន័យទីផ្សារ

ប្រវត្តិថ្លៃ អាចកើតឡើងដដែលៗដោយខ្លួនឯង។ ធម្មជាតិនៃថ្លៃកើតឡើងដដែលៗនេះត្រូវបានសន្មត់ថាជាចិត្តសាស្ត្រទីផ្សារ។ ម៉្យាងទៀត អាចលើកឡើងថា អ្នកចូលរួមទីផ្សារមានទំនោរទៅរកប្រតិកម្មទីផ្សារ (មិនប្រែប្រួល) ស្រដៀងនឹងប្រតិបត្តិលើកមុខ (ជាមួយនឹងការប្រើលំនាំគំរូ Chart) ដែលមានថ្មី ឬមានយូរហើយ។ អាស្រ័យហេតុនេះហើយ ទិន្នន័យទីផ្សារដែលធ្វើការជួញដូរលើកមុខៗ អាចបង្ហាញពីលទ្ធផលនៃការជួញដូរនាពេលបច្ចុប្បន្ន ធ្វើអោយវិនិយោគិនមានទិន្នន័យក្នុងការផ្ទៀងផ្ទាត់នូវតម្លៃមូលបត្រ ដើម្បីធ្វើការវិភាគស្វែងរកផលចំណេញក្នុងការជួញដូរ។

#### ខ. និន្នាការថ្លៃ

និន្នាការនៃអ្នកធ្វើតាម គឺថានៅពេលដែលនិន្នាការមួយត្រូវបានបង្កើតឡើង វាហាក់ដូចជាបន្តទៅមុខទៀតជាជាងត្រឡប់ថយក្រោយ។ របៀបដែលអាចមើលឃើញពីដំបូង និងទីបញ្ចប់នៃនិន្នាការមួយ ប្រហែលដឹងច្បាស់ និងតាមដានយ៉ាងជិតដល់នៃនិន្នាការទាំងអស់គឺ បម្រែបម្រួលជា

មធ្យម (Moving Average)[23]។ ថ្លៃត្រូវបានគេជឿថាធ្វើចលនាតាមនិន្នាការ មានន័យថាបន្ទាប់ពីនិន្នាការមួយត្រូវបានបង្កើតឡើង ចលនាថ្លៃនាពេលអនាគតគឺទំនងជាត្រូវបានធ្វើដំណើរនៅក្នុងទិសដៅដូចគ្នានេះ ជាជាងបញ្ច្រាសទិសដៅគ្នា។ យុទ្ធសាស្ត្រជួញដូរភាគច្រើន ត្រូវបានផ្អែកលើការសន្មត់ដូចជា ៖

- ❖ **សម្គាល់ពីនិន្នាការ** (Notice of Trends)

ថ្លៃភាគហ៊ុនរបស់ក្រុមហ៊ុនមួយមានតម្លៃទាបនៅដើមឆ្នាំ និងខ្ពស់នៅចុងឆ្នាំ (X-dividend) ដោយសារតែវិនិយោគភាគច្រើនសំឡឹងមើលទៅលើគម្លាតថ្លៃ និងភាគលាភដែលនឹងទទួលបាន។ ជាទូទៅកាលណាថ្លៃកើនឡើងកាន់តែលឿនក្នុងអំឡុងរយៈពេលដ៏ខ្លីនោះ វានឹងធ្លាក់ចុះកាន់តែលឿនក្នុងរយៈពេលខ្លីដូចគ្នាដែរ។ ដើម្បីចំណេញ វិនិយោគគួរប្រើប្រាស់លុយរយៈពេលវែងសម្រាប់ការវិនិយោគ និងលុយរយៈពេលខ្លីសម្រាប់ការជួញដូរ។ ផលចំណេញគឺទទួលបានពីការចេះចាត់ចែងប្រភពលុយ និងការរៀបចំផែនការសម្រាប់វិនិយោគត្រឹមត្រូវ ដោយការផ្អែកទៅតាមនិន្នាការដែលមានស្រាប់ និងស្ថានភាពប្រែប្រួលប្រចាំថ្ងៃ ឬតាគ្រា។

- ❖ **ប្រភេទនិន្នាការថ្លៃ** (Type of Trends)

និន្នាការមិនមានភាពងាយស្រួលក្នុងការមើលឃើញនោះទេ ហេតុនេះការមើលឃើញនិន្នាការអាចឱ្យអ្នកវិនិយោគអាចស្វែងរកប្រាក់ចំណេញបាន។ និន្នាការមាន ៣ ប្រភេទគឺ ៖

- និន្នាការកើនឡើង
- និន្នាការធ្លាក់ចុះ
- និន្នាការផ្តេក

- ❖ **ថិរវេលានៃនិន្នាការថ្លៃ** (Length of Trends)

និន្នាការទាំង ៣ ប្រភេទខាងលើមាន ៣ ចំណាច់ថ្នាក់គឺ ៖

- រយៈពេលវែងគឺ ធំជាង ១ ឆ្នាំ
- រយៈពេលមធ្យមគឺ ពី ១ ខែ ដល់ ១ ឆ្នាំ
- រយៈពេលខ្លីគឺ តិចជាង ១ ខែ

- ❖ **គន្លឹះនៃនិន្នាការថ្លៃ** (The Importance of Tend)

មានសុភាសិតសំខាន់ពីរប្រើនៅក្នុងការវិភាគបច្ចេកទេសគឺ និន្នាការជាមិត្តរបស់អ្នក និងកុំទប់ស្កាត់និន្នាការ។

[23] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, ភ្នំពេញ ឆ្នាំ ២០១១ ទំព័រ ៩៥

### គ. តម្រូវការ និងការផ្គត់ផ្គង់

ការវិភាគបច្ចេកទេសគឺ វិភាគតែទៅលើចលនាថ្លៃ។ គេជឿថាកត្តាមូលដ្ឋានរបស់ក្រុមហ៊ុនរួមជាមួយកត្តាសេដ្ឋកិច្ច និងចិត្តសាស្ត្រទីផ្សារត្រូវបានរាប់បញ្ចូលទៅក្នុងថ្លៃរបស់ភាគហ៊ុនរួចជាស្រេចទៅហើយ។ អាចនិយាយបានជាទ្រឹស្តីគឺ ការផ្គត់ផ្គង់ និងតម្រូវការភាគហ៊ុននៅក្នុងទីផ្សារ។ តម្រូវការ ជាទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃទំនិញ X មួយទៅនឹងបរិមាណរបស់ទំនិញ X នោះដែលអ្នកទិញចង់ និងមានលទ្ធភាពទិញក្នុងរយៈពេលមួយជាកំណត់ ដោយលក្ខខណ្ឌកត្តាដទៃទៀតមិនប្រែប្រួល[24]។ ច្បាប់តម្រូវការ បានចែងថាប្រសិនបើកត្តាដទៃទៀតនៅថេរដដែល ហើយថ្លៃទំនិញ X មួយបានកើនឡើងនាំឱ្យបរិមាណទំនិញ X នោះថយចុះ និងច្រាសមកវិញ។ ការប្រែប្រួលតម្រូវការបណ្តាលមកពីកត្តាដូចជា ៖

- ចំណង់ចំណូលចិត្តអតិថិជន
- ចំណូលអតិថិជន
- ថ្លៃទំនិញដទៃទៀត
- ចំនួនអតិថិជន
- ក្តីសង្ឃឹមក្នុងពេលអនាគត។

ការផ្គត់ផ្គង់ គឺជាទំនាក់ទំនងស្របគ្នារវាងថ្លៃទំនិញ X មួយទៅនឹងបរិមាណរបស់ទំនិញ X នោះដែលអ្នកលក់ចង់ និងមានលទ្ធភាពផ្គត់ផ្គង់វានៅក្នុងអំឡុងពេលមួយជាកំណត់។ ច្បាប់ផ្គត់ផ្គង់បានចែងថាប្រសិនបើកត្តាដទៃទៀតនៅថេរដដែល ហើយថ្លៃនៃទំនិញ X មួយបានកើនឡើងនាំឱ្យអ្នកលក់មានបំណង និងលទ្ធភាពផ្គត់ផ្គង់បន្ថែមទៀត និងច្រាសមកវិញ។ ការប្រែប្រួលក្នុងការផ្គត់ផ្គង់បណ្តាលមកពីកត្តាដូចជា៖

- ថ្លៃកត្តាផលិតកម្មដែលប្រើប្រាស់ក្នុងការផលិតទំនិញ
- បច្ចេកវិទ្យាក្នុងការផលិត
- ថ្លៃកត្តាផលិតកម្មដទៃទៀតដែលចូលរួមផលិតកម្មដូចគ្នា (ទំនិញជំនួស)
- ចំនួនអ្នកលក់នៅលើទីផ្សារ
- អាកាសធាតុ។

[24] Dominick Salvatore, Microeconomic Theory Third Edition, page 14

## ៤.៣. អត្ថប្រយោជន៍នៃការវិនិយោគលើមូលបត្រ

ស្របតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ទីផ្សារមូលបត្រត្រូវបានបង្កើតឡើងដើម្បីជាមធ្យោបាយក្នុងការកៀរគរមូលធន ព្រមទាំងបែកចែកទុនសម្រាប់ការផ្ដល់ហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ មានការសិក្សាជាច្រើនបានបង្ហាញថា បណ្ដាប្រទេសដែលបានបើកឱ្យមានទីផ្សារភាគហ៊ុន មានការរីកចម្រើនលឿន ហើយក្រុមហ៊ុនជាច្រើននៅជុំវិញពិភពលោក កំពុងរីករាយក្នុងទទួលបានដើមទុនបន្ថែមតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ភាគហ៊ុន)[25]។ ដូចនេះទីផ្សារមូលបត្រកម្ពុជាបានផ្ដល់អត្ថប្រយោជន៍ជាច្រើនក្នុងការវិនិយោគមូលបត្រដូចជា ៖

### ៤.៣.១. ចំពោះវិនិយោគិន

- **ទទួលបានប្រាក់ចំណេញពីការជួញដូរភាគហ៊ុន និងទទួលបានភាគលាភ (Dividend)**

អត្ថប្រយោជន៍ចម្បងពីការវិនិយោគក្នុងទីផ្សារភាគហ៊ុន គឺឱកាសទទួលបានប្រាក់ចំណេញ។ ទីផ្សារភាគហ៊ុន មានទំនោរកើនឡើងនូវតម្លៃបើទោះបីជាភាគហ៊ុននីមួយៗកើន ឬធ្លាក់ចុះថ្លៃជារៀងរាល់ថ្ងៃក៏ដោយ។ ការវិនិយោគជាមួយក្រុមហ៊ុនដែលមានស្ថេរភាព និងមានសក្ដានុពលអាចនឹងធ្វើឱ្យវិនិយោគិនទទួលបានប្រាក់ចំណេញដោយទិញនៅពេលថ្លៃទាប ហើយលក់ទៅវិញនៅពេលភាគហ៊ុនឡើងថ្លៃ។ មួយវិញទៀត ការវិនិយោគភាគហ៊ុនច្រើនផ្សេងៗគ្នានឹងជួយបង្កើនទ្រព្យសម្បត្តិរបស់លោកអ្នក និងកាត់បន្ថយហានិភ័យវិនិយោគតាមរយៈឥទ្ធិពលកំណើនពីវិស័យផ្សេងៗក្នុងសេដ្ឋកិច្ច បើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលវិនិយោគិនបានវិនិយោគធ្លាក់ចុះថ្លៃក៏ដោយ។ ភាគហ៊ុនជាច្រើនផ្ដល់ឱ្យវិនិយោគិននូវប្រាក់ចំណូលក្នុងទម្រង់ជាភាគលាភ ដែលជាចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនរកបាន ហើយបង់ចំណែកនោះជូនដល់វិនិយោគិនប្រចាំឆ្នាំ។ វិនិយោគិនអាចប្រើប្រាស់ភាគលាភសម្រាប់ទុកចាយវាយនៅពេលចូលនិវត្តន៍ ឬយកទៅធ្វើការវិនិយោគបន្ត។

- **ការទិញភាគហ៊ុនជាជម្រើសល្អបំផុតសម្រាប់ការសន្សំ**

នៅក្នុងប្រទេសដែលបានបង្កើតទីផ្សារភាគហ៊ុនច្រើនឆ្នាំ វិនិយោគិនជាច្រើនជ្រើសរើសយកភាគហ៊ុន ជំនួសឱ្យការវិនិយោគជម្រើសផ្សេងទៀតដូចជា សញ្ញាបណ្ណ (មូលបត្របំណុល) អចលនទ្រព្យ ។ល។ ដោយសារតែភាគហ៊ុនជាជម្រើសសម្រាប់ការវិនិយោគដ៏ល្អមួយ ដែលអាចបង្កើនប្រាក់ក្នុងអត្រាចំណូលខ្ពស់ ជាងជម្រើសវិនិយោគផ្សេងៗទៀតក្នុងរយៈពេលវែង។ យ៉ាងណាមិញ វិនិយោគិនក្នុងទីផ្សារភាគហ៊ុន ក៏ត្រូវប្រឈមនឹងហានិភ័យខ្លះផងដែរ ក៏ប៉ុន្តែវិនិយោគិននៅមាន

[25] ព្រឹត្តិបត្រមូលបត្រ, ឆ្នាំ ២០១៧, ទំព័រ ៦

ពេលវេលា និងឱកាសល្អៗច្រើនទៀត ដើម្បីវិនិយោគក្នុងទីផ្សារភាគហ៊ុន។ បើក្រឡេកមើលករណីនៅសហរដ្ឋអាមេរិកតម្លៃភាគហ៊ុនបានកើនឡើងប្រហែល ១០% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេល ១ សតវត្សចុងក្រោយនេះ ហើយអាចសង្ខេបជារួមបានថា រឿងល្អមានច្រើនជាងរឿងមិនល្អនៅក្នុងទីផ្សារភាគហ៊ុន។ ការវិនិយោគិនភាគហ៊ុន មានសារៈសំខាន់ណាស់ សម្រាប់ការសន្សំ និងវិនិយោគសម្រាប់អនាគត ហើយអ្នកជំនាញផ្នែកវិនិយោគភាគច្រើនក្នុងពិភពលោក សុទ្ធតែយល់ស្របថា ការ វិនិយោគភាគហ៊ុន ជាជម្រើសល្អបំផុតសម្រាប់ការសន្សំ និងការវិនិយោគសម្រាប់ពេលចូលនិវត្តន៍។

- ❖ **ទទួលបានការលើកទឹកចិត្តពន្ធដារ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០% លើការប្រាក់ និង/ឬភាគលាភដែលបានមកពីការកាន់កាប់ និង/ឬការទិញ លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រចូលជាធរមាននៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥។

- ❖ **យុទ្ធសាស្ត្រក្នុងការចាកចេញ**

- វិនិយោគិន អាចដកប្រាក់វិនិយោគរបស់ខ្លួនចេញ តាមរយៈការលក់មូលបត្រកម្មសិទ្ធិ នៅពេលដែលវិនិយោគិនពិនិត្យឃើញថាក្រុមហ៊ុនមានស្ថានភាពមិនល្អ។
- វិនិយោគិន អាចដកខ្លួនទៅវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលផ្ដល់ផលចំណេញខ្ពស់។

### ៣.៣.២. ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

- ទទួលបានមូលធនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនឱ្យកាន់តែធំ និងមានភាពរីកចម្រើន។
- អាចប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ជំរុញឱ្យសាធារណៈជនស្គាល់ពីក្រុមហ៊ុន និងមានកេរ្តិ៍កាន់តែល្បី។
- រក្សាបុគ្គលិកខ្លួន និងទាក់ទាញអ្នកមានសមត្ថភាព។

### ៤.៦.៣. ចំពោះសេដ្ឋកិច្ច

- ជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគនៅក្នុងសេដ្ឋកិច្ច។
- ជួយពូនផ្ដុំមូលធនតូចៗ ទៅជាមូលធនធំមួយ ដើម្បីវិនិយោគនៅក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។

- ជួយទាក់ទាញ និងស្រូបយកមូលធនពីបរទេស។
- ជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ជួយជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។
- ជួយបង្កើតការងារធ្វើឱ្យប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល។

## ៤.៤. ការយល់ដឹងអំពីហានិភ័យលើការវិនិយោគលើមូលបត្រ

ការវិនិយោគភាគហ៊ុននៅផ្សារមូលបត្រកម្ពុជា គឺជាការចូលហ៊ុនរកស៊ីជាមួយក្រុមហ៊ុនដែលចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ដូច្នេះហានិភ័យនៃការវិនិយោគនេះ គឺដូចគ្នានឹងហានិភ័យនៃអាជីវកម្មក្រុមហ៊ុនមួយដូច្នោះដែរ។ ជាការពិតណាស់ ថ្លៃភាគហ៊ុនមានការប្រែប្រួលជារៀងរាល់ថ្ងៃ។ បើប្រៀបធៀបជាមួយឧបករណ៍ហិរញ្ញវត្ថុដទៃទៀត គេអាចនិយាយបានថា ភាគហ៊ុនងាយបង្កហានិភ័យជាងគេ។ ហានិភ័យទាំងនោះមានដូចជា ហានិភ័យនៃការបាត់បង់ចំណែកទីផ្សារទៅដៃគូប្រកួតប្រជែង ហានិភ័យនៃការមិនទូទាត់សងពីអតិថិជន ហានិភ័យនៃការឡើងថ្លៃវត្ថុធាតុដើម ហានិភ័យនៃការធ្វើបាតុកម្ម/កូដកម្មរបស់បុគ្គលិកជាដើម ដែលសុទ្ធសឹងជាកត្តាដែលអាចកើតឡើង និងធ្វើឱ្យក្រុមហ៊ុនខាតបង់។ ប៉ុន្តែចំពោះក្រុមហ៊ុនចុះបញ្ជី ក៏អាចមានផងដែរ ហានិភ័យមួយចំនួនបន្ថែមទៀត ដោយសារម្ចាស់ភាគហ៊ុនភាគច្រើនលើសលុបមិនបានគ្រប់គ្រងអាជីវកម្មដោយផ្ទាល់ គឺបានត្រឹមតែទទួលព័ត៌មានរាយការណ៍ដោយក្រុមហ៊ុនប៉ុណ្ណោះ។ ហានិភ័យទាំងនោះរួមមាន ការក្លែងបន្លំបញ្ជីគណនេយ្យ ការរាយការណ៍មិនពេញលេញឬធ្វើឱ្យយល់ច្រឡំ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនជាដើម។ ក៏ប៉ុន្តែវិនិយោគិនក៏ត្រូវចងចាំផងដែរថា ភាពមិនប្រាកដប្រជានៅក្នុងទីផ្សារភាគហ៊ុននេះហើយ ដែលជាលក្ខណៈពិសេសអចិន្ត្រៃយ៍នៃទស្សនៈវិនិយោគភាគហ៊ុន ដែលមានន័យថា ហានិភ័យគឺតែងតែជាផ្នែកមួយនៃការវិនិយោគ។ ឥរិយាបទក្នុងការវិនិយោគអាចជួយកំណត់ និងគ្រប់គ្រងហានិភ័យរបស់អ្នកនៅពេលធ្វើការវិនិយោគ។ វិនិយោគិន គួរកំណត់កម្រិតអតិបរមានៃការចំណេញ ឬខាតបង់ និងធ្វើការសម្រេចចិត្តឱ្យបានម៉ត់ចត់ មុនពេលធ្វើការជួញដូរភាគហ៊ុន។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលក៏ដូចជាគណៈកម្មការមូលបត្រកម្ពុជាបានយល់ច្បាស់អំពីបញ្ហានេះ ហើយបានបង្កើតនិងដាក់ឱ្យអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាសំដៅកាត់បន្ថយជាអតិបរិមានូវរាល់ហានិភ័យទាំងនេះ ដោយតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយនិងចុះបញ្ជីរៀបចំនិងផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានសំខាន់ៗទាំងឡាយរបស់ក្រុមហ៊ុនឱ្យ

បានត្រឹមត្រូវនិងទាន់ពេលវេលា។ ព័ត៌មានទាំងអស់នេះមាននៅក្នុងឯកសារផ្ដល់ព័ត៌មាននៅពេលក្រុមហ៊ុនបោះផ្សាយភាគហ៊ុនជាលើកដំបូង របាយការណ៍ហិរញ្ញវត្ថុដែលផ្សព្វផ្សាយរៀងរាល់បីខែម្ដង និង ឯកសារផ្ដល់ព័ត៌មានជាបន្តបន្ទាប់ផ្សេងទៀត ដែលអាចរកបាននៅលើគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (www.csx.com.kh) គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា របស់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនបោះផ្សាយផ្ទាល់តែម្ដង។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការស្រាវជ្រាវ និងចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជា ក៏ដូចជានៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រនានា អស់រយៈពេលពីរខែកន្លងមកលើប្រធានបទ "ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា" ឃើញថាការសិក្សាស្រាវជ្រាវនេះ ពិតជាបានចែករំលែកចំណេះដឹងជាច្រើនទាក់ទងនឹងវិស័យមូលបត្រសម្រាប់វិនិយោគិន និងអ្នកដែលមានចំណាប់អារម្មណ៍ធ្វើការវិនិយោគលើមូលបត្រ។ ទោះជាមើលទៅទីផ្សារភាគហ៊ុននៅកម្ពុជាពុំសូវមានសន្ទុះខ្លាំងក្លាក៏ដោយ ប៉ុន្តែត្រឹមរយៈពេលប៉ុន្មានឆ្នាំក្រោយនេះ មានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាសាធារណៈរហូតដល់ទៅប្រាំក្រុមហ៊ុន នេះសបញ្ជាក់ឱ្យឃើញថា វិស័យមូលបត្រមានការរីកចម្រើនជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់។ លើសពីនេះទៅទៀត វិនិយោគិនត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនណា ដែលខ្លួនចង់វិនិយោគដោយផ្អែកលើការវិភាគទៅលើកត្តាមូលដ្ឋាន និងកត្តាបច្ចេកទេស។

បន្ថែមពីនេះទៅទៀត វិនិយោគិនត្រូវស្វែងយល់អំពីដំណើរការនៃការជួញដូរក្នុងទីផ្សារមូលបត្រមួយចំនួនដូចជា ថ្ងៃជួញដូរ ម៉ោងជួញដូរ ប្រភេទបញ្ជា ការដេញថ្លៃ បម្រែបម្រួលថ្លៃ ប្រតិបត្តិការជាត់ទាត់ និងទូទាត់ជាដើម។ ក្រៅពីមានចំណេះដឹងអប្បបរមា ក៏ដូចជាយល់ដឹងពីដំណើរការជួញដូរមូលបត្ររួចមក វិនិយោគិនក៏ត្រូវពិចារណាបន្ថែមពីហានិភ័យផ្សេងៗទៀត ដែលមានផលប៉ះពាល់ដល់វិនិយោគិន ក្រុមហ៊ុនបោះផ្សាយ និងសេដ្ឋកិច្ច ដើម្បីអាចឱ្យវិនិយោគិនត្រៀមខ្លួនក្នុងការកាត់បន្ថយហានិភ័យទាំងនោះនៅពេលដែលធ្វើការវិនិយោគលើមូលបត្រនៅកម្ពុជា។ ជាពិសេសនោះវិនិយោគគួរសិក្សាស្វែងយល់បន្ថែមលើអត្ថប្រយោជន៍ដល់ខ្លួន និងសេដ្ឋកិច្ចជាតិ ដើម្បីឱ្យមានការរីកចម្រើនឡើង។

ជាចុងក្រោយ អាចសន្និដ្ឋានបានថាវិស័យមូលបត្រនៅកម្ពុជានឹងអាចមានការរីកចម្រើនខ្លាំង នៅពេលវិនិយោគិនយល់ដឹងអំពីការត្រៀមខ្លួនក្នុងការវិនិយោគបានត្រឹមត្រូវ និងអត្ថប្រយោជន៍ជាច្រើនពីផ្សារមូលបត្រនៅកម្ពុជា តាមរយៈការផ្សព្វផ្សាយនានា ហើយជាពិសេសតាម រយៈការស្រាវជ្រាវរបាយករណ៍កម្មសិក្សានេះ ដែលផ្តល់សារៈសំខាន់សម្រាប់វិនិយោគិនក្នុងការត្រៀមខ្លួនវិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា។

## ២. អនុសាសន៍

ទីផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារដ៏ថ្មីស្រឡាងសម្រាប់សាធារណៈជនទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីព្រោះទីផ្សារមូលបត្រទើបដំណើរការបានរយៈពេលជាងប្រាំឆ្នាំប៉ុណ្ណោះ។ ហេតុដូចនេះហើយ ដើម្បីជម្រុញឱ្យផ្សារមូលបត្រកម្ពុជាមានសន្ទុះកាន់តែខ្លាំងក្លា និងកាន់តែរីកចម្រើនឡើងនោះ យើងខ្ញុំសូមចូលផ្ដល់ជាអនុសាសន៍ខ្លះៗដូចខាងក្រោម៖

- រដ្ឋាភិបាលគួរតែជំរុញលើកទឹកចិត្តឱ្យសហគ្រាសសាធារណៈ និងឯកជននានាឱ្យចូលរួមក្នុងការបោះផ្សាយលក់មូលបត្រ។ លើសពីនេះទៅទៀតគួរតែលើកទឹកចិត្តផ្នែកពន្ធដារឱ្យបានច្រើនជាងនេះ ក្នុងការទាក់ទាញក្រុមហ៊ុនឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- រដ្ឋាភិបាលគួរតែបន្ថឹងលើប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិដែលការពារផលប្រយោជន៍របស់វិនិយោគិន ដើម្បីបង្កើនភាពទំនុកចិត្តវិនិយោគិនក្នុងការវិនិយោគមូលបត្រឱ្យមានតម្លាភាព និងប្រសិទ្ធិភាព។
- គណៈកម្មការមូលបត្រកម្ពុជា ឬក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក៏ដូចជាក្រុមហ៊ុនមូលបត្រនានាគួរតែរៀបចំប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈឧបករណ៍ផ្សេងៗដូចជា ទូរទស្សន៍ បដា វិទ្យុ ទស្សនាវដ្ដី កាសែត ផ្ទាំងពាណិជ្ជកម្មនានា ឬក៏តាមប្រព័ន្ធ Internet ព្រោះថាបច្ចុប្បន្ននេះ ការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យសាធារណៈជនពុំទាន់មានការយល់ដឹងអំពីមូលបត្រ ព្រមទាំងដំណើរការទីផ្សារមូលបត្រសព្វថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែបន្តការបណ្ដុះបណ្ដាលបន្ថែមទៀតតាមរយៈ សិក្ខាសាលា ការតាំងពិពណ៌ ឬវគ្គបណ្ដុះបណ្ដាលផ្សេងៗដល់សាធារណៈជនទូទៅ ដើម្បីស្វែងយល់ពីវិស័យមូលបត្រនៅកម្ពុជា។
- គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែបញ្ជូនមន្ត្រី និងបុគ្គលិកទៅធ្វើការបណ្ដុះបណ្ដាលនៅបណ្ដាប្រទេសនានា ដែលទីផ្សារមូលបត្រមានការរីកចម្រើនឱ្យបានច្រើន ដើម្បីសិក្សាពីភាពខុសគ្នា និងកត្តាដែលអាចអភិវឌ្ឍឱ្យទីផ្សារមូលបត្រកម្ពុជារីកចម្រើនដូចប្រទេសទាំងនោះ។
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរតែបន្ថែមម៉ោងជួញដូរឱ្យមានរយៈពេលវែងជាសព្វថ្ងៃ ដើម្បីបង្កើនឱកាសដល់វិនិយោគិនទូទៅមានពេលវេលាច្រើនក្នុងការជួញដូរ ពីព្រោះសព្វថ្ងៃ រយៈនៃការជួញដូរអាចធ្វើអោយវិនិយោគិនគ្មានពេលវេលាគ្រប់គ្រាន់នោះទេ។

- គណៈកម្មការមូលបត្រ និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគួរស្នើសុំឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំកម្មវិធីសិក្សានានា ដើម្បីបញ្ជ្រាបចំណេះជាមូលដ្ឋានដល់សិស្សានុសិស្ស នៅតាមបណ្តាវិទ្យាល័យរាជធានី-ខេត្ត ឱ្យបានយល់ដឹងពីវិស័យមូលបត្រ ក្នុងការបណ្តុះវិស័យមូលបត្រឱ្យមានវិសាលភាពទូលំទូលាយ។

សរុបសេចក្តីមក ទីផ្សារមូលបត្រកម្ពុជាអាចរីកចម្រើនបានក៏ដោយសារការចូលរួមយ៉ាងសកម្មពីរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនមូលបត្រ និងវិនិយោគិននានាទាំងអស់ក្នុងការលើកទឹកចិត្ត អនុវត្ត និងផ្សព្វផ្សាយពីវិស័យនេះឱ្យកាន់តែមានភាពរីកចម្រើន។

# ឯកសារយោង

## ច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រកម្ពុជា


១. ច្បាប់ស្តីពី "មូលបត្ររដ្ឋ" ព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧។

២. ច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨/ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧។

៣. អនុក្រឹត្យស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា" លេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨។

៤. អនុក្រឹត្យស្តីពី "ការកែសម្រួលសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា" លេខ ៣៥៧ អនក្រ.តត ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

៥. ព្រះរាជក្រឹត្យស្តីពី "ការតែងតាំងអគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា" លេខ នស/រកត/១០១៤/១១៩៦/ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤។

៦. គោលការណ៍ណែនាំស្តីពី "ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន" លេខ ០០១ គ.ម.ក/គ.ណ.ន. ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២។

៧. គោលការណ៍ណែនាំស្តីពី "ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ" លេខ ០០២/១២ គ.ម.ក/គ.ណ.ន. ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

៨. ប្រកាសស្តីពី "ការអនុវត្តវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ" លេខ ០០៥ ១១ គ.ម.ក./ប្រ.ក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១។


## សៀវភៅ អត្ថបទ និងឯកសារសិក្សា


៩. គណៈកម្មការមូលបត្រកម្ពុជា (២០១៦), អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ", ភ្នំពេញ។

១០. គណៈកម្មការមូលបត្រកម្ពុជា (២០១៧), "ព្រឹត្តិបត្រមូលបត្រ", ចេញផ្សាយលេខ ២, ភ្នំពេញ។

១១. ឈាង ហ៊ុយ (២០១៣), "មូលដ្ឋានគ្រឹះនៃការវិនិយោគ", ភ្នំពេញ។

១២. បៀន សាំង (២០១១), "មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ", ភ្នំពេញ។

១៣. ទូន ផល្លា (២០១៤), "គោលការណ៍មីក្រូសេដ្ឋកិច្ច", ភ្នំពេញ។

១៤. Dominick Salvatore (1991), "Theory and Problem of Microeconomic Theory 3/ed", New York។

១៥. ភ្នំពេញ អេសអ៊ីស្សិត (SEZ Phnom Penh), (២០១៦), "ឯកសារផ្តល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង", ភ្នំពេញ។

១៦. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (P.A.S), (២០១៧), "ឯកសារផ្តល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង", ភ្នំពេញ។

### បទបង្ហាញ សិក្ខាសាលា និងការតាំងពិព័រណ៍ទាក់ទងនឹងវិស័យមូលបត្រ

១៧. ផ្សារមូលបត្រកម្ពុជា, ស្តីពី "ពិព័រណ៍ភាគហ៊ុនកម្ពុជា My First Stock", តាំងពិព័រណ៍នៅផ្សារទំនើបអ៊ីអនម៉ល ជាន់ផ្ទាល់ដី, ភ្នំពេញ, ១៩ កុម្ភៈ ២០១៧។

១៨. គុណ រីតា, ស្តីពី "សេចក្តីសង្ខេបស្តីពីទីផ្សារមូលបត្រកម្ពុជា" បទបង្ហាញនៅធនាគារកម្ពុជាសាធារណៈ ជាន់ទី៦, ១២ មីនា ២០១៧។

១៩. ម៉ុក រ៉ាឌី, ស្តីពី "ការវិនិយោគលើវិស័យមូលបត្រ" សិក្ខាសាលានៅគណៈកម្មការមូលបត្រកម្ពុជា, ២៩ មិថុនា ២០១៧។

២០. រិន រដ្ឋា, ស្តីពី "ទីផ្សារមូលបត្រកម្ពុជា" បទបង្ហាញនៅគណៈកម្មការមូលបត្រកម្ពុជា, ២៩ ឧសភា ២០១៧។

២១. ហ៊ លីគា, ស្តីពី "ការស្វែងយល់ពីទីផ្សារមូលបត្រនៃការវិភាគមូលដ្ឋាន" បទបង្ហាញនៅ គណៈកម្មការមូលបត្រកម្ពុជា, ៣០ មិថុនា ២០១៧។

២២. ទ្រី ថៃលី, ២០១៧, ទីផ្សារមូលបត្រកម្ពុជា", បទបង្ហាញនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ១៦ កក្កដា។

### របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

២៣. ស៊ូ សុជា និងអ៊ឹង នីតា (២០១៥), "ការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា និងការវិភាគលើភាគហ៊ុន" សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

២៤. មាស លីដា និងរ៉ាន់ វល័ក្ខណ៍ (២០១៦), "ការត្រៀមខ្លួនវិនិយោគរបស់វិនិយោគិនក្នុងទីផ្សារមូលបត្រកម្ពុជា" សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### គេហទំព័រ

២៥. គណៈកម្មការមូលបត្រកម្ពុជា www.secc.gov.kh

២៦. ផ្សារមូលបត្រកម្ពុជា www.csx.com.kh

២៧. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ www.ppwsa.com.kh

២៨. ក្រុមហ៊ុន ហ្គ្រែន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី www.grandtwin.com.kh

២៩. កំពង់ផែស្វយ័តក្រុងភ្នំពេញ www.ppap.com.kh

៣០. ភ្នំពេញ អេស អ៊ី ហ្សិត ភីអិលស៊ី www.ppsez.com.kh

៣១. កំពង់ផែស្វយ័តក្រុងព្រះសីហនុ www.pas.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:......០០១..........គ.ម.ក/ ត.ណ.ន.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១២

# គោលការណ៍ណែនាំ

# ស្តីពី

# ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងប្រកាសលេខ ០០៨ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) សូមចេញនូវគោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន (Investor Identification Number) ដូចខាងក្រោម÷

## ១. ការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

បុគ្គលទាំងឡាយណាដែលមានបំណងធ្វើការវិនិយោគនៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវចុះឈ្មោះនៅ **គ.ម.ក** ដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី **គ.ម.ក** មុននឹងធ្វើសកម្មភាពជួញដូរមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការចុះឈ្មោះដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនមានជម្រើសពីរគឺដាក់ពាក្យស្នើសុំមក **គ.ម.ក** ដោយផ្ទាល់ ឬដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

## ២. ដំណើរការនៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន និងឯកសារភ្ជាប់

វិនិយោគិនដែលមានបំណងសុំលេខអត្តសញ្ញាណវិនិយោគិនត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

### ក. សម្រាប់វិនិយោគិនជារូបវន្តបុគ្គល

វិនិយោគិនជារូបវន្តបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវ:

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ក**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។
  - លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ។
  - ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

**ខ. សម្រាប់វិនិយោគិនជានីតិបុគ្គល**

វិនិយោគិនជានីតិបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវ:

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ខ**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាបណ្ណធ្វើអាជីវកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។
  - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន។
  - ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវរបស់អភិបាលនីមួយៗ។
  - លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
  - បញ្ជីឈ្មោះអ្នកដែលមានសិទ្ធិ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ។

<u>**បញ្ជាក់:**</u> ករណីវិនិយោគិនដាក់ពាក្យស្នើសុំមក **គ.ម.ក.** ដោយផ្ទាល់ វិនិយោគិនត្រូវផ្តល់នូវពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ព្រមទាំងឯកសារភ្ជាប់ដែលមានភាពត្រឹមត្រូវមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

ករណីវិនិយោគិនដាក់ពាក្យស្នើសុំ តាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក.** ក្រុមហ៊ុនមូលបត្រត្រូវពិនិត្យពីភាពត្រឹមត្រូវ និងទទួលខុសត្រូវលើព័ត៌មានរបស់វិនិយោគិន មុនបញ្ជូនឯកសារទាំងនោះមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

**៣. ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន**

បន្ទាប់ពីវិនិយោគិនបានបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនត្រឹមត្រូវតាមការណែនាំខាងលើ និងបានផ្តល់ជូនឯកសារភ្ជាប់ត្រឹមត្រូវ និងគ្រប់គ្រាន់មក **គ.ម.ក.** **គ.ម.ក.** នឹងផ្តល់ជូនលេខអត្តសញ្ញាណវិនិយោគិន ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រក្នុងរយៈពេល ០២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់អេឡិចត្រូនិច (Soft copy) ឬរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់បោះពុម្ព (Hard copy) ។ វិនិយោគិនមួយទទួលបានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។

**គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា
Securities and Exchange Commission of Cambodia

ទម្រង់ ក
FORM A

រូបថត ៤x៦
របស់រូបវន្តបុគ្គល
ថតចំពីមុខក្នុងរយៈពេល
៦ខែចុងក្រោយ
Photograph of investor taken within the last six months, 4x6

# ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
# INVESTOR IDENTIFICATION NUMBER APPLICATION FORM

## សម្រាប់រូបវន្តបុគ្គល
## FOR INDIVIDUAL INVESTOR

## ក. ព័ត៌មានផ្ទាល់ខ្លួន
## A. PERSONAL INFORMATION

នាមត្រកូល (អក្សរខ្មែរ) Surname (Khmer) ............ (អក្សរឡាតាំង) (Latin) ............

នាមខ្លួន (អក្សរខ្មែរ) Given Name (Khmer) ............ (អក្សរឡាតាំង) (Latin) ............

ថ្ងៃ ខែ ឆ្នាំកំណើត Date of Birth | D | D | M | M | Y | Y | Y | Y |

ភេទ Gender ☐ ប្រុស Male ☐ ស្រី Female

លក្ខន្តិកៈគ្រួសារ Marital Status ☐ នៅលីវ Single ☐ មានគ្រួសារ Married ☐ លែងលះ Divorced

សញ្ជាតិ Nationality ☐ សញ្ជាតិខ្មែរ Cambodian ☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ............

ក្នុងករណីជនបរទេសសូមបញ្ជាក់ Foreigner Please Specify ☐ និវាសនជន Resident ☐ អនិវាសនជន Non Resident

ប្រភេទបណ្ណសម្គាល់អត្តសញ្ញាណ Identification Type
☐ លេខអត្តសញ្ញាណប័ណ្ណ (សម្រាប់ខ្មែរ) Identification card Number ( For Cambodian) ............
☐ លេខលិខិតឆ្លងដែន (សម្រាប់បរទេស) Passport Number (For Foreigner) ............

កាលបរិច្ឆេទផុតសុពលភាពអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន Expiry Date of Identification card/Passport | D | D | M | M | Y | Y | Y | Y |

លេខអត្តសញ្ញាណកម្មសារពើពន្ធ (បើមាន) Taxpayer Identification Number (If applicable) ............

### ១. អាសយដ្ឋានទំនាក់ទំនង
### 1. Contact Address

អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជា
Contact Address in Cambodia

អគារលេខ No. ............ ផ្លូវ Street ............ ☐ ឃុំ / Commune / ☐ សង្កាត់ Sangkat ............

☐ ស្រុក / District / ☐ ក្រុង / Town/ ☐ ខណ្ឌ Khan ............ ☐ ខេត្ត / Province/ ☐ រាជធានី Capital ............

លេខទូរសព្ទលើតុ Telephone ............ លេខទូរសព្ទដៃ Mobile ............

អ៊ីម៉ែល E-mail ............

អាសយដ្ឋានទំនាក់ទំនងក្រៅប្រទេស (សម្រាប់វិនិយោគិនដែលមិនមានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា)
Contact Address in Your Country (For investor who does not have permanent address in Cambodia)

អគារលេខ No. ............ ផ្លូវ Street ............ ឃុំ Commune ............

☐ ស្រុក / District / ☐ ក្រុង Town ............ ☐ ខេត្ត / Province/ ☐ រាជធានី Capital ............

ប្រទេស Country ............ លេខទូរសព្ទលើតុ Telephone ............

អ៊ីម៉ែល E-mail ............ លេខទូរសព្ទដៃ Mobile ............

### ២. ព័ត៌មានអំពីមុខរបរ
### 2. Occupation

មុខរបរបច្ចុប្បន្ន Present Occupation ............ រយៈពេលនៃអតីតភាពការងារ Length of Work ............

ឈ្មោះកន្លែងធ្វើការ Name of Organization ............ ប្រភេទអាជីវកម្ម Type of Business ............

អាសយដ្ឋានកន្លែងធ្វើការ Address of Workplace ............

## ៣. ព័ត៌មានអំពីការសិក្សា
## 3. Educational Background

ផ្នែក
Field ....................

## ៤. បុគ្គលទំនាក់ទំនង
## 4. Contact Person

បុគ្គលដែលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់
Contact person when necessary

ឈ្មោះ
Name .................... ភេទ
Gender .......... ទូរសព្ទ
Mobile ..........

អាសយដ្ឋានស្នាក់នៅ
Home address ....................

## ៥. ចំណេះដឹងលើការវិនិយោគក្នុងវិស័យមូលបត្រ
## 5. Knowledge in Securities Investment

☐ ល្អណាស់ Very good ☐ ល្អ Good ☐ តិចតួច Limited ☐ គ្មាន Nothing

## ៦. ឯកសារធនាគាររបស់បុគ្គលដាក់ពាក្យស្នើសុំ
## 6. Banking Reference

ឈ្មោះធនាគារ
Bank Name ....................

លេខគណនីធនាគារ
Account Number ....................

## ៧. ឯកសារភ្ជាប់សម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
## 7. Enclosed Documents to Apply for Investor Identification Number

☐ អត្តសញ្ញាណប័ណ្ណថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីសញ្ជាតិខ្មែរ)
Certify true copy of ID Card (For Cambodian)

☐ លិខិតឆ្លងដែនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីមិនមែនសញ្ជាតិខ្មែរ)
Certify true copy of Passport (For Foreigner)

☐ ផ្សេងៗ (សូមបញ្ជាក់)
Other (Please Specify) ....................

**ខ្ញុំសូមធានាចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើរួមទាំងឯកសារភ្ជាប់ពិតជាត្រឹមត្រូវមែន**

I hereby take full responsibility against the law of the Kingdom of Cambodia, that all above information and documents enclosed are true and correct.

ថ្ងៃទី ខែ ឆ្នាំ :
Date: | D | D | M | M | Y | Y | Y | Y |

ហត្ថលេខា
Signature ____________________ ឬ
or

ស្នាមមេដៃស្តាំ
Right Thumb Fingerprint

## ខ. សម្រាប់ក្រុមហ៊ុនមូលបត្រ (ករណីដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ)
## B. FOR SECURITIES FIRM (APPLYING VIA SECURITIES FIRM)

ឈ្មោះក្រុមហ៊ុនមូលបត្រ
Name of Securities Firm ....................

ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Name of Securities Representative ....................

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Comment of Securities Representative ....................

ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ
Signature of Securities Representative ____________________ ថ្ងៃទី ខែ ឆ្នាំ :
Date: | D | D | M | M | Y | Y | Y | Y |

## គ. សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
## C. FOR THE SECC'S USE ONLY

យោបល់របស់មន្ត្រីគ.ម.ក. ÷
SECC Comments :

....................

....................

ទម្រង់ ខ
FORM B

គណៈកម្មការមូលបត្រកម្ពុជា
Securities and Exchange Commission of Cambodia

រូបថត ៤x៦ របស់អ្នកតំណាង ថតក្នុងរយៈពេល ៦ខែចុងក្រោយ
Photograph of representative taken within the last six months, 4x6

# ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
# INVESTOR IDENTIFICATION NUMBER APPLICATION FORM
## សម្រាប់នីតិបុគ្គល
## FOR INSTITUTIONAL INVESTOR

## ក. ព័ត៌មានរបស់នីតិបុគ្គល
## A. Institutional Information

ឈ្មោះនីតិបុគ្គល (អក្សរខ្មែរ)
Name of Institution (Khmer) ..........

ឈ្មោះនីតិបុគ្គល (អក្សរឡាតាំង)
Name of Institution (Latin) ..........

ថ្ងៃ ខែ ឆ្នាំចុះបញ្ជីពាណិជ្ជកម្ម
Date of Registration D D M M Y Y Y Y

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
Expiry Date of Company Registration Certificate D D M M Y Y Y Y

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពអាជ្ញាប័ណ្ណធ្វើអាជីវកម្ម (បើមាន)
Expiry Date of Company License (If applicable) D D M M Y Y Y Y

សញ្ជាតិនីតិបុគ្គល
Nationality of Institution

☐ សញ្ជាតិខ្មែរ
Cambodian

☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ)
Foreigner (Please Specify Nationality) ..........

ប្រភេទអាជីវកម្ម
Type of Business ..........

អាសយដ្ឋាននីតិបុគ្គល
Address of Institution

អគារលេខ
No. ..........

ផ្លូវ
Street ..........

☐ ឃុំ / Commune / ☐ សង្កាត់ Sangkat ..........

☐ ស្រុក / District / ☐ ក្រុង / Town/ ☐ ខណ្ឌ Khan ..........

☐ ខេត្ត / Province/ ☐ រាជធានី Capital ..........

ប្រទេស
Country ..........

លេខអត្តសញ្ញាណកម្មសារពើពន្ធ (បើមាន)
Taxpayer Identification Number (If applicable) ..........

### ឯកសារធនាគាររបស់នីតិបុគ្គល
### BANKING REFERENCE

ឈ្មោះធនាគារ
Bank Name ..........

លេខគណនីធនាគារ
Account Number ..........

## ខ. បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬ អ្នកតំណាង
## B. AUTHORIZED PERSON TO SIGN ON BEHALF OF INSTITUTION OR REPRESENTATIVE

នាមត្រកូល (អក្សរខ្មែរ)
Surname (Khmer) ..........

(អក្សរឡាតាំង)
(Latin) ..........

នាមខ្លួន (អក្សរខ្មែរ)
Given Name (Khmer) ..........

(អក្សរឡាតាំង)
(Latin) ..........

ថ្ងៃ ខែ ឆ្នាំកំណើត
Date of Birth D D M M Y Y Y Y

ភេទ
Gender

☐ ប្រុស Male

☐ ស្រី Female

លក្ខន្តិកៈគ្រួសារ
Marital Status

☐ នៅលីវ Single

☐ មានគ្រួសារ Married

☐ លែងលះ Divorced

សញ្ជាតិ
Nationality

☐ សញ្ជាតិខ្មែរ
Cambodian

☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ)
Foreigner (Please Specify Nationality) ..........

ប្រភេទបណ្ណសម្គាល់អត្តសញ្ញាណ
Identification Type

☐ លេខអត្តសញ្ញាណប័ណ្ណ (សម្រាប់ខ្មែរ)
Identification card Number ( For Cambodian) ..........

☐ លេខលិខិតឆ្លងដែន (សម្រាប់បរទេស)
Passport Number (For Foreigner) ..........

### ១. អាសយដ្ឋានទំនាក់ទំនងរបស់បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬអ្នកតំណាង
### 1. Contact Address of the Authorized Person or Representative

អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជា
Contact Address in Cambodia

អគារលេខ
No. ..........

ផ្លូវ
Street ..........

☐ ឃុំ/ Commune/ ☐ សង្កាត់ Sangkat ..........

☐ ស្រុក / District / ☐ ក្រុង/ Town/ ☐ ខណ្ឌ Khan ..........

☐ ខេត្ត / Province/ ☐ រាជធានី Capital ..........

លេខទូរសព្ទលើតុ
Telephone ..........

លេខទូរសព្ទដៃ
Mobile ..........

អ៊ីម៉ែល
E-mail ..........

អាសយដ្ឋានទំនាក់ទំនងក្រៅប្រទេស (សម្រាប់វិនិយោគិនដែលមិនមានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា)
Contact Address in Your Country (For investor who does not have permanent address in Cambodia)

អគារលេខ No. ____ ផ្លូវ Street ____ ឃុំ Commune ____

☐ ស្រុក / District / ☐ ក្រុង Town ____ ☐ ខេត្ត / Province/ ☐ រាជធានី Capital ____

ប្រទេស Country ____ លេខទូរសព្ទលើតុ Telephone ____

អ៊ីម៉ែល E-mail ____ លេខទូរសព្ទដៃ Mobile ____

## ២. ព័ត៌មានអំពីមុខរបរ
## 2. Occupation

មុខរបរបច្ចុប្បន្ន Present Occupation ____ រយៈពេលនៃអតីតភាពការងារ Length of Work ____

ឈ្មោះកន្លែងធ្វើការ Name of Organization ____ ប្រភេទអាជីវកម្ម Type of Business ____

អាសយដ្ឋានកន្លែងធ្វើការ Address of Workplace ____

## ៣. ព័ត៌មានអំពីការសិក្សា
## 3. Educational Background

ផ្នែក Field ____

## ៤. បុគ្គលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់ (ផ្សេងពីអ្នកតំណាងខាងលើ)
## 4. Contact Person when necessary ( Besides the representative above)

ឈ្មោះ Name ____ ភេទ Gender ____ ទូរសព្ទ Mobile ____

អាសយដ្ឋានស្នាក់នៅ Home address ____

## ៥. ចំណេះដឹងលើការវិនិយោគក្នុងវិស័យមូលបត្រ
## 5. Knowledge in Securities Investment

☐ ល្អណាស់ Very good ☐ ល្អ Good ☐ តិចតួច Limited ☐ គ្មាន Nothing

## ៦. ឯកសារភ្ជាប់សម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
## 6. Enclosed Documents To Apply For Investor Identification Number

☐ អត្តសញ្ញាណបណ្ណរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីសញ្ជាតិខ្មែរ)
Certify true copy of Identification Card of Representative (For Cambodian)

☐ លិខិតផ្ទេរសិទ្ធិអ្នកតំណាង
Power of Attorney

☐ លិខិតឆ្លងដែនរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីមិនមែនសញ្ជាតិខ្មែរ)
Certify true copy of Passport of Representative (For Foreigner)

☐ លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ
Certify true copy of Articles of Association

☐ អាជ្ញាបណ្ណធ្វើអាជីវកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន)
Certify true copy of Company License (If any)

☐ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន)
Certify true copy of Value Added Tax Certificate (If applicable)

☐ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ
Certify true copy of Company Registration Certificate

☐ ផ្សេងៗ (សូមបញ្ជាក់)
Other (Please Specify) ....................

**ខ្ញុំសូមធានាចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើរួមទាំងឯកសារភ្ជាប់ពិតជាត្រឹមត្រូវមែន**

I hereby take full responsibility against the law of the Kingdom of Cambodia, that all above information and documents enclosed are true and correct.

ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

ហត្ថលេខា និងឈ្មោះរបស់អ្នកតំណាង
Signature and Name of Representative ____ ឬ Or

ត្រាសម្គាល់នីតិបុគ្គល
Seal of the Institution

ស្នាមមេដៃស្តាំរបស់អ្នកតំណាង
Right Thumb Fingerprint of Representative

## គ. សម្រាប់ក្រុមហ៊ុនមូលបត្រ (ករណីដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ)
## C. FOR SECURITIES FIRM (APPLYING VIA SECURITIES FIRM)

ឈ្មោះក្រុមហ៊ុនមូលបត្រ Name of Securities Firm ____

ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ Name of Securities Representative ____

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Comment of Securities Representative ____

ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Signature of Securities Representative ____ ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

## ឃ. សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
## D. FOR THE SECC'S USE ONLY

យោបល់របស់មន្ត្រី គ.ម.ក. ÷
SECC Comments :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.....០០២/១២...គ.ម.ក/ក.ល.ខ.

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ២០១២

# គោលការណ៍ណែនាំ

## ស្តីពី

## ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០១ គ.ម.ក. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបដោយរលូន និងមានប្រសិទ្ធិភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** សូមចេញនូវគោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើបរិវិសកម្ម (Subscription) មូលបត្រកម្មសិទ្ធិ ដូចខាងក្រោម÷

### ក.ដំណាក់កាលប៊ុកបៀលឌីង:

**១)** បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិន ឱ្យចូលរួម។

**២)** ដើម្បីជំរុញឱ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបំរុងទុកសម្រាប់លក់ជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០

(សាមសិប) ភាគរយ ទៀត គឺត្រូវលៃបំរុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

៣) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុក-បៀលឌីង (Book-Building Form) ដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្ដល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

៤) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៥) ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

៦) វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៧) ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខ័ណ្ឌទី ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូល-បត្រកម្ពុជា។

៨) ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យបន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្ដល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយ ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោ-គិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

## ខ.ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ:

**៩)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

**១០)** វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

**១១)** វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

**១២)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០ (ដប់) ភាគរយវិញបាន។

**១៣)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata)។

**១៤)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលុប ដោយមានទាំង វិនិយោគិនជានីតិបុគ្គល ឬ/និង វិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលុប លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី ពីរភាគបី (២/៣) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនដ៏ច្រើនលើសលុបនោះ។

**១៥)** បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះវិញ។

**១៦)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកប៊ៀលឌីង វិនិយោគិនទាំងអស់ដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង ត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

**១៧)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកប៊ៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវធ្វើការបែងចែកទៅឱ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកប៊ៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង។

**១៨)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកប៊ៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា (Pro Rata)។

**១៩)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកប៊ៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង មានចំនួនទាបជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនទៅតាមការស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកប៊ៀលឌីង បានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវលៃបំរុងទុកសម្រាប់ការធ្វើប៊ុកប៊ៀលឌីង។

**២០)** ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែង ក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់។

**២១)** ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក.** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

**គណៈកម្មការមូលបត្រកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.................................គ.ម.ក

ទម្រង់ទី ០១

(លេខប៊ុកបៀលឌីង :.................................)

## ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង
## នៃក្រុមហ៊ុន .................................................

### ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនធានាទិញមូលបត្រ និងមូលបត្រកម្មសិទ្ធិ

យើងខ្ញុំជាក្រុមហ៊ុនធានាទិញមូលបត្រ :........................................................................................................................................................................................។

ក្រុមហ៊ុនបោះផ្សាយ :........................................................ បានតែងតាំងក្រុមហ៊ុនមូលបត្រយើងខ្ញុំ.......................................................................... (ឈ្មោះក្រុមហ៊ុនមូលបត្រ) ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ កាលពីថ្ងៃទី ......... ខែ ......... ឆ្នាំ ........... ។

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រយើងខ្ញុំ បានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្ដល់ព័ត៌មានជូន គ.ម.ក. ហើយទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. នៅថ្ងៃទី ...... ខែ ......... ឆ្នាំ ........។ ក្រុមហ៊ុនបោះផ្សាយបានកំណត់ថ្លៃលក់ចន្លោះពី...................... ដល់..................................ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

យើងខ្ញុំសូមបញ្ជាក់ថា វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ (Book-Building) ត្រូវជ្រើសរើសថ្លៃណាមួយក្នុងចំណោមចន្លោះថ្លៃដែលក្រុមហ៊ុនបានកំណត់។ វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ ត្រូវតម្កល់ប្រាក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលមានបំណងធ្វើបរិវិសកម្ម (សូមអានគោលការណ៍ណែនាំរបស់ គ.ម.ក. ស្ដីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដែលអាចទាញយកតាម http://www.secc.gov.kh/khmer/m24.php?pn=3 )។

វិនិយោគិនដែលមានបំណងចូលរួមក្នុងការស្ទាបស្ទង់ថ្លៃ សូមបំពេញនូវព័ត៌មាន ដូចខាងក្រោម÷

### ព័ត៌មានពាក់ព័ន្ធនឹងវិនិយោគិនចូលរួមធ្វើប៊ុកបៀលឌីង

ក. វិនិយោគិនជារូបវន្តបុគ្គល:

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :................................................ ជាអក្សរឡាតាំង :................................................

ថ្ងៃខែឆ្នាំកំណើត :....................................... ភេទ : □ ប្រុស □ ស្រី
ទូរស័ព្ទលេខ :....................................... អ៊ីម៉ែល :.......................................។

លេខអត្តសញ្ញាណវិនិយោគិន[១] :.......................................

**ខ. វិនិយោគិនជានីតិបុគ្គល :**

□នីតិបុគ្គលសញ្ជាតិខ្មែរ □នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ
ឈ្មោះជាអក្សរខ្មែរ :....................................... ជាអក្សរឡាតាំង :.......................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) .......................................
ទូរស័ព្ទលេខ :....................................... អ៊ីម៉ែល :.......................................។

លេខអត្តសញ្ញាណវិនិយោគិន[២] :.......................................

SPECIMEN

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើប៊ុកបៀលនឹងតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

## ព័ត៌មានពាក់ព័ន្ធនឹងការស្នោបស្នងថ្លៃលក់មូលបត្រកម្មសិទ្ធិ

១. ថ្លៃមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :.......................................។
(វិនិយោគិន ត្រូវជ្រើសរើសយកថ្លៃមួយក្នុងចន្លោះថ្លៃ ដូចបានកំណត់ខាងលើ)
២. ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :.......................................
៣. ចំនួនទឹកប្រាក់សរុប (ថ្លៃមូលបត្រកម្មសិទ្ធិ x ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម) :.......................................។

ធ្វើនៅ.................ថ្ងៃទី......... ខែ......... ឆ្នាំ...........

ហត្ថលេខា ឬ/និង ត្រា[៣]

ហត្ថលេខា-ត្រា និងឈ្មោះ

.......................................

**តំណាងក្រុមហ៊ុនមូលបត្រ**

ឈ្មោះវិនិយោគិន

[១] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ករណីវិនិយោគិនជានីតិបុគ្គល

## គំរូវិក្កយបត្រ

## ប៊ុកបៀលឌីងមូលបត្រ

**វិក្កយបត្រប្រាក់តម្កល់នៃក្រុមហ៊ុនមូលបត្រ....................**

លេខប៊ុកបៀលឌីង:........................

SPECIMEN

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើប៊ុកបៀលឌីងឈ្មោះ :..........................................................

លេខអត្តសញ្ញាណវិនិយោគិន :........................................................

ចំនួនទឹកប្រាក់សរុបបានទទួល :.....................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ............................ ធនាគារ :............................................។

ហត្ថលេខា- ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:...............................គ.ម.ក

**ទម្រង់ទី ០២**

**លេខបរិវិសកម្ម :...............................**

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ
## សម្រាប់វិនិយោគិនដែលបានចូលរួមធ្វើប៊ុកបៀលឌីង
## ក្រុមហ៊ុនបោះផ្សាយ..........................................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន ....................... ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ......................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ......................។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់បុគ្គលិកមានចំនួន .................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ....................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ ឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី ................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

## ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

ឈ្មោះជាអក្សរខ្មែរ :.......................................... ជាអក្សរឡាតាំង :.......................................................

លេខប៊ុកបៀលឌីង :.......................................... លេខអត្តសញ្ញាណវិនិយោគិន :......................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីផ្ញើដូវ :.................... លេខគណនីផ្ញើដូវ[១] :.......................

---

[១] ថតចម្លងលេខគណនីផ្ញើដូវ ០១ ច្បាប់ ភ្ជាប់មកជាមួយ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

### ក. វិនិយោគិនដែលទទួលបានជោគជ័យ

| ចំនួនមូលបត្រកម្មសិទ្ធិដែលបានបម្រុងឱ្យក្នុងប៊ុកបៀលឌីង | ចំនួនទឹកប្រាក់តម្កល់ជាក់ស្ដែងសរុបសម្រាប់ប៊ុកបៀលឌីង (១) |
|---|---|
| .............................................. | .............................................. |
| ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
| .............................................. | .............................................. |
| **ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម**<br>(២) - (១) | |
| .............................................................................................. | |

SPECIMEN

### ខ. វិនិយោគិនដែលមិនទទួលបានជោគជ័យ

| ចំនួនទឹកប្រាក់តម្កល់ជាក់ស្ដែងសរុបសម្រាប់ប៊ុកបៀលឌីង (១) | ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
|---|---|---|
| .............................................. | .............................................. | .............................................. |
| **ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម**<br>(២) - (១) | | |
| .............................................................................................. | | |

## សេចក្ដីថ្លែងសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្ដល់ព័ត៌មានក្នុងទម្រង់ជា៖

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :.............................................. ឬ ☐ ផ្សេងពីនេះ : ..............................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្ដល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញ

មូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។  ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____**

ហត្ថលេខា ត្រា និងឈ្មោះ

SPECIMEN

ហត្ថលេខា ឬ/និងត្រា[២]

.........................................

តំណាងក្រុមហ៊ុនមូលបត្រ

.........................................

ឈ្មោះអ្នកធ្វើបរិវិសកម្ម

---

[២] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

# គំរូវិក្កយបត្រ
# បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នៃក្រុមហ៊ុនមូលបត្រ ..........................................**

SPECIMEN

លេខបរិវិសកម្ម :..............................

កាលបរិច្ឆេទ : _ _/_ _/_ _ _ _

អ្នកធ្វើបរិវិសកម្មឈ្មោះ :...............................................................

លេខអត្តសញ្ញាណវិនិយោគិន :.......................................................

ចំនួនទឹកប្រាក់សរុបបានទទួល :.....................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ............................ ធនាគារ :.........................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..............................គ.ម.ក

**ទម្រង់ទី ០៣**

**លេខបរិវិសកម្ម :**..............................

# ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ សម្រាប់វិនិយោគិនដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយ..............................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន ............................ ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង .......................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ......................។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់បុគ្គលិកមានចំនួន ................ ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ..........................ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី ................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

## ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងការធ្វើបរិវិសកម្ម

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.............................................. ជាអក្សរឡាតាំង :..................................................

ថ្ងៃខែឆ្នាំកំណើត :.................................................. ភេទ : ☐ ប្រុស ☐ ស្រី

ទូរស័ព្ទលេខ :........................................................ អ៊ីម៉ែល :..........................................................។

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................... លេខគណនីជួញដូរ[១] :................

[១] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

លេខអត្តសញ្ញាណវិនិយោគិន[២] :............................................

**ខ. វិនិយោគិនជានីតិបុគ្គលៈ**

☐នីតិបុគ្គលសញ្ជាតិខ្មែរ ☐នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.............................................. ជាអក្សរឡាតាំង :..................................................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ......................................

ទូរស័ព្ទលេខ :........................................................ អ៊ីម៉ែល :..........................................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................. លេខគណនីជួញដូរ[៣] :................

លេខអត្តសញ្ញាណវិនិយោគិន[៤]:............................................

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើបរិវិសកម្មតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

SPECIMEN

## សំណើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

| ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលស្នើសុំធ្វើបរិវិសកម្ម | ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ចំនួនទឹកប្រាក់សរុបសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម |
|---|---|---|
| ................................ | ................................ | ................................ |

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលបានចូលរួមធ្វើបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :.......................................... ឬ ☐ ផ្សេងពីនេះ :..............................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិ

---

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៤] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

បដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញមូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____**

SPECIMEN

| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[៥] |
|---|---|
| ........................................ | ........................................ |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

[៥] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

# គំរូវិក្កយបត្រ
# បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនៃក្រុមហ៊ុន ..................................................**

SPECIMEN

លេខបរិវិសកម្ម :...............................

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើបរិវិសកម្មឈ្មោះ :...................................................................

លេខអត្តសញ្ញាណវិនិយោគិន :........................................................

ចំនួនទឹកប្រាក់សរុបបានទទួល :....................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : .............................. ធនាគារ :.......................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:......០០២..........គ.ម.ក/ស.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១១

# គោលការណ៍ណែនាំ
# ស្ដីពី
# យន្ដការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** សូមធ្វើការណែនាំនូវយន្ដការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

**១-** *ការដាក់លិខិតសម្ដែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្ដែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុច ដូចខាងក្រោម:

១- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្ដល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

*២- ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

*៣- ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

*៤- ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

*៥- ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

### ៦- *ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.*

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

### ៧- *ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

### ៨- *ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

### ៩- *ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០**- *ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**១១**- *ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្លាមជូន **គ.ម.ក.**។

**១២**- *ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**គណៈកម្មការមូលបត្រកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែង-តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះ-ផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ។

**មាត្រា ២.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ ÷

១. ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន ។

## ជំពូកទី ២

## សកម្មភាព និងលក្ខខណ្ឌ នៃការលើកទឹកចិត្តពន្ធដារ

### មាត្រា ៤.- ការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារ តាមរយៈ គ.ម.ក. ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ សម្រាប់រយៈពេល ៣ (បី) ឆ្នាំ ។

រយៈពេលនៃការលើកទឹកចិត្ត ៣ (បី) ឆ្នាំខាងលើនេះ ត្រូវគិតចាប់ផ្តើមពី ÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ ។

### មាត្រា ៥.- ការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញទាំងស្រុងក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ចំពោះ÷

១- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញដោយស្នងការសវនកម្មឯករាជ្យ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មពេញលេញ (បានបិទបញ្ជី និងចេញលិខិតបញ្ជាក់សារពើពន្ធសម្រាប់កាលបរិច្ឆេទ N-1, N-2 និង N-3) ។

២- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញពីកម្មវត្ថុនៃការធ្វើសវនកម្មឡើងវិញ ដោយអគ្គនាយកដ្ឋានពន្ធដារ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារនេះបានធ្វើសវនកម្មពេញលេញ ពោលគឺនៅមុនពេលដែលក្រុមហ៊ុន/សហគ្រាស ធ្វើការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ក្នុងរយៈពេល ៧ (ប្រាំពីរ) ឆ្នាំថយក្រោយ រាប់បន្ទាប់ពីឆ្នាំ N-3 ដែលបានធ្វើសវនកម្មដោយស្នងការសវនកម្មឯករាជ្យ ។ ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/សហគ្រាសធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

ការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះបំណុលពន្ធប្រយោលដែលជាបន្ទុករបស់អ្នកប្រើប្រាស់មានជាអាទិ៍ដូចជា អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធកាត់ទុកជាដើម ។

### មាត្រា ៦.- ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុក ជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ (ដប់ប្រាំ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក ។

### មាត្រា ៧.- ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៨.- ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ គ.ម.ក. ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ៖

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។ លិខិតប្រកាសពន្ធសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ គ.ម.ក. អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៩.- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលជាសាធារណៈរួច**

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី គ.ម.ក. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុន/ សហគ្រាសបានបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

**មាត្រា ១០.- ការជំនួស**

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ។

**មាត្រា ១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៥.

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៣៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៨/៩២៨ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការតែងតាំងអគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៩៦ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការតែងតាំងអគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៦៥ អនក្រ.តត ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-** ត្រូវបានតែងតាំងឯកឧត្តម **ស៊ូ សុជាតិ** អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ជាសមាជិកគណៈកម្មការមូលបត្រកម្ពុជា ជំនួសឯកឧត្តម **ម៉ិញ ឆានកុសល** ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់ប្រធានស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មការមូលបត្រកម្ពុជា
- ដូចមាត្រា ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**
**នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤**

| | កំណត់សម្គាល់ | ២០១៤ ពាន់រៀល | ២០១៣ ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | ៨៣៨.៦០៨.៧២៦ | ៨៥០.៣៨៨.១៥៣ |
| ទ្រព្យសម្បត្តិវិនិយោគ | ៧ | ២៦៦.៦០៨.៣៨៥ | ២៤១.៦៣៨.២១២ |
| ទ្រព្យសកម្មអរូបី | ៨ | ៩.៣៤១.១១៩ | ៩.៧៧១.៥៨៨ |
| | | ៨៥៤.៥៥៨.៦៣០ | ៨៨២.១៦០.៤០៧ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ១០ | ៤.០៤៦.៤៧២ | ៣.៥០២.១០៧ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១១ | ១៧.១០០.៧៧៤ | ១៤.៦២០.៣៥៦ |
| ប្រាក់បញ្ញើនៅធនាគាររយៈពេលខ្លី | ១២ | ១៦.៥៣០.៣២៤ | ១០.៤២៣.៦៣៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៣ | ៣៦.៤៧៧.៤០៤ | ២៦.៤៧៨.០៤៤ |
| | | ៧៤.៧០៤.៧៧៤ | ៥៥.៤២១.២៣០ |
| **ទ្រព្យសកម្មសរុប** | | ៩២៩.៣០០.៤០៤ | ៨៨៣.៥៨១.៦៣៧ |
| **មូលធន និងបំណុល** | | | |
| **មូលធន** | | | |
| ដើមទុន | ១៤ | ៤២៤.៨៩៩.៤៣១ | ៤២៤.០៩៩.៤៣១ |
| ទុនបម្រុងផ្សេងៗ | ១៥ | ៩.៧៦៧.៥៥៩ | ៧.៨៩៩.៥២៧ |
| ចំណេញរក្សាទុក | | ៣៨.២៥៧.៦៤១ | ៣.៤២៣.៥១៦ |
| **មូលធនសរុប** | | ៤៧៣.៨៨៥.០៣៦ | ៤៤០.៥៤៣.២៧៩ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៦ | ៣៨១.៦៤១.៦០៥ | ៣៩៩.១៧៧.០៨៨ |
| កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត | ១៧ | ៣៩.៣៥៧.៦៤៧ | ២៩.៥៥៩.៦៤៧ |
| បំណុលពន្ធពន្យារ | ១៨ | ៦.៣៤៧.៥៦៣ | ៦.៣៥៣.៥៥៨ |
| | | ៤២៧.៣៤៦.៤១៩ | ៤៣៥.៤៩០.២៩៩ |
| **បំណុលរយៈពេលខ្លី** | | | |
| បំណុលពន្ធលើប្រាក់ចំណេញ | | ១.៣៨៨.៥០១ | - |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៩ | ១០.៤៣៤.៤៧២ | ៩.០៧២.៥៥៧ |
| ប្រាក់កម្ចី | ១៦ | ១៧.៨៨៨.១៤៦ | ១២.៣៦០.២៨៨ |
| | | ២៧.៦២៨.៩០៩ | ២១.៤៣៣.២៤៥ |
| **បំណុលសរុប** | | ៤៥៥.៤១៥.៣២៨ | ៤៥៦.៩៥៤.៣៥៨ |
| **មូលធន និងបំណុលសរុប** | | ៩២៩.៣០០.៤០៤ | ៨៩៧.៤៩១.៦៣៧ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១០ ដល់ ទំព័រទី ៤៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សម្គាល់ | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|---|
| ចំណូល | ២០ | ១៦៨.៩៦៦.៦៣២ | ១៤៦.៤២០.៧៩៤ |
| ចំណាយ | | | |
| ចំណាយសម្ភារផ្គត់ផ្គង់ | ២១ | (៤៨.៩៨៦.៧៨០) | (៥១.៣៣៤.៩៦៨) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ២២ | (៥០.៣៥៥.៣៣០) | (៤២.៥០២.៣៣៤) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ២៣ | (១៤.២៦៧.០៩៥) | (១៣.៦៧៥.៩៧៤) |
| ចំណាយការជួសជុល និងថែទាំ | | (៥.៦១១.៧១០) | (៤.៤៩៩.៩៨៤) |
| ចំណាយវិភាគទាន និងការបរិច្ចាគ | | (៣.៣១១.៧២១) | (២.៧៣៨.៥៦៨) |
| ចំណាយរដ្ឋបាល | | (២.០៣៥.០៧០) | (១.៧៦៤.៤៦១) |
| ចំណាយទទួលភ្ញៀវ និងបដិសណ្ឋារកិច្ច | | (២.០០៨.៤២៩) | (១.៨០៩.២៧៨) |
| ចំណាយផ្សេងៗ | ២៤ | (៨.០២៥.១៦៨) | (៥.៧៧៥.៩៣២) |
| (ខាត)/ចំណេញផ្សេងៗ – សុទ្ធ | ២៥ | ៧៤១.១៤០ | ៧៧០.៨៤៩ |
| | | (១៣៣.៨៦០.១៦៣) | (១២៣.៣៣០.៦៥០) |
| ចំណេញប្រតិបត្តិការ | | ៣៥.១០៦.៤៦៩ | ២៣.០៩០.១៤៤ |
| ចំណូលការប្រាក់ | | ២៦.៨៨២.៧៧៤ | ៥៤.០៧៧.៨២៧ |
| ចំណាយការប្រាក់ | | (១២.៨៤៨.៥៨៣) | (១២.៤៣៩.៤៣០) |
| ចំណូលការប្រាក់-សុទ្ធ | ២៦ | ១៤.០៣៤.១៩១ | ៤១.៦៣៨.៣៩៧ |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | ៤៩.១៤០.៦៦០ | ៦៤.៧២៨.៥៤១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៧ | (៣.០១៤.៨៦៣) | (១.៤៣៩.១០៨) |
| **ចំណេញក្នុងឆ្នាំ** | | ៤៦.១២៥.៧៩៧ | ៦៣.២៨៩.៤៣៣ |
| ចំណូលលម្អិតផ្សេងៗ | | | |
| ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ក្នុងចំណេញ-ខាត ៖ | | | |
| ការវាស់វែងជាថ្មីនៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត | ១៧ | (១០.៨២៤.០០០) | - |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | ៣៥.៣០១.៧៩៧ | ៦៣.២៨៩.៤៣៣ |
| **ចំណេញរបស់ភាគហ៊ុនិក** | | ៤៦.១២៥.៧៩៧ | ៦៣.២៨៩.៤៣៣ |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | ៣៥.៣០១.៧៩៧ | ៦៣.២៨៩.៤៣៣ |

PORT AUTONOME DE SIHANOUKVILLE

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១០ ដល់ ទំព័រទី ៤៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | ដែលជារបស់ភាគហ៊ុនិក | | | |
|---|---|---|---|---|
| | មូលធនភាគហ៊ុន<br>ពាន់រៀល | ទុនបម្រុង<br>ពាន់រៀល | ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ៤២៨.៨៥៩.៨៣៦ | ៦.៨០១.៩៥៣ | (៥៧.៣៦៧.៩៤៣) | ៣៧៨.២៩៣.៨៤៦ |
| ចំណេញក្នុងឆ្នាំ | - | - | ៦៣.២៨៩.៤៣៣ | ៦៣.២៨៩.៤៣៣ |
| ចំណូលលម្អិតសរុប | - | - | ៦៣.២៨៩.៤៣៣ | ៦៣.២៨៩.៤៣៣ |
| ការផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ១.០៩៧.៩៧៤ | (១.០៩៧.៩៧៤) | - |
| ភាគលាភបានបង់ (កំណត់សម្គាល់ ២៨) | - | - | (១.០០០.០០០) | (១.០០០.០០០) |
| សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៤២៨.៨៥៩.៨៣៦ | ៧.៨៩៩.៩២៧ | ៣.៨២៣.៥១៦ | ៤៤០.៥៨៣.២៧៩ |
| | | | | |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ | ៤២៨.៨៥៩.៨៣៦ | ៧.៨៩៩.៩២៧ | ៣.៨២៣.៥១៦ | ៤៤០.៥៨៣.២៧៩ |
| ចំណេញក្នុងឆ្នាំ | - | - | ៤៦.១២៥.៧៩៧ | ៤៦.១២៥.៧៩៧ |
| ចំណូលលម្អិតផ្សេងៗ - ការវាស់វែងជាថ្មីនៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត | - | - | (១០.៨២៤.០០០) | (១០.៨២៤.០០០) |
| ចំណូលលម្អិតសរុប | - | - | ៣៥.៣០១.៧៩៧ | ៣៥.៣០១.៧៩៧ |
| ការផ្ទេរទៅទុនបម្រុង (កំណត់សម្គាល់ ១៥) | - | ១.៨៦៧.៦៣២ | (១.៨៦៧.៦៣២) | - |
| ភាគលាភបានបង់ (កំណត់សម្គាល់ ២៨) | - | - | (២.០០០.០០០) | (២.០០០.០០០) |
| សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ៤២៨.៨៥៩.៨៣៦ | ៩.៧៦៧.៥៥៩ | ៣៥.២៥៧.៦៨១ | ៤៧៣.៨៨៥.០៧៦ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១០ ដល់ ទំព័រទី ៤៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| | កំណត់សម្គាល់ | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ២៩ | ៤៩.៩៨៥.៨៦៣ | ៤២.៦៤៧.១៨២ |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (១.៦៦៦.៣៦២) | (១.៤៣៩.១០៨) |
| កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តបានបង់ | ១៧ | (២.៩៩២.០០០) | (៧០៦.៤៩៥) |
| សាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ | | ៤៥.៣២៧.៥០១ | ៤០.៥០១.៥៧៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | (១១.១៣៣.៤៧២) | (៨.០៧០.២៧៩) |
| ការទិញទ្រព្យសម្បត្តិវិនិយោគ | ៧ | (១៥.៥៦៧.៨៤៦) | (២៨.៨២៥.៥៤១) |
| ការទិញទ្រព្យសកម្មអរូបី | ៨ | - | (២១.៧៨៦) |
| ការតម្កល់ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារ | | (៦.១០៦.៦៨៥) | (៨.១៤៣.៥៧៧) |
| សាច់ប្រាក់បានពីប្រាក់កក់សម្រាប់ការជួលតំបន់សេដ្ឋកិច្ចពិសេស | | - | ៦៦០.០០០ |
| ការប្រាក់បានទទួល | | ៦២៨.៨១៩ | ៣២៥.៨០៣ |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ | | (៣២.១៧៩.១៨៤) | (៤៤.០៧៥.៣៨០) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | | (២.០០០.០០០) | (១.០០០.០០០) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ២២.៥៧៩.៨៨៧ | ២៤.៣៦១.២៦៤ |
| ការបង់សងប្រាក់កម្ចី | | (១០.៧៦៧.០០៩) | (៧.៧៣១.២៧២) |
| ការប្រាក់បានបង់ | | (១២.៨៥៨.៤៧៩) | (១២.៧២៤.១៤៨) |
| សាច់ប្រាក់/(បានប្រើក្នុង)បានមកពីសកម្មភាពហិរញ្ញប្បទាន | | (៣.០៤៥.៦០១) | ២.៩០៥.៨៤៤ |
| **កំណើន/(តំហយ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ១០.១០២.៧១៦ | (៦៦៧.៩៥៧) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ២៦.៤៧៥.០៨៨ | ២៧.១៤៣.០៤៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១៣ | ៣៦.៥៧៧.៨០៤ | ២៦.៤៧៥.០៨៨ |

PORT AUTONOME DE SIHANOUKVILLE

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី ១០ ដល់ ទំព័រទី ៤៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។